**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# សៀវភៅណែនាំ

# ស្តីពី

# ការរៀបចំគម្រោងសេវាកម្មក្រុង ស្រុក

**ខែធ្នូ ឆ្នាំ២០១៥**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ: ០៧៥ ភភរ /គ.ជ.អ.ប

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការរៀបចំគម្រោងសេវាកម្មក្រុងស្រុក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់នូវសៀវភៅណែនាំស្តីពីការរៀបចំគម្រោងសេវាកម្មក្រុង ស្រុក សម្រាប់ប្រើប្រាស់ក្នុងការសិក្សា និងការរៀបចំគម្រោងសេវាកម្មរបស់រដ្ឋបាលក្រុង ស្រុក។

**ប្រការ ២.-**

ក្រុមប្រឹក្សាក្រុង ស្រុក គណៈអភិបាលក្រុង ស្រុក បុគ្គលិករបស់ក្រុមប្រឹក្សាក្រុង ស្រុក និងអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំគម្រោងក្រុង ស្រុក ត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីនានាដែលបានកំណត់នៅក្នុងសៀវភៅណែនាំនេះ។

**ប្រការ ៣.-**

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

__**កន្លែងទទួល**__ ៖

- *ក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*
- *រដ្ឋបាលខេត្ត*
- *រដ្ឋបាលក្រុង ស្រុក*
- *រដ្ឋបាលឃុំ សង្កាត់*
- *ឯកសារ-កាលប្បវត្តិ*

# មាតិកា


សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការរៀបចំគម្រោងសេវាកម្មក្រុង ស្រុក ............i
មាតិកា ........................................................................................................................ iii


## ជំពូកទី១

## និដ្ឋភាពទូទៅនៃការរៀបចំគម្រោងសេវាកម្មក្រុង ស្រុក


១.១. សេចក្តីផ្តើម ........................................................................................................... ១
១.២. គោលបំណង ........................................................................................................... ១
១.៣. និយមន័យ ............................................................................................................. ២
១.៤. ប្រភេទផ្សេងៗនៃគម្រោងសេវាកម្មក្រុង ស្រុក ............................................................. ៣
១.៥. អ្នកពាក់ព័ន្ធនានាក្នុងការៀបចំគម្រោងសេវាកម្មក្រុង ស្រុក ............................................ ៥
១.៦. សេចក្តីសង្ខេបអំពីដំណើរការរៀបចំគម្រោងសេវាកម្មក្រុង ស្រុក ..................................... ១០


## ជំពូកទី២

## ការត្រៀមរៀបចំគម្រោងសេវាកម្មក្រុង ស្រុក


២.១. ការពិនិត្យគម្រោងវិនិយោគក្រុង ស្រុក .......................................................................... ១១
២.២. ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង ....................................................................... ១២
២.៣. ការកំណត់តម្រូវការជំនួយបច្ចេកទេស ........................................................................... ១៩


## ជំពូកទី៣

## ការសិក្សាគម្រោងសេវាកម្មក្រុង ស្រុក


៣.១. ការរៀបចំផែនការសិក្សាគម្រោង ................................................................................... ២០
៣.២. ការវិភាគផលប៉ះពាល់បរិស្ថាន ..................................................................................... ២៤


## ជំពូកទី៤

## ការរៀបចំគ្រោងការគម្រោងសេវាកម្មក្រុង ស្រុក


៤.១. ការសិក្សា និងប្រមូលព័ត៌មានគម្រោង ............................................................................ ៣៨
៤.២. ការប៉ាន់ស្មានតម្លៃគម្រោង ........................................................................................... ៤៣
៤.៣. ផែនការប្រតិបត្តិ និងថែទាំ ......................................................................................... ៥២
៤.៤. ស្លាកសញ្ញាគម្រោង ..................................................................................................... ៥២
៤.៥. ការរៀបចំបញ្ចប់សេចក្តីព្រាងគ្រោងការគម្រោង .............................................................. ៥៤

## ជំពូកទី៥

## ការបញ្ចប់គ្រោងការគម្រោងសេវាកម្មក្រុង ស្រុក

៥.១. ការពិនិត្យ និងអនុម័តគ្រោងការគម្រោង ..... ៥៥
៥.២. ការពិនិត្យព័ត៌មានគម្រោងដោយទីចាត់ការផែនការ និងវិនិយោគខេត្ត ..... ៥៥
៥.៣. ការពិនិត្យបញ្ជាក់បច្ចេកទេស ..... ៥៦

## ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១.** ឯកសារជំនួយស្មារតីអំពីកម្រិតអប្បបរមានៃលក្ខណៈបច្ចេកទេសគម្រោងសេវាកម្ម សម្រាប់ជាមូលដ្ឋានក្នុងការគណនាតម្លៃប៉ាន់ស្មាន ..... ៥៩
**ឧបសម្ព័ន្ធទី២.** បញ្ជីលេខកូដលទ្ធផលគម្រោងសេវាកម្មក្រុង ស្រុក ..... ៦៤

# ជំពូកទី១

# និន្នាការទូទៅនៃការរៀបចំ

# គម្រោងសេវាកម្មក្រុង ស្រុក

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃការរៀបចំគម្រោងសេវាកម្មក្រុង ស្រុក

## ១.១. សេចក្តីផ្តើម

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាក្រុង ស្រុកត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុករបស់ខ្លួន។ ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុងស្រុក គឺដើម្បីបំលែងខ្លឹមសារនៃផែនការអភិវឌ្ឍក្រុង ស្រុកឱ្យទៅជាគម្រោងសកម្មភាព ឬសេវាជាក់ស្តែងសំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍនៅក្នុងក្រុង ស្រុកសម្រាប់រយៈពេលបីឆ្នាំត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

ការរៀបចំ និងអនុម័តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺជាដំណាក់កាលចាប់ផ្តើមនៃការគិតពិចារណានិងរៀបចំផែនការសម្រាប់ការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗប៉ុណ្ណោះ។ ដើម្បីធានាឱ្យផែនការទាំងនេះ ត្រូវបានអនុវត្តជាក់ស្តែងក្នុងការឆ្លើយតបទៅនឹងតម្រូវការអាទិភាពនានារបស់ប្រជាពលរដ្ឋយ៉ាងពិតប្រាកដ រដ្ឋបាលក្រុង ស្រុកនីមួយៗត្រូវរៀបចំ និងអនុវត្តគម្រោងនានានៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងការធានាឱ្យរដ្ឋបាលក្រុង ស្រុកអាចរៀបចំគម្រោងវិនិយោគនានាដែលបានបញ្ចូលក្នុងកម្មវិធីវិនិយោគ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានរៀបចំ និងដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុក តាមសេចក្តីសម្រេចលេខ ០៥៣ សសរ/គ.ជ.អ.ប ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣។ សៀវភៅណែនាំដែលបានដាក់ឱ្យប្រើប្រាស់នេះ បានធ្វើការណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំគម្រោងវិនិយោគក្រុង ស្រុកដោយផ្តោតជាចម្បងលើការរៀបចំគម្រោងដែលមានលក្ខណៈជាគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបានបរិយាយខ្លះៗអំពីការរៀបចំគម្រោងវិនិយោគក្រុង ស្រុកដែលមានលក្ខណៈជាគម្រោងសេវាកម្ម (គម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្ត)។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការណែនាំនោះមិនទាន់គ្រប់គ្រាន់នៅឡើយសម្រាប់ឱ្យរដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំគម្រោងសេវាកម្មបានពេញលេញ។ ដោយយល់ឃើញនូវសារៈសំខាន់នៃការលើកកម្ពស់ការវិនិយោគផ្នែកសេវាកម្មក្នុងការអភិវឌ្ឍក្រុង ស្រុក គ.ជ.អ.ប ចាំបាច់ត្រូវរៀបចំ និងណែនាំបន្ថែមទៀតអំពីការរៀបចំគម្រោងវិនិយោគក្រុង ស្រុកដែលមានលក្ខណៈជាគម្រោងសេវាកម្ម ឬគម្រោងសេវាសង្គម ឬគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្តនេះឡើង។

## ១.២. គោលបំណង

ការរៀបចំសៀវភៅណែនាំស្តីពីការរៀបចំគម្រោងសេវាកម្មរបស់ក្រុង ស្រុក ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្តល់ការណែនាំដល់រដ្ឋបាលក្រុង ស្រុកអំពី ៖

- ទស្សនទានក្នុងការរៀបចំគម្រោងសេវាកម្មក្រុង ស្រុក
- ដំណើរការ និងនីតិវិធីនៃការរៀបចំគម្រោងសេវាកម្មរបស់រដ្ឋបាលក្រុង ស្រុក

សៀវភៅណែនាំអំពីការរៀបចំគម្រោងសេវាកម្មនេះ នឹងត្រូវបានប្រើប្រាស់ជាឯកសារជំនួយស្មារតីដល់រដ្ឋបាលក្រុង ស្រុកក្នុងការសិក្សា និងការរៀបចំគម្រោងសេវាកម្មនានាដែលប្រើប្រាស់ថវិកាក្រុង ស្រុក។

## ១.៣. និយមន័យ

### ១.៣.១. និយមន័យគម្រោង

គម្រោង គឺជាសំណុំនៃលទ្ធផល(ឬសកម្មភាព)ដែលរួមគ្នាដើម្បីសម្រេចទិសដៅមួយក្នុងក្របខ័ណ្ឌពេលវេលាមួយ និងថវិកាជាក់លាក់។ គម្រោងមួយត្រូវមាន ឈ្មោះ ប្រភេទ រយៈពេល ថវិកា ទីតាំង សកម្មភាពលទ្ធផល និងអ្នកទទួលផល។

លទ្ធផលគម្រោងសំដៅលើសេវាកម្ម ទំនិញ និងហេដ្ឋារចនាសម្ព័ន្ធដែលបានបង្កើតឡើងតាមរយៈការអនុវត្តសកម្មភាពនានានៃគម្រោងដែលអាចរាប់ឬវាស់វែងបាន។

### ១.៣.២. និយមន័យគម្រោងសេវាកម្ម

គម្រោងសេវាកម្មគឺជាសកម្មភាពមួយឬសំណុំសកម្មភាពនានាដែលមានទំនាក់ទំនងនិងគាំទ្រគ្នាទៅវិញទៅមកដើម្បីបង្កើតជាលទ្ធផលគម្រោងមួយដែលមានលក្ខណៈជាហេដ្ឋារចនាសម្ព័ន្ធអរូបវ័ន្ត និងឬបង្កើតលទ្ធផលដែលមានលក្ខណៈជាហេដ្ឋារចនាសម្ព័ន្ធអរូបវ័ន្តផង និងរូបវ័ន្តផង។

ឧទាហរណ៍ ៖

- លទ្ធផលគម្រោងដែលមានលក្ខណៈជាហេដ្ឋារចនាសម្ព័ន្ធអរូបវ័ន្ត មានដូចជា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្សព្វផ្សាយ ការបង្កើនចំណេះដឹង (ផ្នែកការអប់រំសុខភាពទឹកស្អាត អនាម័យ អគ្រានុកូលដ្ឋាន គ្រោះធម្មជាតិ...) ការអភិវឌ្ឍធនធានមនុស្ស សកម្មភាពបង្កើនប្រាក់ចំណូល ការផ្តល់សម្ភារៈ បរិក្ខារ ទំនិញ ការផ្តល់ពូជ និងឬការរៀបចំសហគមន៍ជាដើម។
- លទ្ធផលគម្រោងដែលមានលក្ខណៈជាហេដ្ឋារចនាសម្ព័ន្ធអរូបវ័ន្តផង និងរូបវ័ន្តផង មានដូចជាគម្រោងកសិកម្មចម្រុះ។ លទ្ធផលគម្រោងប្រភេទនេះអាចមានដូចជា ៖
  - ការរៀបចំក្រុមនិងលក្ខន្តិកៈក្រុម
  - ការបណ្តុះបណ្តាល
  - ការជីកស្រះសម្រាប់ចិញ្ចឹមត្រី
  - ការធ្វើរោងជីកំប៉ុស
  - ការធ្វើទ្រុងចិញ្ចឹមសត្វ
  - ការផ្តល់គ្រាប់ពូជកូនត្រីពូជសត្វនិងសម្ភារៈសម្រាប់ការសាងសង់នានា
  - ការចុះតាមដាននិងជួយកសិករគោលដៅក្នុងការអនុវត្តជាក់ស្តែង។
- គម្រោងគាំទ្រវារីវប្បកម្មលក្ខណៈគ្រួសារលទ្ធផលគម្រោងប្រភេទនេះមានដូចជា៖
  - ការបណ្តុះបណ្តាលអំពីបច្ចេកទេសវារីវប្បកម្ម
  - ការជីកស្រះ
  - ការផ្តល់កូនត្រី។ល។

គម្រោងសេវាកម្មមួយចំនួនអាចរួមបញ្ចូលគ្នានូវសកម្មភាព ឬលទ្ធផលនានាដែលមិនស្ថិតនៅក្នុងប្រភេទគម្រោងតែមួយ។ គម្រោងសេវាកម្មប្រភេទនេះអាចរួមបញ្ចូលគ្នានូវសេវាកម្មសម្ភារៈទំនិញ និងឬការងារសាងសង់ តូចតាចដើម្បីសម្រេចបាននូវទិសដៅរួមរបស់គម្រោង។

## ១.៤. ប្រភេទផ្សេងៗនៃគម្រោងសេវាកម្មក្រុង ស្រុក

រដ្ឋបាលក្រុង ស្រុកអាចរៀបចំគម្រោងសេវាកម្មនានាដែលបានកំណត់តាមផ្នែកនីមួយៗរួមមាន ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយការប្រែប្រួលអាកាសធាតុ ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ។

ខាងក្រោមនឹងបង្ហាញជាឧទាហរណ៍មួយចំនួនពាក់ព័ន្ធនឹងគម្រោងសេវាកម្ម។

**ឧទាហរណ៍ ៖**

- **ផ្នែកសេដ្ឋកិច្ច** អាចមានដូចជា៖
  - គម្រោងរៀបចំសហគមន៍ប្រើប្រាស់ទឹក
  - គម្រោងរៀបចំសមាគមអាជីវករធ្វើស្រែអំបិល
  - គម្រោងបង្កើតក្រុមជួយខ្លួនឯង
  - គម្រោងបង្កើនប្រាក់ចំណូលតាមរយៈការបង្កើតមុខរបរខ្នាតតូច
  - គម្រោងបង្កើនការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ
  - គម្រោងបង្កើនការដាំដុះដំណាំកសិឧស្សាហកម្ម
  - គម្រោងបង្កើនប្រាក់ចំណូលរបស់ស្ត្រី
  - គម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី
  - គម្រោងបណ្តុះបណ្តាលជំនាញចម្លាក់ និងស្មូនរូប។ល។
- **ផ្នែកសង្គមកិច្ច** អាចមានគម្រោងដូចជា ៖
  - គម្រោងផ្សព្វផ្សាយអំពីកិច្ចការពារជំងឺផ្តាសាយបក្សី
  - គម្រោងផ្តល់អាហារូបករណ៍ដល់សិស្សស្រីនៅកម្រិតអនុវិទ្យាល័យ
  - គម្រោងបណ្តុះបណ្តាលអ្នកទ្រទ្រង់សុខភាពភូមិ
  - គម្រោងផ្សព្វផ្សាយអំពីជំងឺកាមរោគ មេរោគអេដស៍ ជំងឺអេដស៍ និងវិធានការការពារ
  - គម្រោងចាក់ថ្នាំបង្ការជំងឺ៨មុខដល់កុមារ
  - គម្រោងកាត់បន្ថយអត្រាមរណៈភាពរបស់មាតា និងទារក
  - គម្រោងពង្រឹងបណ្តាញស្ត្រី
  - គម្រោងពង្រឹងពង្រីកសិល្បៈ វប្បធម៌ជនជាតិដើមភាគតិច
  - គម្រោងស្តារលទ្ធភាពពលកម្មជនពិការ
  - គម្រោងលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ
  - គម្រោងការពារ និងទប់ស្កាត់អំពើរំលោភបំពានផ្លូវភេទ និងជួញដូរមនុស្ស
  - គម្រោងផ្សព្វផ្សាយ លើកកម្ពស់អាហាររូបត្ថម្ភ
  - ការផ្សព្វផ្សាយអំពីអាហាររូបត្ថម្ភ និងសុខភាពមាតា និងទារក
  - គម្រោងផ្សព្វផ្សាយអប់រំអំពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទដល់យុវជន
  - គម្រោងលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារី
  - គម្រោងពង្រឹងបណ្តាញស្ត្រីវ័យក្មេងដើម្បីចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍នានា
  - គម្រោងលើកកម្ពស់យុវជនចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍នានា
  - គម្រោងលើកកម្ពស់សុវត្ថិភាពចរាចរណ៍
  - គម្រោងផ្តល់សេវាប្រឹក្សាយោបល់ផ្លូវចិត្ត

– គម្រោងផ្តល់សេវាគាំពារចាស់ជរា
– គម្រោងផ្តល់សេវាគាំពារជនពិការ
– គម្រោងទប់ស្កាត់ការចំណាកស្រុកដោយខុសច្បាប់
– គម្រោងសហគមន៍ផលិតទឹកបរិសុទ្ធ
– គម្រោងរៀបចំ និងដំណើរការមតេយ្យសហគមន៍
– គម្រោងបញ្ជូនស្ត្រីក្នុងគ្រួសារក្រីក្រទៅទទួលសេវាពន្យារកំណើតនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក
– គម្រោងគាំទ្រ និងឧបត្ថម្ភការប្រើប្រាស់សេវាសុខភាពសាធារណៈដល់ស្ត្រីក្រីក្រ ដូចជា មធ្យោបាយធ្វើដំណើរ និងតម្លៃសេវាមណ្ឌលសុខភាព
– គម្រោងអប់រំផ្សព្វផ្សាយដល់យុវជនឱ្យចូលរួមសកម្មភាពធ្វើអនាម័យ និងការការពារបរិស្ថានក្នុងសហគមន៍ ។ល។

- **ផ្នែកការប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** អាចមានគម្រោងដូចជា ៖

– គម្រោងរៀបចំវេទិកាផ្សព្វផ្សាយការបំពុលបរិស្ថាន
– គម្រោងបង្កើតថ្នាលបណ្តុះកូនឈើ និងដាំកូនឈើ
– គម្រោងការពារព្រៃលិចទឹក
– គម្រោងទប់ស្កាត់បទល្មើសនេសាទ
– គម្រោងផ្សព្វផ្សាយច្បាប់ភូមិបាល
– គម្រោងរៀបចំសហគមន៍ព្រៃឈើ
– គម្រោងរៀបចំសហគមន៍នេសាទ
– គម្រោងផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់
– គម្រោងការរៀបចំវិធានការទប់ទល់គ្រោះធម្មជាតិ
– គម្រោងផ្តល់ជំនួយសុខាភិបាលដល់ជនរងគ្រោះដោយសារគ្រោះធម្មជាតិ
– គម្រោងទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារដែលរងគ្រោះដោយសារគ្រោះធម្មជាតិ
– គម្រោងការឆ្លើយតបនឹងគ្រោះមហន្តរាយ និងការបន្សាំ(ទឹកជំនន់ ខ្យល់ព្យុះ រាំងស្ងួត...)។ល។

- **ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**អាចមានគម្រោងដូចជា ៖

– គម្រោងគ្រប់គ្រងទិន្នន័យជនអន្តោប្រវេសន៍
– គម្រោងពង្រឹងកម្មវិធីប្រជាការពារ
– គម្រោងអប់រំផ្សព្វផ្សាយអំពីគ្រឿងញៀន
– គម្រោងទប់ស្កាត់ និងលុបបំបាត់ក្រុមក្មេងទំនើង
– គម្រោងទប់ស្កាត់ចោរកម្ម
– គម្រោងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ
– គម្រោងទប់ស្កាត់ការរំលោភបំពានផ្លូវភេទ និងការជួញដូរមនុស្ស
– គម្រោងត្រួតពិនិត្យទំនិញហួសកាលបរិច្ឆេទប្រើប្រាស់
– គម្រោងពង្រឹងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព
– គម្រោងរៀបចំសណ្តាប់ធ្នាប់ចំណតយានយន្ត។ល។

### ១.៥. តួនាទីអ្នកពាក់ព័ន្ធនានាក្នុងការរៀបចំគម្រោងសេវាកម្ម

#### ១.៥.១. ក្រុមប្រឹក្សាក្រុង ស្រុក

នៅក្នុងការរៀបចំគម្រោងសេវាកម្មក្រុមប្រឹក្សាក្រុង ស្រុកទទួលខុសត្រូវក្នុងការ ៖

- ពិនិត្យ និងអនុម័តសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្ម
- តាមដានដំណើរការនៃការរៀបចំគម្រោងសេវាកម្ម
- បង្កើតយន្តការដើម្បីធានាការចូលរួមពីសហគមន៍ឱ្យបានគ្រប់ជ្រុងជ្រោយជាពិសេសការចូលរួមរបស់ក្រុម ឬបណ្តាញស្ត្រីយុវជន ជនពិការ និងជនងាយរងគ្រោះជាដើមនៅក្នុងដំណើរការរៀបចំនិងអនុវត្តគម្រោងសេវាកម្ម
- កំណត់អំពីចំនួនទុនចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់គម្រោងសេវាកម្មក្រុង ស្រុក។

#### ១.៥.២. គណៈអភិបាលក្រុង ស្រុក

គណៈអភិបាលក្រុង ស្រុកទទួលខុសត្រូវក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង ឬសកម្មភាពសេវាកម្មនានាដែលមាននៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុកនិងគម្រោងថវិកាក្រុង ស្រុក។ នៅក្នុងដំណាក់កាលនៃការរៀបចំគម្រោងគណៈអភិបាលក្រុង ស្រុកទទួលខុសត្រូវក្នុងការ៖

- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- គ្រប់គ្រងការសិក្សាគម្រោងសេវាកម្ម និងសម្របសម្រួលការងារជាមួយអ្នកពាក់ព័ន្ធនានា
- កំណត់ និងតែងតាំងអ្នកជំនួយបច្ចេកទេសសម្រាប់ជួយក្នុងការសិក្សា និងរៀបចំគម្រោង
- ចុះហត្ថលេខាលើព័ត៌មានគម្រោងនិងឯកសារពាក់ព័ន្ធ
- ផ្ញើទម្រង់ព័ត៌មានគម្រោងនិងឯកសារពាក់ព័ន្ធទាំងអស់ទៅទីចាត់ការផែនការ និងវិនិយោគខេត្ត ដើម្បីពិនិត្យ និងចាត់ចែងសម្រាប់ការពិនិត្យបញ្ជាក់បច្ចេកទេស។

#### ១.៥.៣. គណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្ម

នៅក្នុងដំណាក់កាលរៀបចំគម្រោងគណៈកម្មការគ្រប់គ្រងគម្រោងមានតួនាទីដូចខាងក្រោម ៖

- គ្រប់គ្រងចាត់ចែងធ្វើការសិក្សា និងរៀបចំគម្រោង
- រៀបចំឯកសារគម្រោងដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យ និងអនុម័តឯកសារគម្រោង។

នៅក្នុងដំណាក់កាលរៀបចំគម្រោងអន្តររដ្ឋបាល គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលមានតួនាទីដូចខាងក្រោម ៖

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោងអន្តររដ្ឋបាល
- គ្រប់គ្រងចាត់ចែងការសិក្សា និងរៀបចំគម្រោងអន្តររដ្ឋបាល
- កំណត់អ្នកជំនួយបច្ចេកទេសសម្រាប់ជួយក្នុងការសិក្សា និងរៀបចំគម្រោងអន្តររដ្ឋបាល
- រៀបចំឯកសារគម្រោងដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស

#### ១.៥.៤. អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងថែទាំ

ចំពោះគម្រោងទាំងឡាយណាដែលចាំបាច់ត្រូវមានកិច្ចប្រតិបត្តិការនិងការថែទាំគម្រោងនោះនឹងពុំមាននិរន្តរភាពទេប្រសិនបើពុំបានរៀបចំឱ្យមានការទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងថែទាំឱ្យបានច្បាស់លាស់។

**ក). រដ្ឋបាលក្រុង ស្រុក**

ចំពោះប្រភេទគម្រោងមួយចំនួនរដ្ឋបាលក្រុង ស្រុកនឹងទទួលខុសត្រូវផ្ទាល់ក្នុងការប្រតិបត្តិការ និងថែទាំលទ្ធផលគម្រោងហើយការចំណាយសម្រាប់កិច្ចប្រតិបត្តិការនិងការថែទាំនេះត្រូវគ្រោងនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក។ ជាទូទៅគម្រោងទាំងនោះគឺជា ៖

- គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ទាំងមូល ឬដល់ក្រុមប្រជាជនជាក់លាក់ ដូចជាស្ត្រី កុមារ យុវជន ជនមានពិការភាព ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងៗទៀតជាដើម
- គម្រោងសេវាកម្ម ដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ទាំងមូលឬដល់ក្រុមប្រជាជនជាក់លាក់ ដូចជាស្ត្រី កុមារ យុវជន ជនមានពិការភាព ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងៗទៀតជាដើម
- គម្រោងដែលមិនមានភ្នាក់ងាររបស់រាជរដ្ឋាភិបាលណាមួយទទួលខុសត្រូវ។

**ខ). ទីភ្នាក់ងាររបស់រាជរដ្ឋាភិបាល**

ចំពោះប្រភេទគម្រោងមួយចំនួនទៀតទីភ្នាក់ងារផ្សេងទៀតរបស់រាជរដ្ឋាភិបាលជាអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការនិងថែទាំ។ ឧទាហរណ៍មន្ទីរសុខាភិបាលទទួលខុសត្រូវក្នុងការប្រតិបត្តិការនិងថែទាំមណ្ឌលសុខភាពមន្ទីរអប់រំយុវជន និងកីឡាទទួលខុសត្រូវក្នុងដំណើរការប្រតិបត្តិការនិងថែទាំសាលារៀន។ ក្នុងករណីដែលរដ្ឋបាលក្រុង ស្រុកទទួលខុសត្រូវត្រឹមតែការសាងសង់ (ដូចជាមណ្ឌលសុខភាពឬសាលារៀន) នោះក្រុង ស្រុកត្រូវស្វែងរកការព្រមព្រៀងជាមួយទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលឱ្យបានច្បាស់លាស់អំពីការទទួលខុសត្រូវលើការចំណាយសម្រាប់ដំណើរការប្រតិបត្តិការនិងថែទាំ។

**គ). ក្រុមអ្នកប្រើប្រាស់**

ចំពោះប្រភេទគម្រោងមួយចំនួនទៀត ដែលមានក្រុមអ្នកប្រើប្រាស់ជាអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងថែទាំ ឧទាហរណ៍ ៖ សហគមន៍ប្រើប្រាស់ទឹក(គម្រោងប្រព័ន្ធធារាសាស្ត្រ) ក្រុមអ្នកប្រើប្រាស់ទឹកនិងអនាម័យ(គម្រោងអណ្តូងទឹក) រដ្ឋបាលក្រុង ស្រុក ឬគណៈកម្មការគ្រប់គ្រងគម្រោងត្រូវរៀបចំបង្កើតក្រុមអ្នកប្រើប្រាស់នៅដំណាក់កាលចាប់ផ្តើមពីពេលរៀបចំគម្រោង ឬមុនពេលផ្ញើព័ត៌មានគម្រោងទៅទីចាត់ការផែនការ និងវិនិយោគខេត្ត។

នៅក្នុងការរៀបចំគម្រោងក្រុមអ្នកប្រើប្រាស់អាចជួយបំពេញភារកិច្ចដូចជា៖

- ការប្រមូលព័ត៌មានដែលត្រូវការសម្រាប់គ្រោងការគម្រោង
- ការជ្រើសរើសទីតាំងនៃលទ្ធផលគម្រោង (ឧទាហរណ៍: សាលាមត្តេយ្យសិក្សាសហគមន៍)
- ការប្រមូលទុនចូលរួម។

**១.៥.៥. សហគមន៍និងអ្នកទទួលផលពីគម្រោង**

**សហគមន៍**មានន័យថាជាប្រជាពលរដ្ឋមួយក្រុម ដែលរស់នៅជាមួយគ្នានៅកន្លែងមួយមានការពាក់ព័ន្ធគ្នាទៅវិញទៅមក និងមានផលប្រយោជន៍រួមគ្នា។

**អ្នកទទួលផលផ្ទាល់ពីគម្រោង**គឺជាប្រជាពលរដ្ឋឬក្រុមគ្រួសារ រួមទាំងស្ត្រី យុវជន កុមារ ជនមានពិការភាព និងជនងាយរងគ្រោះ ដែលប្រើប្រាស់លទ្ធផលគម្រោងផ្ទាល់។

**ឧទាហរណ៍ ៖**

- អ្នកទទួលផលផ្ទាល់ពីការបណ្តុះបណ្តាលគឺអ្នកទាំងឡាយណាដែលបានចូលរៀនវគ្គបណ្តុះបណ្តាលនោះ (ចំនួនសិក្ខាកាមទាំងពីរភេទ)
- អ្នកទទួលផលផ្ទាល់ពីគម្រោងចាក់ថ្នាំបង្ការជំងឺ៨មុខ គឺកុមារដែលបានទទួលថ្នាំបង្ការ
- អ្នកទទួលផលផ្ទាល់ពីគម្រោងលើកកម្ពស់សុខភាពបន្តពូជ គឺប្រជាពលរដ្ឋដែលទទួលសេវាពន្យារកំណើតបែបទំនើបណាមួយ។
- អ្នកទទួលផលផ្ទាល់ពីគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺសិក្ខាកាមដែលទទួលបានការបណ្តុះបណ្តាល
- អ្នកទទួលផលផ្ទាល់ពីគម្រោងសាលាមត្តេយ្យសិក្សាសហគមន៍ គឺកុមារដែលបានចូលរៀន
- អ្នកទទួលផលផ្ទាល់ពីការផ្តល់សេវាអត្រានុកូលដ្ឋាន គឺកុមារ ឬប្រជាពលរដ្ឋបានទទួលសំបុត្រអត្រានុកូលដ្ឋាន

អ្នកទទួលផលផ្ទាល់និងសហគមន៍ត្រូវចូលរួមឱ្យបានច្រើនក្នុងការជ្រើសរើសគ្រោងការគម្រោងនិងការតាមដានការអនុវត្តគម្រោង។

### ១.៥.៦. អ្នកជំនួយបច្ចេកទេសផ្នែកសេវាកម្ម

អ្នកជំនួយបច្ចេកទេស សំដៅលើអ្នកបច្ចេកទេសដែលក្រុង ស្រុកស្នើសុំ ឬជួល ឬដែលផ្តល់ឱ្យដោយរដ្ឋបាលខេត្ត ដើម្បីជួយផ្តល់ជំនួយផ្នែកបច្ចេកទេសក្នុងការរៀបចំ និងអនុវត្តគម្រោងសេវាកម្មក្រុង ស្រុក។

អ្នកជំនួយបច្ចេកទេសមានភារកិច្ចដូចខាងក្រោម ៖

- ពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថានរបស់គម្រោង
- រៀបចំផែនការសិក្សាគម្រោង
- រៀបចំផែនទីគម្រោង
- អនុវត្តការសិក្សាលទ្ធភាពគម្រោង
- ជួយក្រុង ស្រុកក្នុងការសិក្សាផលប៉ះពាល់បរិស្ថាន
- រៀបចំគ្រោងការគម្រោង
- ប៉ាន់ស្មានតម្លៃគម្រោង
- បំពេញព័ត៌មានផ្នែកបច្ចេកទេសទៅក្នុងទម្រង់ព័ត៌មានគម្រោង
- ចុះហត្ថលេខាលើទម្រង់ព័ត៌មានគម្រោងដើម្បីបញ្ជាក់ថាគំនូសប្លង់គម្រោង និងព័ត៌មាននានានៅក្នុងឯកសារគម្រោងនេះពិតជាត្រឹមត្រូវ
- ជួយបញ្ចូលព័ត៌មានគម្រោងទៅក្នុងប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងក្រុង ស្រុក។

### ១.៥.៧. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃសាលាក្រុង ស្រុក

ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃសាលាក្រុង ស្រុកមានតួនាទីដូចខាងក្រោម ៖

- ជួយគណៈកម្មការគ្រប់គ្រងគម្រោងក្នុងការសិក្សា ការប្រមូលព័ត៌មាន និងការរៀបចំគម្រោងក្រុង ស្រុក ពិសេសការសិក្សាផលប៉ះពាល់បរិស្ថាន
- ធានាថាការបញ្ចូលព័ត៌មានគម្រោងទៅក្នុងប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងក្រុង ស្រុកត្រូវបានអនុវត្តទៅតាមសេចក្តីណែនាំស្តីពីការបញ្ចូលព័ត៌មានទិន្នន័យគម្រោងទៅក្នុងប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងក្រុង ស្រុករបស់គ.ជ.អ.ប។

### ១.៥.៨. ទីចាត់ការផែនការ និងវិនិយោគខេត្ត

ទីចាត់ការផែនការ និងវិនិយោគខេត្តមានតួនាទីដូចខាងក្រោម ៖

- សម្របសម្រួល និងគាំទ្រក្រុង ស្រុកក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងគម្រោងនានាតាមការស្នើសុំ
- គាំទ្រក្រុង ស្រុកក្នុងការសិក្សាគម្រោង ការរៀបចំប្លង់ ការប៉ាន់ស្មានតម្លៃ និងការរៀបចំសំណើគម្រោង
- ពិនិត្យរបាយការណ៍អនុវត្តផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាក្រុង ស្រុក
- ចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យពាក់ព័ន្ធនឹងគម្រោងក្រុង ស្រុក
- រៀបចំបញ្ជីតម្លៃសម្ភារៈស្តង់ដារ ឬតម្លៃសេវាសម្រាប់ជាមូលដ្ឋានក្នុងការគណនាតម្លៃប៉ាន់ស្មានគម្រោង
- ពិនិត្យទៅលើភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃរបាយការណ៍សិក្សាផលប៉ះពាល់បរិស្ថាន
- ពិនិត្យទៅលើភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃព័ត៌មាននានានៅក្នុងទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធ
- សម្របសម្រួលជាមួយមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធក្នុងការពិនិត្យបញ្ជាក់បច្ចេកទេសគម្រោង
- ជូនដំណឹងដល់ក្រុង ស្រុកអំពីគម្រោងដែលទទួលនូវការពិនិត្យបញ្ជាក់បច្ចេកទេសដើម្បីឱ្យក្រុង ស្រុកចាប់ផ្តើមដំណើរការលទ្ធកម្ម
- អភិវឌ្ឍសមត្ថភាពក្រុង ស្រុកក្នុងការរៀបចំអនុវត្ត និងតាមដានការអនុវត្តគម្រោង។

ក្នុងការពិនិត្យទៅលើភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃព័ត៌មាននានានៅក្នុងទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវពិនិត្យ៖

- តើព័ត៌មានចាំបាច់នានានៃគម្រោងនេះមានគ្រប់គ្រាន់ហើយឬនៅ?
- តើគម្រោងនេះស្របទៅតាមផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុកដែរឬទេ?
- តើគម្រោងនេះមានលក្ខណៈសមស្របទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងការប្រើប្រាស់មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ ឬប្រភពថវិកាផ្សេងទៀតដែលគាំទ្រគម្រោងនេះដែរឬទេ?
- តើគម្រោងនេះមានផ្ទុយទៅនឹងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តណាមួយដែរឬទេ?

បន្ទាប់ពីពិនិត្យរួចរាល់ហើយទីចាត់ការផែនការ និងវិនិយោគត្រូវផ្ញើទម្រង់ព័ត៌មានគម្រោងនិងឯកសារពាក់ព័ន្ធមួយច្បាប់ទៅមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។

ចំពោះគម្រោងមួយចំនួនដែលអាចបណ្តាលឱ្យប៉ះពាល់បរិស្ថានទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវធានាថា ការសិក្សាផលប៉ះពាល់បរិស្ថានត្រូវបានរៀបចំ។

### ១.៥.៩. មន្ទីរ អង្គភាពជំនាញនានា

#### ក). ជួយក្នុងការរៀបចំគម្រោង

ចំពោះគម្រោងមួយចំនួនបណ្តាមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធត្រូវចូលរួមជាជំនួយបច្ចេកទេសក្នុងការរៀបចំគម្រោង។ ជំនួយបច្ចេកទេសដែលមន្ទីរ អង្គភាពជំនាញគួរណែនាំរួមមាន ៖

- ការណែនាំបច្ចេកទេសលើគ្រោងការគម្រោងតាមការស្នើសុំ។ ក្នុងករណីដែលអ្នកជំនួយបច្ចេកទេសមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់ការរៀបចំគម្រោង រដ្ឋបាលក្រុង ស្រុកត្រូវស្នើទៅបណ្តាមន្ទីរអង្គភាពជំនាញពាក់ព័ន្ធដើម្បីជួយក្នុងការរៀបចំគម្រោងទាំងនោះ។

**ឧទាហរណ៍ ៖**

- ការរៀបចំគម្រោងសហគមន៍ព្រៃឈើ ត្រូវការជំនាញបច្ចេកទេសពីខណ្ឌរដ្ឋបាលព្រៃឈើ ដូចនេះ រដ្ឋបាលក្រុង ស្រុកត្រូវស្នើទៅខណ្ឌរដ្ឋបាលព្រៃឈើ ឱ្យជួយផ្នែកបច្ចេកទេស។
- មន្ទីរបរិស្ថានខេត្តជួយផ្តល់បច្ចេកទេសដល់រដ្ឋបាលក្រុងក្នុងការរៀបចំគម្រោងគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងទីប្រជុំជនក្រុង។

- កិច្ចព្រមព្រៀងស្តីពីការចាត់ចែងសម្រាប់ការប្រតិបត្តិការ និងថែទាំលទ្ធផលគម្រោងជាពិសេសចំពោះគម្រោងដែលមន្ទីរ អង្គភាពជំនាញទទួលខុសត្រូវក្នុងការចំណាយសម្រាប់ប្រតិបត្តិការ។ ឧទាហរណ៍ រដ្ឋបាលក្រុង ស្រុកមិនអាចអនុវត្តគម្រោងផ្សព្វផ្សាយអំពីការចាក់ថ្នាំបង្ការជំងឺ៨មុខ ឱ្យកុមារបានឡើយ ប្រសិនបើមន្ទីរសុខាភិបាលមិនយល់ព្រមអនុវត្តការចាក់ថ្នាំបង្ការដល់កុមារ។

**ខ). ការពិនិត្យបញ្ជាក់បច្ចេកទេស**

មន្ទីរ អង្គភាពជំនាញនានាមានភារកិច្ចក្នុងការពិនិត្យបញ្ជាក់បច្ចេកទេសនូវគ្រប់គម្រោងសេវាកម្មក្រុង ស្រុកទាំងអស់ដែលពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន។ គម្រោងមួយអាចតម្រូវឱ្យមានការពិនិត្យបញ្ជាក់បច្ចេកទេសពីមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធមួយឬច្រើន។

**១.៥.១០.ក្រុមការងារសុវត្ថិភាពបរិស្ថានដីធ្លីនិងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋានគ.ជ.អ.ប**

ក្រុមការងារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋានគ.ជ.អ.បគឺជាយន្តការមួយដែលបង្កើតឡើងដើម្បីត្រួតពិនិត្យនិងផ្តល់យោបល់ទៅលើ៖

- ដំណើរការនៃការសិក្សាផលប៉ះពាល់បរិស្ថាន
- របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន។

ក្រុមការងារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន (ឃុំ សង្កាត់ដែលស្ថិតនៅក្នុងតំបន់ដែលមានផលប៉ះពាល់ខ្លាំងដល់បរិស្ថាន) ហើយដាក់ជូនគ.ជ.អ.ប ដើម្បីពិនិត្យសម្រេច។ គ.ជ.អ.ប នឹងផ្តល់បញ្ជីនេះដល់ខេត្តដែលពាក់ព័ន្ធ និងផ្សព្វផ្សាយបញ្ជីនេះនៅក្នុងគេហទំព័ររបស់គ.ជ.អ.ប។ បន្ទាប់ពីទទួលបានបញ្ជីទាំងពីរនេះ ខេត្តត្រូវផ្តល់បញ្ជីនេះដល់ក្រុង ស្រុកដែលពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធនានា។

ក្រុមការងារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋានគ.ជ.អ.ប ត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាននេះនៅរៀងរាល់បីឆ្នាំម្តង។

បញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថានត្រូវធ្វើបច្ចុប្បន្នភាពដោយផ្អែកតាមចំណុចដូចខាងក្រោម ៖

- ទំហំសណ្ឋានដីទាំងអស់ឬពាក់កណ្តាលរបស់ឃុំសង្កាត់ដែលគ្របដណ្តប់ដោយព្រៃធម្មជាតិ
- ទំហំសណ្ឋានដីរបស់ឃុំសង្កាត់គ្របដណ្តប់ដោយតំបន់ដីសើម ឬព្រៃដែលមានទំហំចាប់ពី១0% ឡើងទៅនៃទំហំផ្ទៃដីសរុបរបស់ឃុំសង្កាត់
- ការកំណត់ដោយថ្នាក់ខេត្តឬថ្នាក់ជាតិនូវតំបន់ការពារតំបន់ព្រៃការពារតំបន់រក្សាពូជត្រីទឹកសាបទឹកប្រៃនិងតំបន់អភិរក្សបុរាណសាស្ត្រជាដើម
- តំបន់ជីវៈចម្រុះផ្សេងៗ ដែលត្រូវបានចាត់ទុកជាតំបន់ដែលគាំទ្រប្រភេទពូជសត្វព្រៃដែលបាត់បង់ ហើយដែលត្រូវបានប្រកាសដោយក្រសួងបរិស្ថាន
- តំបន់ដែលការអនុវត្តគម្រោងកន្លងមកបណ្តាលឱ្យមានផលប៉ះពាល់បរិស្ថានធំ
- ភូមិដែលមានជនជាតិដើមភាគតិចរស់នៅលើសពី៥%នៃចំនួនប្រជាជនសរុបក្នុងភូមិ។

ចំពោះគម្រោងក្រុង ស្រុកដែលមានទីតាំងស្ថិតនៅក្នុងឃុំសង្កាត់នៃបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថានក្រុមការងារសុវត្ថិភាពបរិស្ថានដីធ្លីនិងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋានគ.ជ.អ.បនឹង ៖

- ពិនិត្យឡើងវិញទៅលើការពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន នៃគម្រោងទាំងនេះដើម្បីបញ្ជាក់អំពីសក្តានុពលនៃផលប៉ះពាល់បរិស្ថាននៃគម្រោងទាំងអស់នោះ
- ចុះពិនិត្យដល់ទីតាំងគម្រោងផ្តល់ការណែនាំអំពីការវិភាគផលប៉ះពាល់បរិស្ថាន និងពិនិត្យរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាននិងឯកសារឧបសម្ព័ន្ធនានានៃគម្រោងដែលពិនិត្យទៅឃើញថាមានសក្តានុពលនៃផលប៉ះពាល់បរិស្ថានជាមុន មុននឹងគម្រោងទទួលបានការពិនិត្យបញ្ជាក់បច្ចេកទេស។

## ១.៦. សេចក្តីសង្ខេបអំពីដំណើរការរៀបចំគម្រោងសេវាកម្ម

**គំនូសបំព្រួញអំពី**
**ដំណើរការរៀបចំគម្រោងសេវាកម្ម**

**១. ការត្រៀមរៀបចំគម្រោងសេវាកម្ម**

- ការពិនិត្យគម្រោងក្នុងកម្មវិធីវិនិយោគ
- ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង
- កំណត់ជំនួយបច្ចេកទេស

**២. ការសិក្សាគម្រោងសេវាកម្ម**

- ការរៀបចំផែនការសិក្សាគម្រោង
- ការវិភាគផលប៉ះពាល់បរិស្ថាន

**៣. ការរៀបចំគ្រោងការគម្រោងសេវាកម្ម**

- ការសិក្សា និងប្រមូលព័ត៌មានគម្រោង
- ការប៉ាន់ស្មានតម្លៃគម្រោង
- ការរៀបចំផែនការប្រតិបត្តិ និងថែទាំ
- ស្លាកសញ្ញាគម្រោង
- ការរៀបចំបញ្ចប់សេចក្តីព្រាងគ្រោងការគម្រោង

**៤. ការបញ្ចប់គ្រោងការគម្រោងសេវាកម្ម**

- ការពិនិត្យ និងអនុម័តគ្រោងការគម្រោង
- ការពិនិត្យព័ត៌មានគម្រោង ដោយទីចាត់ការផែនការ និងវិនិយោគខេត្ត
- ការពិនិត្យបញ្ជាក់បច្ចេកទេស

# ជំពូកទី២
# ការត្រៀមរៀបចំគម្រោង
# សេវាកម្មក្រុង ស្រុក

# ជំពូកទី២

# ការត្រៀមរៀបចំគម្រោងសេវាកម្មក្រុង ស្រុក

ការរៀបចំគម្រោងសេវាកម្មត្រូវធ្វើឡើងបន្ទាប់ពីគម្រោងត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុកដែលបានអនុម័តដោយក្រុមប្រឹក្សានិងមុនពេលការចាប់ផ្តើមដំណើរការលទ្ធកម្ម។ ជំពូកនេះនឹងបរិយាយអំពីការត្រៀមរៀបចំនានាសម្រាប់ការចាប់ផ្តើមរៀបចំគម្រោងសេវាកម្មរបស់រដ្ឋបាលក្រុង ស្រុក។

សកម្មភាពចម្បងៗដែលត្រូវអនុវត្តក្នុងការត្រៀមរៀបចំគម្រោងសេវាកម្មរបស់ក្រុង ស្រុករួមមាន៖

- ការពិនិត្យគម្រោងវិនិយោគក្រុង ស្រុក
- ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មក្រុង ស្រុក
- ការកំណត់អំពីជំនួយបច្ចេកទេសផ្នែកសេវាកម្ម

## ២.១. ការពិនិត្យគម្រោងវិនិយោគក្រុង ស្រុក

ដោយមានជំនួយពីការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ និងនាយក នាយករងរដ្ឋបាល អភិបាលក្រុង ស្រុកត្រូវពិនិត្យមើលគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ ដោយប្រើប្រាស់ថវិកាក្រុង ស្រុក និងពិនិត្យតារាងផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងវិនិយោគក្រុង ស្រុកឆ្នាំទី១ ដើម្បីស្រង់យកគម្រោងដែលត្រូវអនុវត្តឱ្យស្របតាមផែនការសកម្មភាពដែលបានកំណត់។ ចំពោះគម្រោងវិនិយោគដែលត្រូវអនុវត្តដោយអង្គការសង្គមស៊ីវិល វិស័យឯកជន និងការិយាល័យ មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល (ក្រៅពីគម្រោងដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក) ក្រុង ស្រុកមិនចាំបាច់រៀបចំគម្រោងទាំងនោះឡើយ។ ក្នុងការពិនិត្យ និងស្រង់គម្រោងសម្រាប់ការរៀបចំនេះ អភិបាលក្រុង ស្រុកត្រូវណែនាំឱ្យការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ និងនាយក នាយករងរដ្ឋបាលក្រុង ស្រុកពិនិត្យស្រង់គម្រោងម្តងមួយៗតាមផ្នែកនីមួយៗ ដោយប្រើទម្រង់ទី១. បញ្ជីគម្រោងសេវាកម្ម។ ក្នុងការរៀបចំបញ្ជីគម្រោងនេះ គួររៀបចំតាមលំដាប់នៃពេលវេលា ដើម្បីឱ្យមានភាពងាយស្រួលក្នុងការចាប់ផ្តើមរៀបចំគម្រោង។

**ទម្រង់ទី១. បញ្ជីគម្រោងសេវាកម្មក្រុង ស្រុក**

| ល.រ | ឈ្មោះគម្រោង | កាលបរិច្ឆេទអនុវត្ត | | អនុវត្តដោយ | ផ្សេងៗ |
|---|---|---|---|---|---|
| | | ចាប់ផ្តើម | បញ្ចប់ | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | |
| | | | | | |
| | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | |
| | | | | | |
| | | | | | |
| ៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | | | | | |
| | | | | | |
| | | | | | |
| ៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | |
| | | | | | |

## ២.២. ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មក្រុង ស្រុក

### ២.២.១. គម្រោងក្រុង ស្រុក

គម្រោងក្រុង ស្រុកនីមួយៗត្រូវរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងមួយ។ គណៈអភិបាលក្រុង ស្រុករៀបចំសេចក្តីព្រាងសមាសភាព និងតួនាទី ភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងគម្រោង ហើយដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុកពិនិត្យ និងអនុម័ត។ សមាសភាពគណៈកម្មការនេះត្រូវមានស្ត្រី និងយុវជនចូលរួម។ ក្រុមប្រឹក្សាក្រុង ស្រុកត្រូវចេញសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងគម្រោង។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាក្រុង ស្រុក។

សមាសភាពរបស់គណៈកម្មការគ្រប់គ្រងគម្រោង រួមមាន ៖

- អភិបាលក្រុង ស្រុក ជាប្រធាន
- អភិបាលរងក្រុង ស្រុក ០១រូប ជាអនុប្រធាន
- នាយករដ្ឋបាល ឬនាយករងរដ្ឋបាលសាលាក្រុង ស្រុក ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សា ០១រូប ជាសមាជិក
- ប្រធាន ឬអនុប្រធាន ឬមន្ត្រីការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ នៃសាលាក្រុង ស្រុក ជាលេខាធិការ
- តំណាងគណៈកម្មាធិការលទ្ធកម្មក្រុង ស្រុក (០១រូប) ជាសមាជិក
- ប្រធាន ឬអនុប្រធាន ឬមន្ត្រីការិយាល័យសាលាក្រុង ស្រុកដែលពាក់ព័ន្ធនឹងគម្រោង ជាសមាជិក
- តំណាងក្រុមប្រឹក្សាឃុំ សង្កាត់មួយរូបពីឃុំ សង្កាត់នីមួយៗ ដែលទទួលផលដោយផ្ទាល់ពីគម្រោង ជាសមាជិក
- តំណាងអ្នកទទួលផលម្នាក់ពីភូមិនីមួយៗដែលទទួលផលដោយផ្ទាល់ពីគម្រោង ជាសមាជិក។

ក្រៅពីសមាសភាពខាងលើ រដ្ឋបាលក្រុង ស្រុកអាចសម្រេចជ្រើសរើសតំណាងការិយាល័យជំនាញ និងក្រុមប្រើប្រាស់ដែលនឹងទទួលខុសត្រូវសម្រាប់ការប្រើប្រាស់និងថែទាំអ្នកតំណាងភូមិ ឬអ្នកពាក់ព័ន្ធផ្សេងៗទៀតឱ្យចូលរួមតាមការចាំបាច់។

> **កំណត់សម្គាល់** ÷ ក្នុងការអនុវត្តជាក់ស្តែង រដ្ឋបាលក្រុង ស្រុកអាចចាត់តាំងសមាជិកក្រុមប្រឹក្សា ឬអភិបាល ឬអភិបាលរង ឬនាយក ឬនាយករងរដ្ឋបាល ឬមន្ត្រីដែលមានសមត្ថភាពឱ្យទទួលការងារជាប្រធានគណៈកម្មការគ្រប់គ្រងគម្រោងណាមួយតាមការចាំបាច់។

ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង។ ក្នុងករណីប្រធានអវត្តមានត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅឱ្យអនុប្រធានជាប្រធានស្តីទី ហើយប្រធានស្តីទីជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំ។

កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្ម អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល។ សេចក្តីសម្រេចរបស់អង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអាចយកជាការបានលុះត្រាមានសំឡេងអនុម័តលើសពីពាក់កណ្តាល នៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មការគ្រប់គ្រងគម្រោងអវត្តមានសមាជិកនោះអាចផ្ទេរសិទ្ធិជា

លាយល័ក្ខណ៍អក្សរឱ្យទៅសមាជិកណាមួយនៅក្នុងស្ថាប័ន អង្គភាព ឬក្រុមរបស់ខ្លួន ដើម្បីចូលរួមប្រជុំគណៈកម្មការជំនួសខ្លួនបាន។ សមាជិកដែលចូលរួមប្រជុំជំនួសនេះ ក៏មានសិទ្ធិសម្រេចដូចសមាជិកគណៈកម្មការគ្រប់គ្រងគម្រោងផងដែរ។

ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអាចអញ្ជើញបុគ្គលិកមកពីទីភ្នាក់ងារ ឬតំណាងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងក្នុងនាមជាអ្នកសង្កេតការណ៍ និងឬ ផ្តល់យោបល់។

អ្នកជំនួយបច្ចេកទេសនិងមន្ត្រីដែលមានភារកិច្ចជួយគាំទ្រក្រុង ស្រុកត្រូវចូលរួមកិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងក្នុងនាមជាអ្នកសង្កេតការណ៍និងឬផ្តល់យោបល់។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

### ២.២.២. គម្រោងអន្តររដ្ឋបាល

ក្នុងករណីរដ្ឋបាលក្រុង ស្រុកធ្វើកិច្ចសហប្រតិបត្តិការ និងព្រមព្រៀងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទរួមគ្នា(ជាមួយក្រុង ស្រុក) ឬប្រភេទខុសគ្នា (ជាមួយឃុំ សង្កាត់ ឬជាមួយខេត្ត ឬជាមួយឃុំ សង្កាត់ និងខេត្ត) រដ្ឋបាលពាក់ព័ន្ធនឹងគម្រោងនោះត្រូវជួបប្រជុំគ្នា ដើម្បីពិភាក្សា និងព្រមព្រៀងទៅលើការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មអន្តររដ្ឋបាលមួយសម្រាប់គម្រោងអន្តររដ្ឋបាលមួយ តាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋបាលដែលពាក់ព័ន្ធនឹងគម្រោងនោះ(**ទម្រង់ទី២**)។

គណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មអន្តររដ្ឋបាលមានសមាសភាពដូចខាងក្រោម ៖

- អភិបាលក្រុង ស្រុក ឬមេឃុំ ចៅសង្កាត់មួយរូបនៃរដ្ឋបាលដែលពាក់ព័ន្ធនឹងគម្រោងសេវាកម្មអន្តររដ្ឋបាលនោះជាប្រធាន
- អភិបាលក្រុង ស្រុក ឬមេឃុំ ចៅសង្កាត់ទាំងអស់នៃរដ្ឋបាលដែលពាក់ព័ន្ធនឹងគម្រោងសេវាកម្មអន្តររដ្ឋបាលនោះ ជាសមាជិក
- នាយករដ្ឋបាល ឬនាយករងរដ្ឋបាល ឬស្មៀនឃុំ សង្កាត់នៃប្រធានគណៈកម្មការគម្រោងអន្តររដ្ឋបាលជាលេខាធិការ
- តំណាងអ្នកទទួលផលម្នាក់ពីភូមិនីមួយៗ ដែលលទ្ធផលពីគម្រោងសេវាកម្មបានស្ថាបនានៅក្នុងភូមិទាំងនោះជាសមាជិក។ ប្រសិនបើមានក្រុមអ្នកប្រើប្រាស់ដែលនឹងទទួលខុសត្រូវសម្រាប់ការប្រើប្រាស់ និងថែទាំអ្នកតំណាងភូមិគួរមកពីក្រុមអ្នកប្រើប្រាស់។

> **កំណត់សម្គាល់** ÷ ករណីបើមានគម្រោងសេវាកម្មក្រុងស្រុកដែលមានលក្ខណៈជាគម្រោងសេវាសង្គមអន្តររដ្ឋបាលរដ្ឋបាលពាក់ព័ន្ធត្រូវពិគ្រោះពិភាក្សា និងសម្រេចអំពីប្រធានគណៈកម្មការគ្រប់គ្រងគម្រោងនោះ។ ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងគឺជាអ្នកបញ្ជូននិងទទួលឯកសារគម្រោងទាំងទៅទាំងមកពីរដ្ឋបាលខេត្ត។

ក្រុមប្រឹក្សាអាចសម្រេចបន្ថែម ឬបន្ថយចំនួន និងសមាសភាពគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលតាមការចាំបាច់។ ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល គឺជាអភិបាលក្រុង ស្រុក ឬជាមេឃុំ ចៅសង្កាត់ដែលពាក់ព័ន្ធនឹងគម្រោងអន្តររដ្ឋបាលនោះ តាមការព្រមព្រៀងឯកភាពគ្នារវាងរដ្ឋបាលពាក់ព័ន្ធនឹងគម្រោងទាំងនោះ។

ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មអន្តររដ្ឋបាលក្រុង ស្រុក គឺជាតំណាងផ្លូវការក្នុងការចុះហត្ថលេខាលើគ្រប់ឯកសារផ្លូវការនានាពាក់ព័ន្ធនឹងការអនុវត្តគម្រោងអន្តររដ្ឋបាល ដោយប្រើប្រាស់ត្រា និងចុះលេខរបស់រដ្ឋបាលសាមី លើកលែងតែលិខិតជូនដំណឹងស្តីពីការដេញថ្លៃ កំណត់ហេតុនៃកិច្ចប្រជុំដេញថ្លៃ របាយការណ៍នៃកិច្ចប្រជុំដេញថ្លៃ និងរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម ដែលឯកសារទាំងនេះត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការលទ្ធកម្ម។ ក្នុងករណីប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលអវត្តមាន អភិបាលស្តីទី ឬមេឃុំ ចៅសង្កាត់ស្តីទីនៃរដ្ឋបាលដែលទទួលភារកិច្ចជាប្រធានគណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មអន្តររដ្ឋបាលក្រុង ស្រុក គឺជាប្រធានស្តីទីនៃគណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មអន្តររដ្ឋបាលក្រុង ស្រុក។

ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្មអន្តររដ្ឋបាលក្រុង ស្រុកជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង។ ក្នុងករណីប្រធានអវត្តមានប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល។

សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលអាចយកជាការបាន លុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសម្លេងអនុម័តមានចំនួនស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលអវត្តមានសមាជិកនោះអាចផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរឱ្យទៅសមាជិកណាមួយនៅក្នុងស្ថាប័ន អង្គភាព ឬក្រុមរបស់ខ្លួន ដើម្បីចូលរួមប្រជុំគណៈកម្មការជំនួសខ្លួនបាន។ សមាជិកដែលចូលរួមប្រជុំជំនួសនេះ ក៏មានសិទ្ធិសម្រេចដូចសមាជិកគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលផងដែរ។

ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលអាចអញ្ជើញបុគ្គលិកមកពីទីភ្នាក់ងារ ឬតំណាងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលក្នុងនាមជាអ្នកសង្កេតការណ៍។

អ្នកជំនួយបច្ចេកទេសនិងមន្ត្រីខេត្តដែលមានភារកិច្ចគាំទ្រក្រុង ស្រុក ត្រូវចូលរួមកិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលក្នុងនាមជាអ្នកសង្កេតការណ៍។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលត្រូវមានកំណត់ហេតុ ដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

## ឧបសម្ព័ន្ធទី២ ÷ កិច្ចព្រមព្រៀងស្តីពីគម្រោងសេវាកម្មអន្តររដ្ឋបាលក្រុង ស្រុក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិសាសនាព្រះមហាក្សត្រ**

## កិច្ចព្រមព្រៀង
## ស្តីពី
## ការគ្រប់គ្រងគម្រោងសេវាកម្មអន្តររដ្ឋបាលក្រុង ស្រុក

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅថ្ងៃទី....... ខែ........... ឆ្នាំ.........រវាង៖

- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី.............................................
- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី.............................................
- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី.............................................
- រដ្ឋបាល.................... តំណាងដោយ........................ តួនាទី.............................................

ភាគីទាំងអស់បានឯកភាពគ្នាតាមលក្ខខ័ណ្ឌដូចខាងក្រោម ៖

**ប្រការ ១.-**

គម្រោង...................................(ឈ្មោះគម្រោង)..................................................................
នឹងអនុវត្តទៅតាមលក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

**ប្រការ ២.-**

ចំនួនថវិកាប៉ាន់ស្មានដែលត្រូវចូលរួមចំណែកដល់គម្រោងអន្តររដ្ឋបាលនៃរដ្ឋបាលនីមួយៗដែលពាក់ព័ន្ធមានដូចខាងក្រោម ៖

- រដ្ឋបាល............... ចំនួន................ (ជាអក្សរ.....................................................................)
- រដ្ឋបាល............... ចំនួន................ (ជាអក្សរ.....................................................................)
- រដ្ឋបាល............... ចំនួន................ (ជាអក្សរ.....................................................................)

**សរុប**........................ (ជាអក្សរ.....................................................................)

រដ្ឋបាលដែលពាក់ព័ន្ធនឹងគម្រោងអន្តររដ្ឋបាលបានឯកភាពគ្នា ក្នុងការផ្ទេរថវិកានៃចំណែករបស់ខ្លួនទាំងអស់ ឬជាដំណាក់កាលទៅក្នុងគណនីរបស់រដ្ឋបាលនៃប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលបន្ទាប់ពីកិច្ចសន្យានៃគម្រោងនេះត្រូវបានចុះហត្ថលេខា។

**ប្រការ ៣.-**

គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលមានសមាសភាពដូចខាងក្រោម៖

| ល.រ | ឈ្មោះ | ភេទ | មកពី | តួនាទី |
|---|---|---|---|---|
| | | | | ប្រធាន |
| | | | | សមាជិក |
| | | | | សមាជិក |
| | | | | លេខាធិការ |

**ប្រការ ៤.-**

គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

**១. ក្នុងដំណាក់កាលរៀបចំគម្រោង**

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោងអន្តររដ្ឋបាល
- គ្រប់គ្រងចាត់ចែងដំណើរការសិក្សា និងរៀបចំគម្រោងអន្តររដ្ឋបាល
- កំណត់អ្នកជំនួយបច្ចេកទេសសម្រាប់ជួយក្នុងការរៀបចំ និងអនុវត្តគម្រោងអន្តររដ្ឋបាល
- រៀបចំឯកសារគម្រោងអន្តររដ្ឋបាល ដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យ និងអនុម័តឯកសារគម្រោងអន្តររដ្ឋបាល។

**២. ក្នុងដំណាក់កាលអនុវត្តគម្រោង**

- ពិនិត្យ និងឯកភាពទៅលើអ្នកដេញថ្លៃដែលមានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងអន្តររដ្ឋបាល ដោយផ្អែកតាមការសម្រេចរបស់រដ្ឋបាលពាក់ព័ន្ធ
- ធានាដល់ការរៀបចំឯកសារដេញថ្លៃគម្រោងអន្តររដ្ឋបាលឱ្យបានត្រឹមត្រូវទៅតាមការកំណត់
- ចេញលិខិតជូនដំណឹងស្តីពីការសម្រេចផ្តល់កិច្ចសន្យាដល់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មឬអ្នកផ្គត់ផ្គង់ទំនិញទៅតាមលទ្ធផលនៃការដេញថ្លៃ
- រៀបចំ និងអនុម័តសំណុំឯកសារកិច្ចសន្យា និងព័ត៌មានកិច្ចសន្យា
- ពិនិត្យ និងឯកភាពលើផែនការការងាររបស់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម
- រៀបចំប្រជុំបើកការអនុវត្តគម្រោង កិច្ចប្រជុំបញ្ចប់គម្រោង រៀបចំប្រជុំពិនិត្យ និងអនុម័តការទូទាត់គម្រោងអន្តររដ្ឋបាល
- តាមដានត្រួតពិនិត្យការអនុវត្តគម្រោងអន្តររដ្ឋបាល
- រៀបចំសំណុំឯកសារទូទាត់ និងចេញអាណត្តិទូទាត់
- រៀបចំកិច្ចប្រជុំជាទៀងទាត់នៅក្នុងអំឡុងពេលអនុវត្តគម្រោងអន្តររដ្ឋបាលដើម្បីពិនិត្យនិងវាយតម្លៃការអនុវត្តគម្រោងអន្តររដ្ឋបាល។

**ប្រការ ៥.-**

ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល គឺជាតំណាងផ្លូវការរបស់គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល ក្នុងការចុះហត្ថលេខាលើឯកសារផ្លូវការនានា ដែលទាក់ទងនឹងការអនុវត្តគម្រោងដោយប្រើប្រាស់ត្រា និងចុះលេខរបស់រដ្ឋបាលសាមីលើកលែងតែលិខិតជូនដំណឹងស្តីពីការដេញថ្លៃ កំណត់ហេតុនៃកិច្ចប្រជុំដេញថ្លៃរបាយការណ៍នៃកិច្ចប្រជុំដេញថ្លៃ និងរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម។

ក្នុងករណីប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលអវត្តមាន អភិបាលស្តីទី ឬមេឃុំ ចៅសង្កាត់ស្តីទីនៃរដ្ឋបាលដែលទទួលភារកិច្ចជាប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល គឺជាប្រធានស្តីទីនៃគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល។

ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល ជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង។ក្នុងករណីប្រធានអវត្តមាន ប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល។

សេចក្តីសម្រេចរបស់អង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល អាចយកជាការបានលុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសម្លេងអនុម័តមានចំនួនស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលអវត្តមាន សមាជិកនោះអាចផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរឱ្យទៅសមាជិកណាមួយនៅក្នុងស្ថាប័ន អង្គភាព ឬក្រុមរបស់ខ្លួន ដើម្បីចូលរួមប្រជុំគណៈកម្មការជំនួសខ្លួនបាន។ សមាជិកដែលចូលរួមប្រជុំជំនួសនេះ ក៏មានសិទ្ធិសម្រេចដូចសមាជិកគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលផងដែរ។

ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងរដ្ឋបាលអាចអញ្ជើញបុគ្គលិកមកពីទីភ្នាក់ងារ ឬតំណាងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល ក្នុងនាមជាអ្នកសង្កេតការណ៍។

អ្នកជំនួយបច្ចេកទេសនិងមន្ត្រីខេត្តដែលមានភារកិច្ចគាំទ្រក្រុង ស្រុកត្រូវចូលរួមកិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល ក្នុងនាមជាអ្នកសង្កេតការណ៍។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលត្រូវមានកំណត់ហេតុ ដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

**ប្រការ ៦.-**

គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មនៃប្រធានគណៈកម្មការគម្រោងអន្តររដ្ឋបាល ត្រូវបានប្រើប្រាស់សម្រាប់ដំណើរការលទ្ធកម្មគម្រោងអន្តររដ្ឋបាលនេះ។

គណៈកម្មាធិការលទ្ធកម្មនៃរដ្ឋបាលពាក់ព័ន្ធដទៃទៀតនៃគម្រោងអន្តររដ្ឋបាលនេះ ចូលរួមនៅក្នុងការប្រជុំបើកសំណើដេញថ្លៃ ការប្រជុំវាយតម្លៃសំណើដេញថ្លៃ និងការប្រជុំប្រកាសលទ្ធផលនៃការដេញថ្លៃ ក្នុងនាមជាអ្នកសង្កេតការណ៍។

**ប្រការ ៧.-**

លោកលោកស្រីខាងក្រោមនេះជាតំណាងម្ចាស់គម្រោងអន្តររដ្ឋបាល ៖

| ល.រ | ឈ្មោះ | ភេទ | ភូមិ | ឃុំសង្កាត់ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

តំណាងម្ចាស់គម្រោងអន្តររដ្ឋបាលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ចូលរួមគ្រប់កិច្ចប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល
- តាមដានត្រួតពិនិត្យការអនុវត្តការងារប្រចាំថ្ងៃរបស់អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញនៅក្នុងអំឡុងពេលអនុវត្តគម្រោង
- រាយការណ៍អំពីការរីកចម្រើនគម្រោងនៅក្នុងភូមិសាស្ត្ររបស់ខ្លួនជូនអង្គប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល

- ក្នុងករណីតំណាងម្ចាស់គម្រោងពិនិត្យឃើញថា ការអនុវត្តគម្រោងមិនសមស្របតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យាតំណាងម្ចាស់គម្រោងមានសិទ្ធិក្នុងការបញ្ជាឱ្យអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញបញ្ឈប់ការងារជាបណ្តោះអាសន្នចំនួន២ថ្ងៃការងារ ដើម្បីទុកពេលវេលាឱ្យអ្នកត្រួតពិនិត្យបច្ចេកទេសចុះត្រួតពិនិត្យការងារជាក់ស្តែង
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល។

**ប្រការ ៨.-**

លោកលោកស្រី...................................ជាអ្នកជំនួយបច្ចេកទេសសម្រាប់គម្រោង..........................
...............(ឈ្មោះគម្រោង).................................................។

អ្នកជំនួយបច្ចេកទេសជួយគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលលើការងារដូចខាងក្រោម ៖

- រៀបចំផែនការសិក្សាគម្រោង
- អនុវត្តការសិក្សាគម្រោង
- រៀបចំគ្រោងការគម្រោង
- រៀបចំគំនូសប្លង់បច្ចេកទេស និងសេចក្តីលម្អិតបច្ចេកទេស
- ប៉ាន់ស្មានតម្លៃគម្រោង
- បំពេញព័ត៌មានផ្នែកបច្ចេកទេសទៅក្នុងទម្រង់ព័ត៌មានគម្រោង
- រៀបចំឯកសារដែលទាក់ទងនឹងការងារលទ្ធកម្ម
- ពិនិត្យផែនការការងាររបស់អ្នកផ្តល់សេវាកម្ម
- រៀបចំឯកសារកិច្ចសន្យា
- ចូលរួមគ្រប់ការប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលនៅក្នុងអំឡុងពេលរៀបចំគម្រោង និងកិច្ចលទ្ធកម្មកិច្ចសន្យា
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល។

**ប្រការ ៩.-**

លោកលោកស្រី................................ជាអ្នកត្រួតពិនិត្យបច្ចេកទេសសម្រាប់គម្រោង......................
...........................(ឈ្មោះគម្រោង).................................................។

អ្នកត្រួតពិនិត្យបច្ចេកទេសជួយគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលលើការងារដូចខាងក្រោម ៖

- ផ្តល់យោបល់ដល់គណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល និងអ្នកផ្តល់សេវាកម្មអំពីបញ្ហាបច្ចេកទេស
- បង្រៀនគណៈកម្មការគ្រប់គ្រងគម្រោងឬតំណាងម្ចាស់គម្រោងអំពីចំណុចសំខាន់ៗផ្នែកបច្ចេកទេស ដើម្បីតាមដាន ត្រួតពិនិត្យការអនុវត្តកិច្ចសន្យា
- ត្រួតពិនិត្យកិច្ចសន្យា
- រៀបចំរបាយការណ៍រីកចម្រើនដែលបញ្ជាក់ទៅលើគុណភាពនិងបរិមាណនៃការងាររបស់អ្នកផ្តល់សេវាកម្ម
- ចូលរួមគ្រប់ការប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាលនៅក្នុងអំឡុងអនុវត្តកិច្ចសន្យា
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តររដ្ឋបាល។

**ប្រការ ១០.-**

កិច្ចព្រមព្រៀងនេះរៀបចំឡើងចំនួន........ច្បាប់ដើម ហើយរក្សាទុកនៅរដ្ឋបាលនីមួយៗដែលពាក់ព័ន្ធនឹងគម្រោង០១ច្បាប់។

**ប្រការ ១១.-**

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**អភិបាលក្រុង ស្រុក ឬមេឃុំចៅសង្កាត់**............ **អភិបាលក្រុង ស្រុក ឬមេឃុំចៅសង្កាត់**............

**អភិបាលក្រុង ស្រុក ឬមេឃុំចៅសង្កាត់**............ **អភិបាលក្រុង ស្រុក ឬមេឃុំចៅសង្កាត់**............

## ២.៣. ការកំណត់អ្នកផ្តល់ជំនួយបច្ចេកទេសសេវាកម្ម

គណៈអភិបាលក្រុង ស្រុកត្រូវកំណត់អ្នកផ្តល់ជំនួយបច្ចេកទេសដើម្បីជួយក្នុងការរៀបចំគម្រោងសេវាកម្មរបស់ខ្លួន។ អ្នកជំនួយបច្ចេកទេសសេវាកម្ម អាចជា ៖

- មន្ត្រីនៃសាលាក្រុង ស្រុក ឬរាជធានី ខេត្ត។ ក្នុងករណីនេះ គណៈអភិបាលក្រុង ស្រុក ត្រូវតែងតាំងមន្ត្រីបច្ចេកទេសមួយរូបជាអ្នកជំនួយបច្ចេកទេសសេវាកម្ម។
- មន្ត្រីនៃមន្ទីរ អង្គភាពជំនាញក្រុង ស្រុក ឬរាជធានី ខេត្ត។ ក្នុងករណីនេះ គណៈអភិបាលក្រុង ស្រុក ត្រូវស្នើសុំទៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្តជាលាយលក្ខណ៍អក្សរ ដើម្បីផ្តល់មន្ត្រីបច្ចេកទេសមួយរូបជាអ្នកជំនួយបច្ចេកទេសសេវាកម្ម។
- អ្នកជំនាញ ឬក្រុមហ៊ុន ឬអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងករណីនេះ គណៈអភិបាលក្រុង ស្រុកត្រូវធ្វើការជ្រើសរើសទៅតាមនីតិវិធីដែលបានកំណត់ និងប្រកបដោយតម្លាភាព។

នៅពេលកំណត់បានអ្នកផ្តល់ជំនួយបច្ចេកទេស ហើយគណៈអភិបាលក្រុង ស្រុកត្រូវតែងតាំងអ្នកជំនួយបច្ចេកទេសសេវាកម្មនោះ។

# ជំពូកទី៣

# ការសិក្សាគម្រោងសេវាកម្ម

# ក្រុង ស្រុក

# ជំពូកទី៣

# ការសិក្សាគម្រោងសេវាកម្មក្រុង ស្រុក

បន្ទាប់ពីបញ្ចប់ការត្រៀមរៀបចំគម្រោងសេវាកម្ម គណៈកម្មការគ្រប់គ្រងគម្រោងត្រូវធ្វើការសិក្សាអំពីគម្រោងនីមួយៗ។ ជំពូកនេះ នឹងបរិយាយអំពីសកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តក្នុងការសិក្សាអំពីគម្រោងសេវាកម្មនីមួយៗ ដែលរួមមាន៖

- ការរៀបចំផែនការសិក្សាគម្រោងសេវាកម្ម
- ការវិភាគផលប៉ះពាល់បរិស្ថាន

## ៣.១. ការរៀបចំផែនការសិក្សាគម្រោងសេវាកម្ម

ផែនការសិក្សាគម្រោង ត្រូវរៀបចំសម្រាប់ការសិក្សាគម្រោងទាំងអស់ ដែលមានក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ហើយដែលត្រូវបានគ្រោងក្នុងការប្រើប្រាស់ថវិកាពី ៖

- មូលនិធិក្រុង ស្រុក
- ប្រភពផ្សេងទៀតដែលបានបញ្ចូលនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក។

ក្នុងការរៀបចំផែនការសិក្សាគម្រោង អ្នកជំនួយបច្ចេកទេសត្រូវពិនិត្យលើបញ្ជីគម្រោងម្តងមួយគម្រោងៗ ដោយត្រូវកំណត់អំពីព័ត៌មានចាំបាច់មួយចំនួនពាក់ព័ន្ធនឹង៖

- ឈ្មោះគម្រោង
- លទ្ធផលគ្រោងរបស់គម្រោង
- តម្រូវការសកម្មភាពសិក្សាគម្រោង
- តម្រូវការវិភាគផលប៉ះពាល់បរិស្ថាន
- រយៈពេលសម្រាប់ការសិក្សាគម្រោង
- កាលបរិច្ឆេទបញ្ចប់ការសិក្សាគម្រោង។

ក). **ការកំណត់លទ្ធផលគ្រោងរបស់គម្រោង ៖** លទ្ធផលគ្រោងរបស់គម្រោង គឺជាលទ្ធផលដែលរំពឹងថានឹងទទួលបានពីការអនុវត្តគម្រោង។ អ្នកជំនួយបច្ចេកទេសអាចស្រង់លទ្ធផលគ្រោងរបស់គម្រោងចេញពីតារាងគម្រោង វិនិយោគបីឆ្នាំរំកិលនៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក បញ្ចូលក្នុងកូឡោន "លទ្ធផលគ្រោង" នៃតារាងផែនការសិក្សាគម្រោង ក្រុង ស្រុក ម្តងមួយគម្រោងៗ(ទម្រង់ទី៣)។

ខ). **ការកំណត់តម្រូវការសកម្មភាពសិក្សាគម្រោង ៖** អ្នកជំនួយបច្ចេកទេសត្រូវពិនិត្យគ្រប់គម្រោងក្រុង ស្រុក ទាំងអស់ម្តងមួយៗ ហើយកំណត់ថាតើគម្រោងនីមួយៗនោះត្រូវការសកម្មភាពសិក្សាអ្វីខ្លះ?។

**ឧទាហរណ៍ ៖** គម្រោងរៀបចំថ្នាក់មត្តេយ្យសិក្សាសហគមន៍។ តម្រូវការសកម្មភាពសិក្សាគម្រោងនេះអាចមាន ៖

- សិក្សាចំនួនកុមារដែលមានអាយុពី០៣ទៅ០៥ឆ្នាំនៅក្នុងសហគមន៍
- ការសិក្សាអំពីចំនួនសិស្សថ្នាក់ទី១ដែលបានបោះបង់ការសិក្សា
- មូលហេតុដែលសិស្សបោះបង់ចោលសាលា
- ទីតាំងមត្តេយ្យសាលារដ្ឋ
- ទីតាំងសម្រាប់បើកថ្នាក់មត្តេយ្យសិក្សាសហគមន៍
- លទ្ធភាពសហគមន៍ក្នុងការគាំទ្រគ្រូមត្តេយ្យ ដំណើរការរបស់ថ្នាក់មត្តេយ្យសិក្សាសហគមន៍។ល។

បន្ទាប់ពីកំណត់តម្រូវការសកម្មភាពសិក្សាគម្រោង អ្នកជំនួយបច្ចេកទេសត្រូវស្រង់ចូលក្នុងកូឡោន "សកម្មភាពសិក្សាគម្រោងដែលត្រូវការ" នៃតារាងផែនការសិក្សាគម្រោង ក្រុង ស្រុក(ទម្រង់ទី៣)។

គ). **ការកំណត់តម្រូវការវិភាគផលប៉ះពាល់បរិស្ថាន** ៖ អ្នកជំនួយបច្ចេកទេសត្រូវពិនិត្យគ្រប់គម្រោងក្រុង ស្រុកទាំងអស់ដើម្បីកំណត់ថាតើគម្រោងនីមួយៗទាំងនោះត្រូវធ្វើការសិក្សាផលប៉ះពាល់បរិស្ថានដែរឬទេ?។ ប្រសិនបើ ពិនិត្យឃើញថាគម្រោងនោះត្រូវការសិក្សាអំពីផលប៉ះពាល់បរិស្ថានអ្នកជំនួយបច្ចេកទេសត្រូវបញ្ជាក់ថា "ត្រូវការ" ប៉ុន្តែប្រសិនបើពិនិត្យឃើញថាមិនចាំបាច់ អ្នកជំនួយបច្ចេកទេសត្រូវបញ្ជាក់ថា "មិនត្រូវការ" ក្នុងកូឡោន "ត្រូវការការសិក្សាផលប៉ះពាល់បរិស្ថាន" នៃតារាងផែនការសិក្សាគម្រោងក្រុង ស្រុក(ទម្រង់ទី៣)។

គម្រោងសេវាកម្មដែលត្រូវធ្វើការវិភាគផលប៉ះពាល់បរិស្ថានគឺជាគម្រោងដែល ៖

- ការអនុវត្តនៃគម្រោងនោះអាចបណ្តាលឱ្យមានការខូចខាត ឬប៉ះពាល់ដល់បរិស្ថាន ឬវប្បធម៌ និងទំនៀមទំលាប់ប្រពៃណីល្អក្នុងតំបន់នោះ
- ការអនុវត្តនៃគម្រោងអាចបណ្តាលឱ្យមានការខូចខាតឬប៉ះពាល់ដល់ប្រភពផ្គត់ផ្គង់ទឹកដែលប្រជាពលរដ្ឋកំពុងប្រើប្រាស់។
- គម្រោងផ្សេងទៀតដែលធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន ដូចជា គម្រោងស្រែបង្ហាញដោយប្រើប្រាស់ជីគីមីនិងថ្នាំពុលគីមីកសិកម្ម គម្រោងប្រមូលនិងគ្រប់គ្រងសំរាមតាមទីប្រជុំជន និងឬគម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបង្កឱ្យមានផលប៉ះពាល់ធនធានធម្មជាតិជាដើម។

ឃ). **ការកំណត់រយៈពេលសម្រាប់ការសិក្សា** ៖ អ្នកជំនួយបច្ចេកទេសត្រូវកំណត់រយៈពេលជាក់លាក់សម្រាប់ ការសិក្សាគម្រោងនីមួយៗ។ ចំពោះគម្រោងមួយចំនួន ពេលវេលាសិក្សាគម្រោងមានរយៈពេលខ្លី ប៉ុន្តែគម្រោងមួយចំនួនទៀតអាចត្រូវការរយៈពេលវែងជាងអាស្រ័យតាមលក្ខណៈ និងភាពស្មុគ្រស្មាញនៃគម្រោងនោះ។ រយៈពេលសិក្សាគម្រោងអាចកំណត់ជាចំនួនថ្ងៃជាក់លាក់។ បន្ទាប់ពីកំណត់រយៈពេលសិក្សា ហើយអ្នកជំនួយបច្ចេកទេសត្រូវស្រង់ចូលក្នុងកូឡោន "ចំនួនថ្ងៃធ្វើការ"នៃតារាងផែនការសិក្សាគម្រោងក្រុង ស្រុក (ទម្រង់ទី៣)។

ង). **កាលបរិច្ឆេទបញ្ចប់ការសិក្សាគម្រោង** ៖ អ្នកជំនួយបច្ចេកទេសត្រូវកំណត់កាលបរិច្ឆេទសម្រាប់បញ្ចប់ការសិក្សាគម្រោងសម្រាប់គម្រោងនីមួយៗ។ បន្ទាប់ពីកំណត់ហើយអ្នកជំនួយបច្ចេកទេសត្រូវស្រង់ចូលក្នុងកូឡោន "កាលបរិច្ឆេទបញ្ចប់ការសិក្សាគម្រោង" នៃតារាងផែនការសិក្សាគម្រោង ក្រុង ស្រុក(ទម្រង់ទី៣)។

ច). **យោបល់ផ្សេងៗ** ៖ អ្នកជំនួយបច្ចេកទេសអាចធ្វើកំណត់សម្គាល់នានា តាមការចាំបាច់។

ផែនការសិក្សាគម្រោងត្រូវរក្សាទុកក្នុងសំណុំឯកសារគម្រោងនៅសាលាក្រុង ស្រុក។ ចំពោះគម្រោងអន្តររដ្ឋបាល ផែនការសិក្សាគម្រោងច្បាប់ដើម ត្រូវរក្សាទុកនៅការិយាល័យនៃប្រធានគណៈកម្មការគ្រប់គ្រងគម្រោង ហើយច្បាប់ថតចម្លងត្រូវរក្សាទុកនៅតាមរដ្ឋបាលដែលពាក់ព័ន្ធគម្រោងនោះ។

ក្នុងការអនុវត្តការសិក្សាគម្រោង អ្នកជំនួយបច្ចេកទេសអាចពិចារណាចំណុចមួយចំនួនដូចខាងក្រោម ៖

- គម្រោងសេវាកម្មរបស់ក្រុង ស្រុកត្រូវមានការរៀបចំគម្រោងសម្រាប់តែឆ្នាំដំបូងប៉ុណ្ណោះ។ បន្ទាប់ពីនោះមក ការបន្តផ្តល់សេវាកម្មគឺជាគម្រោងចាស់វាមិនមែនជាគម្រោងថ្មីនោះទេ។
- អ្នកជំនួយបច្ចេកទេសមិនមែនធ្វើការសិក្សាគម្រោងតែម្នាក់ឯងនោះទេ។ ក្រុង ស្រុកត្រូវធានាឱ្យមានអ្នកទទួលផលពីគម្រោងចូលរួមឱ្យបានគ្រប់គ្រាន់ជាពិសេសត្រូវផ្តោតលើស្ត្រី កុមារ យុវជន ជនជាតិ

ដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងៗទៀត ដើម្បីជួយដល់អ្នកជំនួយបច្ចេកទេស ក្នុងការសិក្សាគម្រោងឱ្យបានពេញលេញ។

- អ្នកជំនួយបច្ចេកទេសអាចធ្វើសកម្មភាពសិក្សាគម្រោងបានគ្រប់ពេលវេលាអាស្រ័យលើលក្ខខណ្ឌសមស្រប និងពេលវេលាដែលអាចធ្វើបាន។
- អ្នកជំនួយបច្ចេកទេសត្រូវសិក្សាគម្រោងទាំងមូល មិនមែនសិក្សាត្រឹមតែលទ្ធផលដែលមានថវិកាសម្រាប់អនុវត្តនោះទេ។
- ប្រសិនបើ គម្រោងមួយដែលត្រូវអនុវត្តរយៈពេលលើសពី១ឆ្នាំ គម្រោងនោះមិនតម្រូវឱ្យធ្វើការសិក្សា ២ដង ឬច្រើនដងនោះទេ។
- កិច្ចប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោងចាស់មិនចាំបាច់ធ្វើការរៀបចំគម្រោងទេ។

## ទម្រង់ទី៣ ÷ ផែនការសិក្សាគម្រោងសេវាកម្មក្រុង ស្រុក

| ខេត្ត៖ | ក្រុង ស្រុក៖ | លេខកូដក្រុង ស្រុក៖ |
|---|---|---|

| ឈ្មោះគម្រោង | លទ្ធផលគ្រោង | សកម្មភាពសិក្សាគម្រោងដែលត្រូវការ | ត្រូវការការសិក្សាផលប៉ះពាល់បរិស្ថាន | ចំនួនថ្ងៃធ្វើការងារ | កាលបរិច្ឆេទបញ្ចប់ផែនការ | យោបល់ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |

ថ្ងៃទី........ ខែ............. ឆ្នាំ.........

**អភិបាលក្រុង ស្រុក**

ថ្ងៃទី........ ខែ............. ឆ្នាំ.........

**អ្នកជំនួយបច្ចេកទេស**

## ៣.២. ការវិភាគផលប៉ះពាល់បរិស្ថាន

ការវិភាគផលប៉ះពាល់បរិស្ថាន គឺជាការសិក្សាមួយដើម្បីស្វែងរកផលប៉ះពាល់របស់គម្រោងទៅលើបរិស្ថាន មុននឹងធ្វើលទ្ធកម្មនិងអនុវត្តគម្រោង។ ដោយផ្អែកតាមផែនការសិក្សាគម្រោងដែលបានរៀបចំ ប្រសិនបើ "មានតម្រូវការសិក្សាផលប៉ះពាល់បរិស្ថាន" ក្រុង ស្រុកត្រូវចាត់តាំងមន្ត្រីទទួលបន្ទុករបស់ក្រុង ស្រុក ដែលមានសមត្ថភាពឱ្យអនុវត្តការសិក្សាផលប៉ះពាល់បរិស្ថាននៃគម្រោងនោះ ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។ ការសិក្សាត្រូវធ្វើឡើងនៅទីតាំង និងឬជិតទីតាំងគម្រោងនោះ។

សកម្មភាពចម្បងៗ ដែលត្រូវអនុវត្តក្នុងការសិក្សាផលប៉ះពាល់បរិស្ថាននៃគម្រោងសេវាកម្មក្រុង ស្រុករួមមាន ៖

- ការណែនាំអំពីគម្រោង
- ការរៀបចំផែនទីបរិស្ថាន
- ការរៀបចំបញ្ជីវិភាគផលប៉ះពាល់បរិស្ថាន
- អនុសាសន៍
- ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន
- រៀបចំរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន
- ការតាមដានផលប៉ះពាល់បរិស្ថាន
- ការពិនិត្យរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន។

### ៣.២.១. ការណែនាំអំពីគម្រោង

មន្ត្រីទទួលបន្ទុកអនុវត្តការសិក្សាផលប៉ះពាល់បរិស្ថានត្រូវធ្វើការណែនាំ ឬបង្ហាញឱ្យប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាដែលចូលរួមសិក្សាផលប៉ះពាល់បានយល់ដឹងអំពីគម្រោង។ ព័ត៌មានសំខាន់ៗនៃគម្រោងដែលត្រូវបង្ហាញមានដូចជា៖

- ឈ្មោះគម្រោង
- លទ្ធផលគ្រោងរបស់គម្រោង
- មូលហេតុសម្រាប់ការអនុវត្តគម្រោង
- ចំនួន និងប្រភេទអ្នកទទួលផលពីគម្រោង
- ទីតាំងគម្រោង
- ពេលវេលានៃការអនុវត្តគម្រោង
- ចំនួនថវិកា និងប្រភពថវិកាជាដើម

បន្ទាប់មក មន្ត្រីទទួលបន្ទុកត្រូវពន្យល់អំពីមូលហេតុចាំបាច់ ដែលត្រូវធ្វើការវិភាគផលប៉ះពាល់បរិស្ថានចំពោះគម្រោងនេះ។ មន្ត្រីទទួលបន្ទុកក៏ត្រូវតែប្រាកដថាប្រជាពលរដ្ឋបានដឹងច្បាស់ថា លទ្ធផលនៃការវិភាគនេះគឺគ្រាន់តែជាការផ្តល់អនុសាសន៍តែប៉ុណ្ណោះ។ ជួនកាលអនុសាសន៍ដែលបានលើកឡើងនៅក្នុងអំឡុងពេលធ្វើការវិភាគនេះ អាចនឹងមិនត្រូវបានអនុវត្តតាមទាំងស្រុងនោះទេ។

### ៣.២.២. ការរៀបចំផែនទីបរិស្ថាន

ដំណាក់កាលដំបូងនៃការវិភាគផលប៉ះពាល់បរិស្ថាន គឺត្រូវធ្វើផែនទីបរិស្ថានរបស់គម្រោងជាមុន។ ផែនទីនេះត្រូវផ្អែកតាមផែនទីគម្រោងនៅក្នុងទម្រង់ព័ត៌មានគម្រោង។ ជាដំបូងផែនទីបរិស្ថានត្រូវគូសលើក្រដាសផ្ទាំងធំដើម្បីឱ្យប្រជាពលរដ្ឋមូលដ្ឋានអាចមើលឃើញនិងចូលរួមយោបល់។ បន្ទាប់មកមន្ត្រីទទួលបន្ទុកត្រូវចម្លងផែនទីនេះលើក្រដាសខ្នាតតូច(ក្រដាសអា៤) សម្រាប់ធ្វើរបាយការណ៍នៅពេលក្រោយ។

ព័ត៌មានសំខាន់ៗ ដែលត្រូវបង្ហាញនៅលើផែនទីរួមមាន ៖

១. ឋានលេខា ៖ ទីចំណោតទីជម្រាលឬផ្ទៃដីរាបស្មើ

២. ប្រភេទដី ៖ ការហូរច្រោះខ្លាំងការហូរច្រោះតិចតួច និងមិនមានការហូរច្រោះ

៣. គម្របរុក្ខជាតិ និងការប្រើប្រាស់ដី ពិសេសតំបន់ព្រៃឈើនិងតំបន់ដីសើម

៤. ទីតាំងវប្បធម៌សំខាន់ៗ

៥. ផ្លូវអាចចូលដល់ទីតាំងគម្រោង

៦. ប្រភពទឹក

៧. ទំហំ(កម្រិត) នៃទឹកជំនន់តាមរដូវ

៨. តំបន់លំនៅស្ថាន និងប្រភពទឹកប្រើប្រាស់

៩. តំបន់ការពារដែលកំណត់ដោយថ្នាក់ជាតិ និងថ្នាក់ខេត្ត

១០. តំបន់ជីវៈចម្រុះដែលកំណត់ដោយក្រសួងបរិស្ថាន

១១. តំបន់ជនជាតិដើមភាគតិចរស់នៅ

១២. ទីតាំងអគាររដ្ឋបាល ជាដើម។

**ការប្រើប្រាស់និមិត្តសញ្ញានៅក្នុងផែនទី**

| និមិត្តសញ្ញា | អត្ថន័យ |
|---|---|
| ⇨ | ចំណោត (ច្រើនជាង៥%) សញ្ញាព្រួញចុះពីទីខ្ពស់ |
| → | ជម្រាល (តិចជាង៥%) សញ្ញាព្រួញចុះពីទីខ្ពស់ |
|  | អាចមានការហូរច្រោះដីខ្ពស់ ៖ ហូរនាំដីល្បាប់ម៉ដ្ឋ ឬដីឥដ្ឋ |
|  | វាលស្រែ |
| ✓ ✓ ✓<br>✓ ✓ ✓ | វាលសម្រាប់ដំណាំប្រចាំឆ្នាំ |
| ♀ ♀ ♀<br>♀ ♀ ♀ | ដំណាំឈើហូបផ្លែ |
| ॥ ॥ ॥<br>॥ ॥ ॥ | វាលស្មៅ |
|  | ព្រៃដែលមានដើមឈើតូចៗ |

| និមិត្តសញ្ញា | អត្ថន័យ |
|---|---|
|  | ព្រៃដែលមានដើមឈើធំៗ |
|  | ទីតាំងផ្ទះ។ ចូរពិពណ៌នាអំពីប្រភេទទឹកប្រើប្រាស់ |
|  | មានទឹកពេញ១ឆ្នាំ |
|  | មិនមានទឹកពេញ១ឆ្នាំទេ |
|  | ទីតាំងវប្បធម៌ |
|  | ផ្លូវអាចចូលដល់ទីតាំងការដ្ឋាន ឬគម្រោង |
|  | តំបន់ការពារដែលកំណត់ដោយថ្នាក់ជាតិនិងថ្នាក់ខេត្ត |
|  | តំបន់ជីវៈចម្រុះដែលកំណត់ដោយក្រសួងបរិស្ថាន |
|  | តំបន់ជនជាតិដើមភាគតិចរស់នៅ |

### ៣.២.៣. រៀបចំបញ្ជីវិភាគផលប៉ះពាល់បរិស្ថាន

បញ្ជីវិភាគផលប៉ះពាល់បរិស្ថានគឺជាបញ្ជីសម្រាប់ធ្វើការវិភាគអំពីផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីការអនុវត្តគម្រោងក្រុង ស្រុក។ បញ្ជីវិភាគផលប៉ះពាល់បរិស្ថានចែកជាពីរផ្នែក គឺផលប៉ះពាល់បរិស្ថានរយៈពេលវែងនិងផលប៉ះពាល់បរិស្ថានរយៈពេលខ្លី។

ចំពោះបញ្ហានីមួយៗនៅក្នុងបញ្ជីនេះ មន្ត្រីទទួលបន្ទុកត្រូវពន្យល់អត្ថន័យ និងឯកភាពជាមួយប្រជាពលរដ្ឋមូលដ្ឋានប្រសិនបើបញ្ហានេះអាចនឹងកើតមានឡើង។ ចំពោះបញ្ហានីមួយៗនៅក្នុងបញ្ជី មន្ត្រីទទួលបន្ទុកត្រូវគូសសម្គាល់ដូចជា **"ផលប៉ះពាល់ធំ" "ផលប៉ះពាល់មធ្យម" ឬ "ផលប៉ះពាល់តិចតួចឬគ្មាន"**។ ផលប៉ះពាល់ធំនិងផលប៉ះពាល់មធ្យមមានន័យថា បញ្ហាគឺធំគ្រប់គ្រាន់ល្មមដែលគម្រោងមួយចំនួនត្រូវតែធ្វើការផ្លាស់ប្តូរដើម្បីដោះស្រាយបញ្ហា។ ដូច្នេះ ត្រូវគូសសម្គាល់កន្លែងនោះនៅលើផែនទី។ កន្លែងនីមួយៗត្រូវគូសសម្គាល់ជាអក្សរ។

**ឧទាហរណ៍ ៖** ការខូចខាតបណ្តាលមកពីប្រើប្រាស់ថ្នាំពុលគីមីកសិកម្មនៅកន្លែង "ក" និងកន្លែង "ខ" ។ សរសេរ "ក" "ខ" នៅក្នុងកូឡោននៃទម្រង់ព័ត៌មានហើយគូសសម្គាល់កន្លែង "ក" និង "ខ" លើផែនទីនោះ។

នៅក្នុងពេលធ្វើការវិភាគផលប៉ះពាល់បរិស្ថាន មន្ត្រីទទួលបន្ទុក និងប្រជាពលរដ្ឋត្រូវពិចារណានិងវិនិច្ឆ័យអំពីទំហំនៃផលប៉ះពាល់ទៅលើបរិស្ថាន។

ប្រសិនបើការអនុវត្តផ្តល់នូវផលប៉ះពាល់បរិស្ថានធំ គម្រោងនោះទាមទារឱ្យធ្វើការពិចារណាឡើងវិញថាតើត្រូវលុបគម្រោងនោះចោល ឬយ៉ាងហោចណាស់ត្រូវកែសម្រួលគម្រោងនោះឡើងវិញ។

ប្រសិនបើការអនុវត្តផ្តល់នូវផលប៉ះពាល់បរិស្ថានមធ្យមគម្រោងនេះអាចដោះស្រាយបានដោយត្រូវធ្វើការកែសម្រួលលក្ខណៈបច្ចេកទេសរបស់គម្រោង និងឬចាត់វិធានការការពារផ្សេងៗនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។ ប្រសិនបើការអនុវត្តផ្តល់នូវផលប៉ះពាល់បរិស្ថានតិចតួច គម្រោងនេះអាចអនុវត្តបានដោយគ្រាន់តែ

កំណត់បណ្តាសកម្មភាពគ្រប់គ្រងបរិស្ថាននៅក្នុងផែនការការងាររបស់អ្នកផ្តល់សេវាកម្ម និងផែនការគ្រប់គ្រងបរិស្ថាន។

ជាទូទៅគម្រោងសេវាកម្ម និងឬគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចកម្រនឹងបណ្តាលឱ្យមានផលប៉ះពាល់ធំ និងរយៈពេលវែងណាស់ ប៉ុន្តែអាចបណ្តាលឱ្យផលប៉ះពាល់មធ្យម ឬតិចតួច ក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ លើសពីនេះទៀតគម្រោងសេវាកម្មរបស់រដ្ឋបាលក្រុង ស្រុកភាគច្រើនអាចមានផលប៉ះពាល់ជាវិជ្ជមានជាច្រើនទៅលើបរិស្ថាន។ លើសពីនេះទៀត ទម្រង់ព័ត៌មានគម្រោងមានកន្លែងសម្រាប់សរសេរបំពេញអំពីផលប៉ះពាល់វិជ្ជមានលើបរិស្ថានមួយចំនួនដែលរំពឹងទុកពីគម្រោង។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវពិចារណា និងវិនិច្ឆ័យអំពីផលប៉ះពាល់បរិស្ថានរយៈពេលវែង ឬរយៈពេលខ្លី ដោយផ្អែកតាមលក្ខខណ្ឌនានាមួយចំនួនដូចខាងក្រោម៖

**ក). ផលប៉ះពាល់បរិស្ថានរយៈពេលវែង**

- ការគំរាមកំហែងដែលបណ្តាលឱ្យអន្តរាយដល់ការរស់នៅរបស់សត្វព្រៃ ដែលរស់នៅក្នុងតំបន់នោះ។ បើគម្រោងគំរាមកំហែងដោយផ្ទាល់ដល់ការរស់នៅរបស់សត្វ ដែលស្ថិតនៅក្នុងបញ្ជីប្រភេទសត្វងាយបាត់បង់ ឬងាយផុតពូជផលប៉ះពាល់នេះ គឺជាផលប៉ះពាល់ធំដែលចាំបាច់ត្រូវលុបគម្រោងនោះចោល ឬរៀបចំគ្រោងការគម្រោងឡើងវិញ។
- ការធ្វើឱ្យខូចខាតដល់មច្ឆជាតិ ឬជម្រកមច្ឆជាតិ។ បើគម្រោងគំរាមកំហែងដល់ការរស់នៅនៃប្រភេទពូជត្រីធ្ងន់ធ្ងរ ឬធ្វើឱ្យអន្តរាយធ្ងន់ធ្ងរដល់តំបន់ត្រីពង-កូន ផលប៉ះពាល់នេះគឺជាផលប៉ះពាល់ធំដែលត្រូវតែជៀសវាងជាដាច់ខាត។ ប្រសិនបើការគំរាមកំហែងឬការអន្តរាយនេះមិនសូវធ្ងន់ធ្ងរ ផលប៉ះពាល់នេះ គឺជាផលប៉ះពាល់មធ្យម។ ក្នុងករណីនេះអាចដោះស្រាយបានដោយចាត់វិធានការនានាតាមរយៈការរៀបចំផែនការគ្រប់គ្រងបរិស្ថាន។ **ឧទាហរណ៍ ៖** គម្រោងវារីវប្បកម្មដោយប្រើពូជត្រីនាំចូលផ្សេងៗនៅក្បែរ ឬនៅក្នុងបឹងធម្មជាតិ ពីព្រោះពូជត្រីនាំចូលនេះអាចចូលទៅក្នុងបឹងធម្មជាតិ ហើយបំផ្លាញដល់ពូជត្រីធម្មជាតិ។
- ការធ្វើឱ្យខូចខាតដល់ព្រៃឈើ(ជាពិសេសនៅតំបន់ជីវៈចម្រុះ)។ ប្រសិនបើ គម្រោងបណ្តាលឱ្យកើនឡើងនូវការកាប់បំផ្លាញព្រៃឈើ ឬកើនឡើងនូវការប្រើប្រាស់ផលិតផលព្រៃឈើ ដូចជាបង្កើននូវការផលិតធ្យូង ឬកាប់អុស។ ផលប៉ះពាល់នេះ គឺជាផលប៉ះពាល់ធំដែលត្រូវតែជៀសវាងជាដាច់ខាត។
- ការប៉ះពាល់ខូចខាតដល់និរន្តរភាពនៃតំបន់ដីសើម ឬប្រភពទឹកនានា (ជាពិសេសនៅក្នុងតំបន់ជីវៈចម្រុះ ឬតំបន់ការពារ)។
- ការខូចខាតរយៈពេលយូរអង្វែងទៅលើដីកសិកម្ម។ ប្រសិនបើគម្រោងបណ្តាលឱ្យចុះថយនូវជីជាតិដីធ្លាក់ចុះនៃគុណភាពដី ផលប៉ះពាល់នេះ គឺជាផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យម អាស្រ័យទៅនឹងកម្រិត និងទំហំនៃផលប៉ះពាល់ទៅលើតំបន់ដែលទទួលរងនូវផលប៉ះពាល់នោះ។
- ការហូរច្រោះដែលបណ្តាលមកពីការធ្វើឱ្យបាត់បង់គម្របរុក្ខជាតិ។ ជាទូទៅការហូរច្រោះដែលបណ្តាលមកពីការធ្វើឱ្យបាត់បង់គម្របរុក្ខជាតិត្រូវបានចាត់ទុកថាជាផលប៉ះពាល់កម្រិតតិចតួចទៅមធ្យម ដែលអាចដោះស្រាយបាន តាមរយៈរៀបចំគំនូសប្លង់ឡើងវិញ ឬវិធានការសាមញ្ញៗនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដូចជា ការដាំស្មៅការដាំដើមឈើឡើងវិញ។ល។
- ការខូចខាតដល់គុណភាពទឹកដោយសារសារធាតុគីមី។ រាល់គម្រោងដែលលើកទឹកចិត្តឱ្យកសិករប្រើប្រាស់ជីគីមី និងបង្ហូរកាកសំណល់វារីពីស្រែរបស់ខ្លួនទៅក្នុងស្ទឹង ឬបឹងធម្មជាតិនានា ដែលជាប្រភពទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋ គម្រោងទាំងនោះត្រូវបានចាត់ទុកថាផ្តល់ផលប៉ះពាល់ធំដែលត្រូវតែជៀសវាង។

- ការខូចខាតដល់ទីតាំងវប្បធម៌ ឬទីសក្ការៈ។ គម្រោងដែលបណ្តាលឱ្យមានការខូចខាតដល់ទីតាំងវប្បធម៌ ឬទីសក្ការៈនានា ឬបណ្តាលឱ្យខូចខាតដល់បរិស្ថានជុំវិញ ឬបណ្តាលឱ្យប៉ះពាល់ដល់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋមូលដ្ឋាន គម្រោងទាំងនោះត្រូវចាត់ទុកថាមានផលប៉ះពាល់ធំ ហើយត្រូវជៀសវាង។
- ការប៉ះពាល់ដល់ជីវភាពរស់នៅបរិស្ថានរស់នៅ ឬទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច។ គម្រោងដែលបណ្តាលឱ្យប៉ះពាល់ដល់ជីវភាពរស់នៅបរិស្ថានរស់នៅ ឬទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច ឬគម្រោងដែលបណ្តាលឱ្យជនជាតិដើមភាគតិចផ្លាស់ប្តូរទីតាំងរស់នៅ គម្រោងទាំងនោះត្រូវចាត់ទុកថាមានផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យម។

**ខ). ផលប៉ះពាល់បរិស្ថានរយៈពេលខ្លី**

- ផលប៉ះពាល់បរិស្ថានរយៈពេលខ្លី គឺជាផលប៉ះពាល់ដែលកើតមានឡើងនៅក្នុងអំឡុងពេលអនុវត្តគម្រោង។
- ផលប៉ះពាល់បរិស្ថានរយៈពេលខ្លីភាគច្រើនអាចត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈការអនុវត្តសកម្មភាពគ្រប់គ្រងបរិស្ថាន ដែលបានកំណត់នៅក្នុងផែនការងាររបស់អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញ និងផែនការគ្រប់គ្រងបរិស្ថាន។

### ៣.២.៤. អនុសាសន៍

នៅផ្នែកចុងក្រោយនៃទម្រង់ព័ត៌មាន គឺជាកន្លែងសម្រាប់មន្ត្រីទទួលបន្ទុកក្នុងការវិភាគ ដើម្បីសង្ខេបអំពីការរកឃើញ និងអនុសាសន៍របស់ខ្លួន។ មន្ត្រីទទួលបន្ទុកអាចផ្តល់អនុសាសន៍ដោយពិចារណាលើជម្រើសណាមួយនៃអនុសាសន៍មួយចំនួន ដូចខាងក្រោម ៖

- ប្រសិនបើ គម្រោងត្រូវបានអនុវត្តតាមគ្រោងការ គម្រោងនឹងមិនមានផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យមណាមួយទៅលើបរិស្ថាន ដែលមិនអាចទទួលយកបាននោះទេ
- គម្រោងនឹងមានផលប៉ះពាល់មធ្យម ប៉ុន្តែផលប៉ះពាល់មធ្យមនេះអាចត្រូវបានកាត់បន្ថយ តាមរយៈការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ឬ
- គ្រោងការគម្រោងត្រូវបានផ្លាស់ប្តូរ ដើម្បីជៀសវាងផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យមទៅលើបរិស្ថានដែលមិនអាចទទួលយកបាន ឬ
- គម្រោងមិនអាចអនុវត្តបានទេ ពីព្រោះផលប៉ះពាល់ទៅលើបរិស្ថានមានទំហំធំជាងផលប្រយោជន៍ដែលទទួលបានពីគម្រោង។

### ៣.២.៥. ផែនការគ្រប់គ្រងផលប៉ះពាល់បរិស្ថាន

ផែនការគ្រប់គ្រងផលប៉ះពាល់បរិស្ថានបង្ហាញអំពីអ្វីដែលត្រូវធ្វើការផ្លាស់ប្តូរ ចំពោះគម្រោងសេវាកម្មទៅតាមអនុសាសន៍ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ទាំងនោះ។

រាល់បញ្ហាទាំងអស់ដែលបានបង្ហាញថាមានផលប៉ះពាល់ធំ ត្រូវតែបញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។ អនុសាសន៍នានាត្រូវបានចែកចេញជា ៖

- ការផ្លាស់ប្តូរលក្ខណៈបច្ចេកទេសនៅក្នុងគ្រោងការគម្រោង (ឧទាហរណ៍ការផ្លាស់ប្តូរពីការធ្វើពិសោធដោយប្រើប្រាស់ថ្នាំពុលគីមី និងជីគីមីទៅជាការប្រើប្រាស់ថ្នាំពុលធម្មជាតិ និងជីធម្មជាតិ)

- ការផ្លាស់ប្តូរដើម្បីធានានិរន្តរភាពនៃគម្រោង (ឧទាហរណ៍ ការផ្លាស់ប្តូរពីការបណ្តុះបណ្តាលតែវិជ្ជាជីវៈក្នុងការផលិតផលិតផលអំពីវល្លិ៍ ទៅជាការបណ្តុះបណ្តាលវិជ្ជាជីវៈការចងក្រងសហគមន៍ផលិតផលិតផលអំពីវល្លិ៍ និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព)
- ការផ្លាស់ប្តូរមធ្យោបាយក្នុងការប្រតិបត្តិ និងថែទាំគម្រោង (ឧទាហរណ៍៖ការផ្លាស់ប្តូរពីទិញពូជពីខាងក្រៅទៅជាការបន្សុទ្ធពូជដោយខ្លួនឯង)។

ការផ្លាស់ប្តូរមធ្យោបាយក្នុងការអនុវត្តគម្រោងត្រូវបញ្ចូលទៅក្នុងផែនការការងាររបស់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មនៅមុនពេលដែលអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មចាប់ផ្តើមអនុវត្តគម្រោង។ ចំពោះការប៉ាន់ស្មានតម្លៃសម្រាប់ការអនុវត្ត និងប្រតិបត្តិការគម្រោងត្រូវធ្វើឡើងទៅតាមអនុសាសន៍នីមួយៗ។ អ្នកទទួលខុសត្រូវក្នុងការអនុវត្តអនុសាសន៍ត្រូវកត់ត្រាជាលាយល័ក្ខណ៍អក្សរ។ ចំពោះបញ្ហានីមួយៗត្រូវកត់ត្រាទុកថាតើបញ្ហាទាំងនោះកើតឡើងធ្ងន់ធ្ងរប៉ុណ្ណា ប្រសិនបើ មិនអនុវត្តទៅតាមអនុសាសន៍នោះ(ផលប៉ះពាល់ធំមធ្យមនិងតិចតួច ឬគ្មាន) និងត្រូវកត់ត្រាយោបល់ផ្សេងៗទៀត ប្រសិនបើមាន។

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវធ្វើការពិភាក្សាជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលទទួលរងនូវផលប៉ះពាល់ផ្ទាល់ពីគម្រោង។

### ៣.២.៦. ការតាមដានផលប៉ះពាល់បរិស្ថាន

នៅផ្នែកចុងក្រោយនៃរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន គឺជាផែនការតាមដានផលប៉ះពាល់បរិស្ថាន។ ការតាមដានមាន២ប្រភេទ ដែលយើងអាចធ្វើទៅបាន ៖

- តាមដានជាមួយម្ចាស់គម្រោងនិងអ្នកផ្តល់សេវាកម្មទៅតាមអនុសាសន៍នៃរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន។
- តាមដានអំពីផលប៉ះពាល់ជាក់ស្តែងទៅលើបរិស្ថាន។

មន្ត្រីទទួលបន្ទុកក្នុងការវិភាគផលប៉ះពាល់បរិស្ថាន ត្រូវតាមដានការអនុវត្តអនុសាសន៍ពីការវិភាគផលប៉ះពាល់នានា ហើយត្រូវធ្វើរបាយការណ៍ទាំងនោះជូនដល់រដ្ឋបាលក្រុង ស្រុក។

មន្ត្រីទទួលបន្ទុកត្រូវរៀបចំផែនការតាមដានផលប៉ះពាល់បរិស្ថាន។ ផែនការតាមដានបង្ហាញអំពីរបៀបដែលត្រូវធ្វើការតាមដាន ដូចជា ៖

- **អ្វីខ្លះ?** តើត្រូវតាមដានទៅលើអ្វីខ្លះ? (ឧទាហរណ៍"ប្រភេទពូជត្រី" "គុណភាពទឹក"។ល។)។
- **កន្លែងណា?** តើត្រូវតាមដាននៅកន្លែងណា?
- **របៀបណា?** តើត្រូវតាមដានរបៀបណា? ចំពោះប្រភេទបញ្ហាមួយចំនួនអាចធ្វើការវាស់វែងជាក់ស្តែងបាន (ឧទាហរណ៍៖ការចុះពិនិត្យមើលអំពីការប្រមូលអនុផលព្រៃឈើការធ្វើតេស្តគុណភាពទឹកដោយប្រើឧបករណ៍)។ ទោះបីជាយ៉ាងណាក៏ដោយមន្ត្រីទទួលបន្ទុកអាចមានរបៀបផ្សេងទៀត ដូចជា តាមរយៈ ការសួរប្រជាពលរដ្ឋ ការសង្កេត ឬការពិនិត្យផែនការសកម្មភាពរបស់អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញជាដើម។
- **នៅពេលណា?** តើត្រូវតាមដាននៅពេលណា? (ឧទាហរណ៍ "តាមដានម្តងក្នុង១ខែ" "តាមដានរៀងរាល់ថ្ងៃក្នុងអំឡុងពេលអនុវត្តគម្រោង" ។ល។)។
- **នរណា?** តើនរណាជាអ្នកតាមដាន? តើនរណាជាអ្នកទទួលខុសត្រូវលើការអនុវត្តការងារ?

### ៣.២.៧. ការរៀបចំបញ្ចប់របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន

បន្ទាប់ពីសិក្សា និងវិភាគផលប៉ះពាល់បរិស្ថានរបស់គម្រោងសេវាកម្មរួចមក មន្ត្រីទទួលបន្ទុកត្រូវរៀបចំ និងបំពេញទម្រង់មួយចំនួនដូចខាងក្រោម ៖

- របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន (ទម្រង់ទី៤)
- បញ្ជីវិភាគផលប៉ះពាល់បរិស្ថាន (ទម្រង់ទី៥)
- ផែនការគ្រប់គ្រងបរិស្ថាន (ទម្រង់ទី៦)
- ផែនការតាមដានផលប៉ះពាល់បរិស្ថាន (ទម្រង់ទី៧)
- បញ្ជីឈ្មោះអ្នកចូលរួមក្នុងការវិភាគផលប៉ះពាល់បរិស្ថាន (ទម្រង់ទី៨)
- ផែនទីបរិស្ថាន

បន្ទាប់ពីរៀបចំរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានចប់សព្វគ្រប់ គណៈកម្មការគ្រប់គ្រងគម្រោងសេវាកម្ម និងមន្ត្រីទទួលបន្ទុកត្រូវដាក់ជូនរបាយការណ៍នេះជូនទៅគណៈអភិបាលក្រុង ស្រុក។ គណៈអភិបាលក្រុង ស្រុកត្រូវផ្ញើរបាយការណ៍នេះទៅទីចាត់ការផែនការ និងវិនិយោគខេត្ត។ ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវផ្ញើរបាយការណ៍នេះទៅមន្ទីរបរិស្ថានខេត្ត និងឬស្ថាប័នពាក់ព័ន្ធនានា ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។

**បញ្ជាក់** ÷ ជាទូទៅគម្រោងសេវាកម្មមិនសូវបង្កផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចទេ ពិសេសផលប៉ះពាល់ផ្នែកដីធ្លី និងជនជាតិដើមភាគតិច ទោះបីជាគម្រោងនោះស្ថិតនៅក្នុងឃុំ សង្កាត់នៃបញ្ជីតំបន់ងាយរងផលប៉ះពាល់បរិស្ថាន និងបញ្ជីតំបន់ជនជាតិដើមភាគតិចក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានគម្រោងមួយចំនួនដែលស្ថិតនៅក្នុងឃុំ សង្កាត់នៃបញ្ជីតំបន់ងាយរងផលប៉ះពាល់បរិស្ថាន ដែលត្រូវសិក្សាផលប៉ះពាល់បរិស្ថាន ហើយក៏ត្រូវបញ្ជូនមកក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យ និងផ្តល់យោបល់។ គម្រោងទាំងនេះ គឺជាគម្រោងសេវាកម្មដែល ៖

- នឹងបង្កផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាន
- ពាក់ព័ន្ធនឹងការគ្រប់គ្រង និងកែច្នៃសំណល់ឬសំរាម
- មានលក្ខណៈប្រមូលផ្តុំ ឬបម្រើផលប្រយោជន៍ជាសមូលហភាព

## ឧបសម្ព័ន្ធទី៤ ÷ របាយការណ៍ស្តីពីការវិភាគផលប៉ះពាល់បរិស្ថាន

| របាយការណ៍ស្តីពីការវិភាគផលប៉ះពាល់បរិស្ថាន | | |
|---|---|---|
| ខេត្ត ៖ | ក្រុង ស្រុក ៖ | លេខកូដក្រុង ស្រុក ៖ |
| ឈ្មោះគម្រោង ៖ | | |
| កាលបរិច្ឆេទនៃការវិភាគបរិស្ថានដោយមានការចូលរួម | ឈ្មោះមន្ត្រីទទួលបន្ទុកក្នុងការវិភាគបរិស្ថាន | |
| ទីកន្លែងធ្វើការវិភាគបរិស្ថាន | ចំនួនប្រជាពលរដ្ឋដែលបានចូលរួមវិភាគបរិស្ថាន | |

**១. មូលហេតុនៃការវិភាគផលប៉ះពាល់បរិស្ថាន** (អាចច្រើនជាងមួយ)

| | |
|---|---|
| គម្រោងសេវាកម្ម ដែលនឹងបង្កផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាន | |
| គម្រោងសេវាកម្មដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងកែច្នៃសំណល់ ឬសំរាម | |
| គម្រោងសេវាកម្មដែលមានលក្ខណៈប្រមូលផ្តុំ ឬបម្រើផលប្រយោជន៍ជាសមូលហភាព | |
| | |

**២. អនុសាសន៍**

| ល.រ | ការពិពណ៌នា | ជ្រើសយកចម្លើយ១ |
|---|---|---|
| ១ | បើគម្រោងត្រូវបានអនុវត្តតាមគ្រោងការគម្រោង គម្រោងនឹងមិនមានផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យមណាមួយទៅលើបរិស្ថានដែលមិនអាចទទួលយកបាននោះទេ។ | |
| ២ | គម្រោងនឹងមានផលប៉ះពាល់មធ្យម ប៉ុន្តែផលប៉ះពាល់មធ្យមនេះអាចត្រូវបានកាត់បន្ថយតាមរយៈការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន។ | |
| ៣ | គ្រោងការគម្រោងត្រូវបានផ្លាស់ប្តូរដើម្បីជៀសវាងផលប៉ះពាល់ធំ ឬផលប៉ះពាល់មធ្យមទៅលើបរិស្ថានដែលមិនអាចទទួលយកបាន។ | |
| ៤ | គម្រោងមិនអាចអនុវត្តបានទេ ពីព្រោះផលប៉ះពាល់ទៅលើបរិស្ថានមានទំហំធំជាងផលប្រយោជន៍ដែលទទួលបានពីគម្រោង។ | |

**ឯកសារឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ៖**

– ផែនទីបរិស្ថាន
– បញ្ជីវិភាគផលប៉ះពាល់បរិស្ថាន
– ផែនការគ្រប់គ្រងបរិស្ថាន
– ផែនការតាមដានបរិស្ថាន
– បញ្ជីឈ្មោះអ្នកចូលរួមវិភាគផលប៉ះពាល់បរិស្ថាន
– កំណត់ហេតុប្រជុំវិភាគផលប៉ះពាល់បរិស្ថាន

ថ្ងៃទី........ ខែ........... ឆ្នាំ.........  ថ្ងៃទី........ ខែ........... ឆ្នាំ.........

**អភិបាលក្រុង ស្រុក**  **មន្ត្រីទទួលបន្ទុក**

## ឧបសម្ព័ន្ធទី៥ ៖ បញ្ជីវិភាគផលប៉ះពាល់បរិស្ថាន

| ខេត្ត ៖ | ក្រុង ស្រុក ៖ | លេខកូដក្រុង ស្រុក ៖ |
|---|---|---|
| ឈ្មោះគម្រោង ៖ | | |

**១. ផលប៉ះពាល់បរិស្ថានរយៈពេលវែង**

| បញ្ហា | កម្រិត | | ទីកន្លែងក្នុងផែនទី |
|---|---|---|---|
| ការគំរាមកំហែងដល់ការអន្តរាយដល់ការរស់នៅរបស់សត្វព្រៃដែលងាយនឹងបាត់បង់ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ការធ្វើឱ្យខូចខាតដល់មច្ឆជាតិ ឬជម្រកមច្ឆជាតិ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ការធ្វើឱ្យខូចខាតដល់ព្រៃឈើ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ការប៉ះពាល់ខូចខាតដល់និរន្តរភាពនៃតំបន់ដីសើមឬប្រភពទឹក | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ការខូចខាតរយៈពេលវែងទៅលើដីកសិកម្ម | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ការហូរច្រោះដែលបណ្តាលមកពីផ្លាស់ប្តូរចរន្តទឹក និងការពង្រីកទំហំព្រែក ឬអូរ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ការហូរច្រោះដែលបណ្តាលមកពីការធ្វើឱ្យបាត់បង់គម្របរុក្ខជាតិ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ការខូចខាតដល់គុណភាពទឹកដោយសារសារធាតុគីមី | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ផលប៉ះពាល់រយៈពេលវែងដែលបណ្តាលមកពីធូលីហុយសំឡេងនិងបញ្ហាសុវត្ថិភាព | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |

| បញ្ហា | កម្រិត | | ទីកន្លែងក្នុងផែនទី |
|---|---|---|---|
| ការខូចខាតដល់ទីតាំងវប្បធម៌ឬទីសក្ការៈ | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ការប៉ះពាល់ដល់ជីវភាពរស់នៅ បរិស្ថានរស់នៅ ឬទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ផលប៉ះពាល់ផ្សេងទៀត (សូមបញ្ជាក់) | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ផលប៉ះពាល់ផ្សេងទៀត (សូមបញ្ជាក់) | ផលប៉ះពាល់ធំ | | |
| | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |

**២. ផលប៉ះពាល់បរិស្ថានរយៈពេលខ្លី**

| បញ្ហា | កម្រិត | | ទីកន្លែងក្នុងផែនទី |
|---|---|---|---|
| ការខូចខាតដល់ច្បារដំណាំ ឬឈើហូបផ្លែរបស់ប្រជាពលរដ្ឋ | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ការខូចខាតដល់ដីកសិកម្មរយៈពេលខ្លី | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ការខូចខាតដល់ទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋ | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ផលប៉ះពាល់ផ្សេងទៀត (សូមបញ្ជាក់) | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |
| ផលប៉ះពាល់ផ្សេងទៀត (សូមបញ្ជាក់) | ផលប៉ះពាល់មធ្យម | | |
| | ផលប៉ះពាល់តិចឬគ្មាន | | |

| |
|---|
| ចូររៀបរាប់ថាតើគម្រោងមានផលប៉ះពាល់ល្អទៅលើបរិស្ថានអ្វីខ្លះ ? |

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**អភិបាលក្រុង ស្រុក**

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**មន្ត្រីទទួលបន្ទុក**

## ទម្រង់ទី៦ ÷ ផែនការគ្រប់គ្រងបរិស្ថាន

| | | | |
|---|---|---|---|
| ខេត្ត ៖ | ក្រុង ស្រុក ៖ | លេខកូដក្រុង ស្រុក ៖ | ឈ្មោះគម្រោង ៖ |

| បញ្ហា | វិធានការបន្ធូរបន្ថយ | ការចំណាយ | | អ្នកណាទទួលខុសត្រូវ | | ផលប៉ះពាល់នៅសល់បន្ទាប់ពីបន្ធូរបន្ថយ(ធំ មធ្យម គ្មាន) | អាទិភាព (ខ្ពស់ មធ្យម ទាប) | យោបល់ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ស្ថាបនា | ការប្រើប្រាស់ | ស្ថាបនា | ការប្រើប្រាស់ | | | |
| ១. អនុសាសន៍នៃការផ្លាស់ប្តូរគ្រោងការគម្រោង | | | | | | | | |
| | | | | | | | | |
| ២. អនុសាសន៍នៃការផ្លាស់ប្តូរមធ្យោបាយក្នុងការអនុវត្តគម្រោង | | | | | | | | |
| | | | | | | | | |
| ៣. អនុសាសន៍នៃការផ្លាស់ប្តូរមធ្យោបាយនៅក្នុងការប្រើប្រាស់ ឬការថែទាំគម្រោង | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**អភិបាលក្រុង ស្រុក**

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**មន្ត្រីទទួលបន្ទុក**

**ទម្រង់ទី៧ ៖ ផែនការតាមដានផលប៉ះពាល់បរិស្ថាន**

| ខេត្ត ៖ | ក្រុង ស្រុក ៖ | លេខកូដក្រុង ស្រុក ៖ | ឈ្មោះគម្រោង ៖ |
|---|---|---|---|

| **តើអ្វីខ្លះ?** | **តើនៅកន្លែងណា?** | **ដោយរបៀបណា?** | **នៅពេលណា?** | **ដោយអ្នកណា?** |
|---|---|---|---|---|
| តើអ្វីខ្លះដែលត្រូវធ្វើការតាមដាន ? | តើទីកន្លែងណាត្រូវតាមដាន ? | តើត្រូវតាមដានដោយរបៀបណា ? | តើពេលណាត្រូវធ្វើការតាមដាន ? | តើនរណាទទួលខុសត្រូវក្នុងការតាមដាន ? |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**អភិបាលក្រុង ស្រុក**

ថ្ងៃទី........ ខែ........... ឆ្នាំ.........

**មន្ត្រីទទួលបន្ទុក**

## ទម្រង់ទី៨ ៖ បញ្ជីឈ្មោះអ្នកចូលរួមក្នុងការវិភាគផលប៉ះពាល់បរិស្ថាន

ថ្ងៃទី......... ខែ............ ឆ្នាំ.........

| ល.រ | ឈ្មោះ | ភេទ | អាយុ | ភូមិ | ឃុំ សង្កាត់ | តួនាទី |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

### ៣.២.៨. ការពិនិត្យរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានដោយទីចាត់ការផែនការ និងវិនិយោគខេត្ត

ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវត្រួតពិនិត្យរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាននេះថាតើបានបំពេញត្រឹមត្រូវតាមគោលការណ៍ណែនាំដែរឬទេ។ ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវផ្ញើរបាយការណ៍នេះមួយច្បាប់ទៅមន្ទីរបរិស្ថាននិងស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។ ដំណើរការពិនិត្យបញ្ជាក់បច្ចេកទេសទៅលើរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានត្រូវបានអនុវត្តដូចគ្នានឹងទម្រង់ព័ត៌មានគម្រោងដែរ។ មន្ទីរបរិស្ថាន និងស្ថាប័នពាក់ព័ន្ធដែលមានតួនាទីពិនិត្យបញ្ជាក់បច្ចេកទេសមានសិទ្ធិជំទាស់នៅក្នុងអំឡុងពេល**១៥ថ្ងៃ**បន្ទាប់ពីទទួលបានរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន។

ប្រសិនបើ មន្ទីរបរិស្ថាន និងស្ថាប័នពាក់ព័ន្ធចង់ធ្វើការជំទាស់អ្វីមួយទៅលើរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន នោះមន្ទីរត្រូវផ្តល់ព័ត៌មានជាលាយល័ក្ខណ៍អក្សរទៅទីចាត់ការផែនការ និងវិនិយោគខេត្តវិញ ហើយទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវជូនដំណឹងដល់ក្រុង ស្រុកអំពីការជំទាស់នេះ។

ប្រសិនបើនៅក្នុងអំឡុងពេល១៥ថ្ងៃពុំមានការជំទាស់ទេ នោះមានន័យថារបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានត្រូវបានពិនិត្យបញ្ជាក់បច្ចេកទេសដោយមន្ទីរបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ រួចជាស្ថាពរ។ ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវជូនដំណឹងដល់ក្រុង ស្រុក ដើម្បីអាចចាប់ផ្តើមដំណើរការលទ្ធកម្មបាន។

ចំពោះគម្រោងនានាដែលទីតាំងនៃគម្រោងទាំងនោះស្ថិតនៅឃុំ សង្កាត់ដែលស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន ហើយជាគម្រោងដែលនឹងបង្កផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាន ឬគម្រោងដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងកែច្នៃសំណល់ ឬសំរាម ឬគម្រោងដែលមានលក្ខណៈប្រមូលផ្តុំ ឬបម្រើផលប្រយោជន៍ជាសមូលហភាព ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវផ្ញើរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសារឧបសម្ព័ន្ធនានានៃរបាយការណ៍នេះជាទម្រង់ឯកសារក្នុងកុំព្យូទ័រ(Electronic File)ជូនក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋានគ.ជ.អ.ប ដើម្បីពិនិត្យជាមុន មុននឹងផ្ញើរបាយការណ៍វិភាគបរិស្ថាននេះទៅមន្ទីរបរិស្ថាន ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។ ក្រុមការងារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប មានរយៈពេល**១០ថ្ងៃធ្វើការ** ក្នុងការពិនិត្យបន្ទាប់ពីទទួលបានរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន។ ប្រសិនបើពិនិត្យទៅឃើញថាមានចំណុចខុសឆ្គង ឬខ្វះខាត ដែលត្រូវធ្វើការកែតម្រូវ ឬបំពេញបន្ថែម ក្រុមការងារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវជម្រាបទៅទីចាត់ការផែនការ និងវិនិយោគខេត្តវិញតាមរយៈអ៊ីម៉ែលក្នុងអំឡុងពេល១០ថ្ងៃធ្វើការ។ ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធដទៃទៀត មិនអាចផ្ញើទៅមន្ទីរជំនាញពាក់ព័ន្ធ ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេសបានទេ នៅមុនរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានត្រូវបានយល់ព្រមដោយក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប។

# ជំពូកទី៤

# ការរៀបចំផែនការគម្រោង

# សេវាកម្មក្នុង ស្រុក

# ជំពូកទី៤
# ការរៀបចំគ្រោងការគម្រោងសេវាកម្មក្រុង ស្រុក

បន្ទាប់ពីសិក្សាអំពីគម្រោង អ្នកជំនួយបច្ចេកទេសត្រូវជួយក្រុង ស្រុក ក្នុងការរៀបចំគ្រោងការគម្រោងសេវាកម្មក្រុង ស្រុក។ ការរៀបចំគ្រោងការគម្រោងសេវាកម្មក្រុង ស្រុក គឺជាការសិក្សានិងប្រមូលព័ត៌មានទាំងអស់ដែលត្រូវការដើម្បីរៀបចំឱ្យបាននូវគម្រោងសេវាកម្មមួយរបស់ក្រុង ស្រុក។

សកម្មភាពសំខាន់ៗនៃការរៀបចំគ្រោងការគម្រោងសេវាកម្មក្រុង ស្រុក រួមមាន ៖

- ការសិក្សា និងប្រមូលព័ត៌មានគម្រោង
- ការប៉ាន់ស្មានតម្លៃគម្រោង
- ផែនការប្រតិបត្តិ និងថែទាំ
- ការរៀបចំស្លាកសញ្ញាគម្រោង
- ការរៀបចំបញ្ចប់សេចក្តីព្រាងគ្រោងការគម្រោង

## ៤.១. ការសិក្សា និងប្រមូលព័ត៌មានគម្រោង

អ្នកជំនួយបច្ចេកទេសនឹងជួយគណៈកម្មការគ្រប់គ្រងគម្រោងក្នុងការចុះសិក្សាបច្ចេកទេសគម្រោងក្រុង ស្រុក នៅទីតាំងគម្រោងដោយមានការចូលរួមពីប្រជាពលរដ្ឋ ក្រុមអ្នកប្រើប្រាស់គម្រោងនិងអង្គការសហគមន៍មូលដ្ឋានក្នុងគោលបំណងប្រមូលព័ត៌មានសំខាន់ៗ និងចាំបាច់ដើម្បីបំពេញទម្រង់ព័ត៌មានគម្រោង(ទម្រង់ទី៨)។

អ្នកទទួលខុសត្រូវក្នុងការបំពេញទម្រង់ព័ត៌មានគម្រោងរួមមាន ៖

- គណៈកម្មការគ្រប់គ្រងគម្រោង ទទួលខុសត្រូវក្នុងការរៀបចំប្រមូលព័ត៌មានសម្រាប់បំពេញក្នុងទម្រង់ព័ត៌មានគម្រោង។
- អ្នកជំនួយបច្ចេកទេសត្រូវធានាថា ព័ត៌មានបច្ចេកទេសដែលបានបំពេញក្នុងទម្រង់ព័ត៌មានគម្រោងនិងឯកសារពាក់ព័ន្ធពិតជាត្រឹមត្រូវ។
- ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវពិនិត្យទៅលើភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃព័ត៌មាននានានៅក្នុងទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធ។

ជាធម្មតា គណៈកម្មការគ្រប់គ្រងគម្រោងត្រូវបំពេញទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធនៅផ្នែកដែលមិនទាក់ទងនឹងបច្ចេកទេស។ អ្នកជំនួយបច្ចេកទេសត្រូវបំពេញទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធនៅផ្នែកដែលទាក់ទងនឹងព័ត៌មានបច្ចេកទេស។ ទោះបីជាយ៉ាងណាក៏ដោយក្នុងនាមគណៈកម្មការគ្រប់គ្រងគម្រោង អភិបាលក្រុង ស្រុក ជាអ្នកទទួលខុសត្រូវទាំងស្រុងទៅលើខ្លឹមសារនានានៅក្នុងទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធមិនមែនទទួលខុសត្រូវ តែផ្នែកដែលខ្លួនបានបំពេញនោះទេ។

## ទម្រង់ទី៩ ÷ ទម្រង់ព័ត៌មានគម្រោងសេវាកម្ម

| ព័ត៌មានគម្រោងសេវាកម្ម | | |
|---|---|---|
| ខេត្ត ៖ | ក្រុង ស្រុក ៖ | លេខកូដក្រុង ស្រុក ៖ |

**ផ្នែកទី១ ÷ ព័ត៌មានទូទៅ**

| | | | |
|---|---|---|---|
| ឈ្មោះគម្រោង ៖ | | | |
| កាលបរិច្ឆេទបញ្ចប់ការសិក្សា ៖ | ឈ្មោះអ្នកជំនួយបច្ចេកទេស ៖ | ឋានៈអ្នកជំនួយបច្ចេកទេស ៖ | |
| ទិសដៅរបស់គម្រោង ៖ | | | |
| វិស័យ ឬផ្នែក ៖ | ប្រភេទគម្រោង ៖ | | |
| លទ្ធផលគ្រោង(ស្រង់ចេញពីកម្មវិធីវិនិយោគក្រុង ស្រុក) ៖ | លទ្ធផលគ្រោងក្រោយពីសិក្សា ៖ | | |
| តម្លៃប៉ាន់ស្មានក្នុងកម្មវិធីវិនិយោគ ៖ | តម្លៃប៉ាន់ស្មានក្រោយពីសិក្សា ៖ | | |
| ឆ្នាំ | ២០១៤ | ២០១៥ | ២០១៦ |
| លទ្ធផលតាមឆ្នាំ | | | |
| តម្លៃប៉ាន់ស្មានតាមឆ្នាំ | | | |

**អ្នកទទួលផលពីគម្រោង**

| ល.រ | ឈ្មោះភូមិ | ឈ្មោះឃុំ សង្កាត់ | ចំនួនអ្នកទទួលផល | | ចំនួនគ្រួសារ |
|---|---|---|---|---|---|
| | | | សរុប | ស្ត្រី | |
| ១ | | | | | |
| ២ | | | | | |
| សរុប | | | | | |

**ផ្នែកទី២ ÷ ការទទួលខុសត្រូវចំពោះការប្រើប្រាស់និងថែទាំ**

| តើអ្នកណាទទួលខុសត្រូវចំពោះការប្រើប្រាស់និងថែទាំលទ្ធផលគម្រោង? | |
|---|---|
| មន្ទីរ អង្គភាពជំនាញ | |
| រដ្ឋបាលក្រុង ស្រុក | |
| ក្រុមអ្នកប្រើប្រាស់ដែលមានស្រាប់ | |
| ក្រុមអ្នកប្រើប្រាស់ដែលត្រូវបង្កើតមុនពេលចាប់ផ្តើមអនុវត្តគម្រោង | |
| ផ្នែកឯកជន | |
| .......... | |

**ផ្នែកទី៣ ÷ ផលប៉ះពាល់បរិស្ថាន**

| | |
|---|---|
| ៣.១. | តើទីតាំងគម្រោងនេះស្ថិតនៅក្នុងឃុំសង្កាត់នៃបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថានដែរឬទេ?<br>បាទ ☐ ទេ☐ |

| | |
|---|---|
| ៣.២. | តើការអនុវត្តគម្រោងបណ្តាលឱ្យមានការប៉ះពាល់ខូចខាតដល់ទីកន្លែងណាមួយ ដែលមានសារៈសំខាន់ចំពោះបរិស្ថាន ឬទីតាំងវប្បធម៌ដែរឬទេ? (ឧទាហរណ៍ ៖ ព្រៃឈើឧទ្យានសត្វព្រៃឬប្រាសាទ) ..................................................................................................................... ..................................................................................................................... .....................................................................................................................។ |
| ៣.៣. | តើការអនុវត្តគម្រោងបណ្តាលឱ្យមានការប៉ះពាល់ខូចខាតដល់ប្រភពទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋដែរឬទេ? ..................................................................................................................... ..................................................................................................................... .....................................................................................................................។ |

**ផ្នែកទី៤ ÷ ការពិនិត្យឡើងវិញមុនចុះហត្ថលេខា**

| |
|---|
| ៤.១. តើមានហេតុផលណាដែលបណ្តាលឱ្យគម្រោងនេះមិនទទួលបានជោគជ័យដែរឬទេ?(ចម្លើយរបស់អ្នកជំនួយបច្ចេកទេស) |
| ៤.២. តើការសិក្សាព័ត៌មានគម្រោងត្រូវបានផ្តល់ទាំងអស់ដែរឬទេ? |

| លរ | ព័ត៌មាន | ពិនិត្យដោយគណៈកម្មការគ្រប់គ្រងគម្រោង | ពិនិត្យដោយទីចាត់ការផែនការ និងវិនិយោគ |
|---|---|---|---|
| ១ | ទិសដៅ | | |
| ២ | វិស័យ ឬផ្នែក | | |
| ៣ | ប្រភេទគម្រោង | | |
| ៤ | អ្នកទទួលផលពីគម្រោង | | |
| ៥ | ផែនទីគម្រោង | | |
| ៦ | ព័ត៌មានបច្ចេកទេស (អាស្រ័យនឹងប្រភេទគម្រោង) | | |
| ៧ | តម្លៃប៉ាន់ស្មានគម្រោងលម្អិត | | |
| ៨ | លទ្ធផលគម្រោងនិងតម្លៃប៉ាន់ស្មានគម្រោង | | |
| ៩ | ទីតាំងលទ្ធផលគម្រោង | | |
| ១០ | ផែនការប្រតិបត្តិ និងថែទាំ | | |
| ១១ | របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន | | |

ថ្ងៃទី......ខែ...........ឆ្នាំ......... ថ្ងៃទី......ខែ...........ឆ្នាំ......... ថ្ងៃទី......ខែ...........ឆ្នាំ.........

**ទីចាត់ការផែនការ និងវិនិយោគ** **អភិបាលក្រុង ស្រុក** **អ្នកជំនួយបច្ចេកទេស**

# របៀបបំពេញព័ត៌មានក្នុងតារាង ៩

| | |
|---|---|
| **ផ្នែកទី១ ៖ ព័ត៌មានទូទៅ** | |
| ១.១. ឈ្មោះគម្រោង | ព័ត៌មានស្រង់ចេញពីកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក |
| ១.២. កាលបរិច្ឆេទបញ្ចប់ការសិក្សា | កាលបរិច្ឆេទបញ្ចប់ការសិក្សាគម្រោង(ស្រង់កាលបរិច្ឆេទនៃការចុះហត្ថលេខារបស់អ្នកជំនួយបច្ចេកទេសលើទម្រង់ព័ត៌មានគម្រោង) |
| ១.៣. ឈ្មោះអ្នកជំនួយបច្ចេកទេស | ឈ្មោះអ្នកជំនួយបច្ចេកទេសដែលរដ្ឋបាលក្រុង ស្រុកបានតែងតាំង |
| ១.៤. ឋានៈអ្នកជំនួយបច្ចេកទេស | អាចជាមន្ត្រីរបស់សាលាក្រុង ស្រុក ខេត្ត មន្ទីរ ការិយាល័យ អង្គភាពជំនាញ ឬផ្នែកឯកជន ...។ល។ |
| ១ .៥.ទិសដៅគម្រោង | ទិសដៅជាក់លាក់របស់គម្រោងដែលត្រូវបង្កើតនៅពេលបំពេញទម្រង់ព័ត៌មានគម្រោង។ |
| ១.៦. វិស័យ ឬផ្នែក | ជាផ្នែកដែលមាននៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក(ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ចផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ និងផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ)។ |
| ១.៧. ប្រភេទគម្រោង | ជាប្រភេទគម្រោងដូចមាននៅក្នុងបញ្ជីវិស័យប្រភេទគម្រោងនិងមន្ទីរអង្គភាពពាក់ព័ន្ធដែលទទួលខុសត្រូវ។ |
| ១.៨. លទ្ធផលគ្រោងទុក | ត្រូវចម្លងទាំងស្រុងពីកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក។ |
| ១.៩. លទ្ធផលគ្រោងទុកក្រោយពីធ្វើការសិក្សា | ការសិក្សាគម្រោងអាចធ្វើការផ្លាស់ប្តូរលទ្ធផលដែលបានគ្រោងទុក។ |
| ១.១០. ការប៉ាន់ស្មានតម្លៃក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក | នេះគឺជាការប៉ាន់ស្មានតម្លៃគម្រោង ដូចបានបង្ហាញក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក។ |
| ១.១១. ការប៉ាន់ស្មានតម្លៃក្រោយការសិក្សាគម្រោង | នេះគឺជាការប៉ាន់ស្មានតម្លៃគម្រោងក្រោយពីអ្នកជំនួយបច្ចេកទេសបានសិក្សារៀបចំគំនូសប្លង់ តារាងលទ្ធផល និងប៉ាន់ស្មានតម្លៃរួច(ស្រង់ចេញពីតារាងទី ១០)។ |
| ១.១២. អ្នកទទួលផលពីគម្រោង | អ្នកទទួលផលផ្ទាល់ពីគម្រោង គឺប្រជាពលរដ្ឋមូលដ្ឋានដែលប្រើប្រាស់លទ្ធផលគម្រោង។ ចំនួនប្រជាពលរដ្ឋដែលជាអ្នកទទួលផលត្រូវបានចុះបញ្ជីតាមភូមិ និងឃុំ សង្កាត់នីមួយៗ ដោយមានបញ្ជាក់ច្បាស់លាស់នូវចំនួនស្ត្រី និងចំនួនគ្រួសារ។ |
| **ផ្នែកទី២ ៖ កិច្ចប្រតិបត្តិការ និងការថែទាំ** | |
| ២.១. ការទទួលខុសត្រូវក្នុងការប្រតិបត្តិ និងថែទាំ | ត្រូវបង្ហាញអ្នកដែលនឹងទទួលខុសត្រូវក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោង។ ជម្រើសអាចជា៖<br>• មន្ទីរ អង្គភាពជំនាញ (ឧទាហរណ៍៖ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម)<br>• រដ្ឋបាលក្រុង ស្រុក (ឧទាហរណ៍ ៖ ការផ្សព្វផ្សាយការចុះបញ្ជីអត្រានុកូលដ្ឋាន)<br>• ក្រុមអ្នកប្រើប្រាស់ដែលមានស្រាប់(ឧទាហរណ៍ ៖ សហគមន៍សន្សំប្រាក់)<br>• ក្រុមអ្នកប្រើប្រាស់ដែលត្រូវបង្កើត (ឧទាហរណ៍ ៖ សហគមន៍នេសាទ)<br>• ផ្នែកឯកជន (ឧទាហរណ៍៖ការបណ្តុះបណ្តាលជីវៈ)<br>• . . . ។ល។ |

| | | |
|---|---|---|
| **ផ្នែកទី៣ ៖ ផលប៉ះពាល់បរិស្ថាន** | | |
| ៣.១. | តើទីតាំងគម្រោងនេះស្ថិតនៅក្នុងឃុំដែលស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថានដែរឬទេ? | បញ្ជីនេះត្រូវបានដាក់ឱ្យប្រើប្រាស់ដោយ គ.ជ.អ.ប ដើម្បីជំរុញការយកចិត្តទុកដាក់ទៅលើតំបន់ដែលងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន។ |
| ៣.២. | តើការអនុវត្តគម្រោងនេះបណ្តាលឱ្យមានការខូចខាត ឬប៉ះពាល់ដល់កន្លែងមួយចំនួនដែលមានសារៈសំខាន់លើផ្នែកបរិស្ថាន ឬវប្បធម៌ដែរឬទេ? | ឧទាហរណ៍ ៖ ព្រៃឈើព្រៃលិចទឹកមច្ឆជាតិរុក្ខជាតិដុះក្នុងទឹកធនធានរ៉ែលើ និងក្រោមដីសួនសត្វ ឬប្រាង្គប្រាសាទ ទួលអ្នកតា ...។ល។ |
| ៣.៣. | តើការអនុវត្តគម្រោងនឹងបណ្តាលឱ្យមានការខូចខាត ឬប៉ះពាល់ដល់ប្រភពផ្គត់ផ្គង់ទឹកដែលប្រជាពលរដ្ឋកំពុងប្រើប្រាស់ដែរឬទេ? | ឧទាហរណ៍ ៖ គម្រោងប្រពលវប្បកម្មដំណាំស្រូវ ដែលស្ថិតនៅជិតអូរ ឬប្រឡាយដែលប្រជាពលរដ្ឋយកទឹកនោះសម្រាប់ការប្រើប្រាស់ក្នុងផ្ទះសំបែងរាល់ថ្ងៃ។ ប្រសិនបើការអនុវត្តគម្រោងដោយប្រើប្រាស់សារធាតុពុលគីមីកសិកម្ម នោះសារធាតុគីមីកសិកម្មទាំងនោះអាចនឹងហូរចូលក្នុងប្រភពទឹក ដែលធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ។ |
| **ផ្នែកទី៤ ៖ ការសង្ខេបព័ត៌មាន** | | |
| ៤.១ | តើមានហេតុផលណាដែលបណ្តាលឱ្យគម្រោងនេះមិនទទួលបានជោគជ័យដែរឬទេ? (សំណួរនេះឆ្លើយដោយអ្នកជំនួយបច្ចេកទេស)។ | តាមជាក់ស្តែងអ្នកជំនួយបច្ចេកទេសរំពឹងថា គម្រោងនឹងទទួលបានជោគជ័យ (ព្រោះគាត់បានរៀបចំគំនូសប្លង់) តែទោះជាយ៉ាងណាក៏ដោយគាត់ប្រហែលជាចង់ប្រើប្រអប់នេះ ដើម្បីកត់ត្រាចំណុចសំខាន់ៗមួយចំនួន។ ឧទាហរណ៍ ៖ គម្រោងអាចទទួលបានជោគជ័យយ៉ាងធំធេង តែក្នុងករណីសហគមន៍កសិករចេះប្រើប្រាស់ទឹកឱ្យមានប្រយោជន៍ និងថែទាំលទ្ធផលគម្រោងបានល្អ។ |
| ៤.២. | តើព័ត៌មានទាំងអស់អំពីការសិក្សាគម្រោងត្រូវបានផ្តល់ឱ្យគ្រប់គ្រាន់ហើយឬនៅ? | នេះគ្រាន់តែជាបញ្ជីដើម្បីពិនិត្យមើលថា ព័ត៌មានទាំងអស់មានសព្វគ្រប់។ គណៈកម្មការគ្រប់គ្រងគម្រោង (ដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស) ត្រូវគូសនៅក្នុងប្រអប់នីមួយៗ ដើម្បីបញ្ជាក់ថាព័ត៌មានទាំងអស់បានបំពេញនៅក្នុងទម្រង់ព័ត៌មាន ឬឯកសារភ្ជាប់។<br>ទីចាត់ការផែនការ និងវិនិយោគខេត្តក៏ត្រូវពិនិត្យមើលបញ្ជីនេះផងដែរ ដោយគូសក្នុងប្រអប់ បន្ទាប់មុនពេលផ្ញើទៅមន្ទីរអង្គភាពជំនាញ ដើម្បីបញ្ជាក់បច្ចេកទេស។ |
| ការចុះហត្ថលេខា | | អភិបាលក្រុង ស្រុក និងអ្នកជំនួយបច្ចេកទេសត្រូវចុះហត្ថលេខា ដើម្បីបញ្ជាក់ថា រាល់ព័ត៌មានទាំងអស់បានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវ។<br>ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវចុះហត្ថលេខា ដើម្បីបញ្ជាក់ថា បានឃើញនិងពិនិត្យរាល់ព័ត៌មានចប់សព្វគ្រប់។ |
| **ឯកសារភ្ជាប់មកជាមួយ** | | |
| ផែនទីគម្រោង | | ផែនទីគម្រោងត្រូវបានគូសដោយចម្លងពីផែនទីក្រុងស្រុក ដែលមានក្នុងផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគក្រុង ស្រុក។ ប្រភេទ និងទីតាំងនៃលទ្ធផលគម្រោងត្រូវបង្ហាញដោយប្រើប្រាស់និមិត្តសញ្ញាសាមញ្ញៗ។ |
| ព័ត៌មានបច្ចេកទេស | | ប្រភេទព័ត៌មានបច្ចេកទេសអាស្រ័យទៅនឹងប្រភេទគម្រោង។ អ្នកជំនួយ |

| | |
|---|---|
| | បច្ចេកទេសត្រូវតែទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានទាំងនេះ ដែលត្រូវបានបញ្ចូលទៅក្នុងទម្រង់ព័ត៌មានគម្រោង |
| តម្លៃប៉ាន់ស្មានគម្រោងលម្អិត | ទម្រង់នេះបង្ហាញអំពីតម្លៃប៉ាន់ស្មានតាមលទ្ធផលគម្រោងនីមួយៗ ឬលទ្ធផលគម្រោងទាំងមូលអាស្រ័យនឹងប្រភេទគម្រោង។ |
| លទ្ធផលគម្រោង និងតម្លៃប៉ាន់ស្មាន | ទម្រង់នេះបង្ហាញតាមលទ្ធផលគម្រោងនីមួយៗ និងតម្លៃប៉ាន់ស្មាន។ អ្នកជំនួយបច្ចេកទេសនឹងជួយបំពេញទម្រង់នេះ។ |
| ផែនការប្រតិបត្តិ និងថែទាំ | ទម្រង់នេះបង្ហាញពីផែនការសម្រាប់ប្រតិបត្តិ និងថែទាំលទ្ធផលគម្រោង។ |
| របាយការណ៍សិក្សាផលប៉ះពាល់បរិស្ថាន | ទម្រង់នេះបង្ហាញអំពីផលប៉ះពាល់បរិស្ថាន ដែលបណ្តាលមកពីការអនុវត្តគម្រោង និងផែនការគ្រប់គ្រងបរិស្ថាន។ |

ទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធមួយច្បាប់ត្រូវរក្សាទុកក្នុងសំណុំឯកសារគម្រោងនៅសាលាក្រុង ស្រុក។ ចំពោះគម្រោងអន្តររដ្ឋបាល ទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធច្បាប់ដើមត្រូវ រក្សាទុកនៅការិយាល័យនៃប្រធានគណៈកម្មការគ្រប់គ្រងគម្រោង ហើយច្បាប់ថតចម្លងរក្សាទុកនៅតាមរដ្ឋបាលដែលពាក់ព័ន្ធនឹងគម្រោងនោះ។

**កំណត់សម្គាល់ ៖** ជាទូទៅ គម្រោងសេវាកម្មក្រុង ស្រុក ផ្តោតលើការលើកកម្ពស់ជីវភាព និងបញ្ហារបស់ប្រជាពលរដ្ឋក្រីក្រ ក្រុមជនងាយរងគ្រោះ ជនមានពិការភាព។ល។ ដូច្នេះ ដើម្បីជ្រើសរើសបានអ្នកទទួលផលត្រឹមត្រូវពិតប្រាកដ គណៈកម្មការគ្រប់គ្រងគម្រោងគប្បីពិនិត្យផ្ទៀងផ្ទាត់នូវទិន្នន័យ និងព័ត៌មានដែលមានស្រាប់ ដូចជារបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណអ្នកក្រីក្រ និងលទ្ធផលនៃការរៀបចំផែនទីសេវាសង្គម ព្រមទាំងត្រូវពិនិត្យលើស្ថានភាពជាក់ស្តែងផងដែរ។ ក្នុងករណីដែលមានចំនួនអ្នកក្រច្រើនជាងទំហំគម្រោងដែលក្រុង ស្រុក អាចអនុវត្តបាន រដ្ឋបាលក្រុង ស្រុក គួរជ្រើសរើសវិធីសាស្ត្រណាមួយដែលសមស្របបំផុត និងធានាបាននូវសមធម៌ក្នុងការជ្រើសរើសក្រុម ឬគ្រួសារគោលដៅ។

## ៤.២. ការប៉ាន់ស្មានតម្លៃគម្រោង

បន្ទាប់ពីរៀបចំគ្រោងការគម្រោងចប់សព្វគ្រប់ អ្នកជំនួយបច្ចេកទេសត្រូវធ្វើការប៉ាន់ស្មានតម្លៃគម្រោងដោយផ្អែកតាមគោលការណ៍ណែនាំដែលបានកំណត់។ ដើម្បីធ្វើការប៉ាន់ស្មានតម្លៃគម្រោង ជាដំបូងត្រូវធ្វើការប៉ាន់ស្មានតម្លៃនៃលទ្ធផលនីមួយៗរបស់គម្រោង ហើយបន្ទាប់មកត្រូវបូកសរុបតម្លៃប៉ាន់ស្មានរបស់លទ្ធផលនីមួយៗនៃលទ្ធផលទាំងអស់របស់គម្រោង។ តម្លៃប៉ាន់ស្មានសរុបនៃលទ្ធផលទាំងអស់ គឺជាតម្លៃប៉ាន់ស្មាននៃគម្រោង។ បន្ទាប់ពីគណនាតម្លៃប៉ាន់ស្មាននៃលទ្ធផលនីមួយៗរបស់គម្រោង អ្នកជំនួយបច្ចេកទេសត្រូវបំពេញទម្រង់លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោង។

តម្លៃគម្រោងប៉ាន់ស្មានត្រូវឆ្លុះបញ្ចាំងនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក។ ការប្រកាសផ្សព្វផ្សាយអំពីការប្រជុំដេញថ្លៃត្រូវជម្រាបអំពីតម្លៃប៉ាន់ស្មានរបស់គម្រោងដល់អ្នកដេញថ្លៃ។

ឯកសារដេញថ្លៃដែលផ្តល់ឱ្យអ្នកដេញថ្លៃនឹងភ្ជាប់ជាមួយនូវបញ្ជីប៉ាន់ស្មានតម្លៃលម្អិតនៃលទ្ធផលគម្រោងនីមួយៗ។ អ្នកដេញថ្លៃត្រូវគណនាតម្លៃនៃលទ្ធផលគម្រោងនីមួយៗសម្រាប់ដាក់ដេញថ្លៃ ដោយធ្វើការថ្លឹងថ្លែងតម្លៃប៉ាន់ស្មាន ផ្អែកលើតម្លៃដែលខ្លួននឹងចំណាយទៅលើសម្ភារៈ និងពលកម្ម។ បន្ទាប់មកអ្នកដេញថ្លៃនឹងសរសេរតម្លៃ ដែលខ្លួនបានគណនានេះទៅក្នុងទម្រង់សំណើដេញថ្លៃ។ វិធីសាស្ត្រនេះ គឺដើម្បីឱ្យអ្នកដេញថ្លៃ

ទាំងអស់យល់ច្បាស់អំពីតម្លៃគម្រោងដែលនឹងត្រូវអនុវត្ត។

ជាការសំខាន់ណាស់ដែលការប៉ាន់ស្មានតម្លៃត្រូវមានតម្លាភាព និងអាចជឿទុកចិត្តបាន។ តម្លៃប៉ាន់ស្មានត្រូវតែគណនាដោយប្រើប្រាស់វិធីសាស្ត្រដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំនេះ។ អ្នកជំនួយបច្ចេកទេសមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់វិធីសាស្ត្រផ្សេងពីនេះឡើយ។

អ្នកជំនួយបច្ចេកទេសជាអ្នករៀបចំការប៉ាន់ស្មានតម្លៃគម្រោង ហើយគណៈកម្មការគ្រប់គ្រងគម្រោងជាអ្នកពិនិត្យ និងអនុម័តទៅលើតម្លៃប៉ាន់ស្មាននេះ។ ប្រសិនបើ គណៈកម្មការគ្រប់គ្រងគម្រោងគិតថា តម្លៃប៉ាន់ស្មាននេះមិនត្រឹមត្រូវគណៈកម្មការគ្រប់គ្រងគម្រោងមិនត្រូវទទួលយកតម្លៃប៉ាន់ស្មាននេះឡើយ។ គណៈកម្មការគ្រប់គ្រងគម្រោងអាច ៖

- ប្រៀបធៀបតម្លៃក្នុងបញ្ជីសម្ភារៈជាមួយនឹងតម្លៃជាក់ស្តែងនៅលើទីផ្សារ។
- ប្រៀបធៀបតម្លៃប៉ាន់ស្មានជាមួយនឹងតម្លៃជាក់ស្តែងនៃគម្រោងប្រហាក់ប្រហែលគ្នានេះ (អ្នកជំនួយបច្ចេកទេសត្រូវផ្តល់បញ្ជីតម្លៃទាំងនេះដល់គណៈកម្មការគ្រប់គ្រងគម្រោង)។
- ស្នើសុំវិស្វករឯកជនឱ្យជួយពិនិត្យតម្លៃ។

នៅពេលគណៈកម្មការគ្រប់គ្រងគម្រោងគិតថាតម្លៃប៉ាន់ស្មាននេះត្រឹមត្រូវ គណៈកម្មការគ្រប់គ្រងគម្រោងត្រូវដាក់ជូនអភិបាលក្រុង ស្រុកនូវទម្រង់ប៉ាន់ស្មានតម្លៃលម្អិត និងទម្រង់លទ្ធផលគម្រោង និងតម្លៃប៉ាន់ស្មានគម្រោង ដើម្បីចុះហត្ថលេខា។

### ៤.២.១. របៀបគណនាតម្លៃប៉ាន់ស្មាន

**តម្លៃប៉ាន់ស្មាន = តម្លៃផ្ទាល់ + តម្លៃប្រយោល + ប្រាក់ចំណេញ**

**ក). តម្លៃផ្ទាល់**

តម្លៃផ្ទាល់ គឺជាតម្លៃសម្រាប់អនុវត្តសកម្មភាពនានា និងតម្លៃសម្ភារៈ ឬទំនិញនានាសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពរបស់គម្រោង។ ដូចនេះមុននឹងគណនាតម្លៃ អ្នកជំនួយបច្ចេកទេសដែលមានភារកិច្ចជួយគណៈកម្មការគ្រប់គ្រងគម្រោងក្នុងការគណនាតម្លៃប៉ាន់ស្មានគម្រោង ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីសកម្មភាពនានារបស់គម្រោងនិងសម្ភារៈ ឬទំនិញនានាដែលគាំទ្រដល់ការអនុវត្តសកម្មភាពរបស់គម្រោង។ សកម្មភាពនិងសម្ភារៈនានានៃគម្រោងសេវាកម្មអាចមាន ៖

- ការចងក្រងក្រុមនិងរៀបចំលក្ខន្តិកៈក្រុម
- ការបណ្តុះបណ្តាលអប់រំផ្សព្វផ្សាយ(ចំនួនដងក្នុងមួយវគ្គចំនួនវគ្គ ចំនួនសិក្ខាកាម សម្ភារៈបណ្តុះបណ្តាល)
- ការធ្វើបង្ហាញដល់កសិករគោលដៅ (ចំនួនកន្លែង និងសម្ភារៈដែលត្រូវការ)
- ការរៀបចំទិវាផ្សេងៗ
- ការផ្តល់សម្ភារៈជូនកសិករគោលដៅសម្រាប់ការរៀបចំកន្លែងអនុវត្តជាក់ស្តែង
- ការចុះតាមដាន និងជួយដល់កសិករគោលដៅក្នុងការរៀបចំកន្លែងសម្រាប់ការអនុវត្តជាក់ស្តែង ដូចជាការរៀបចំថ្នាលបណ្តុះ ការរៀបចំស្រះ ការរៀបចំដី ការរៀបចំរោងជីកំប៉ុស ការរៀបចំទ្រុង... ។ល។
- ការផ្តល់គ្រាប់ពូជ ឬពូជសត្វឬកូនឈើ... សម្រាប់អនុវត្តជាក់ស្តែង។

- ការចុះតាមដាន និងគាំទ្រដល់កសិករគោលដៅនៅក្នុងអំឡុងពេលអនុវត្តជាក់ស្តែងរហូតដល់បញ្ចប់គម្រោង។ ជួនកាលសកម្មភាពនេះ ត្រូវបន្តរហូតដល់កសិករគោលដៅមានសមត្ថភាពគ្រប់គ្រាន់។
- ពូជសម្ភារៈ និងឧបករណ៍ដែលត្រូវការ ៖
  – សម្ភារៈសម្រាប់រៀបចំ ឬសាងសង់កន្លែងអនុវត្តជាក់ស្តែង
  – ឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តជាក់ស្តែង
  – គ្រាប់ពូជ
  – ពូជសត្វ
  – កូនឈើ ...។ល។

បន្ទាប់ពីកំណត់សកម្មភាពនិងសម្ភារៈ ឬទំនិញនានារួច យើងត្រូវចាប់ផ្តើមគណនាតម្លៃនៃសកម្មភាព និងសម្ភារៈ ឬទំនិញនីមួយៗ។ ចំពោះសកម្មភាពរៀបចំក្រុមការបណ្តុះបណ្តាល ឯកសារបណ្តុះបណ្តាល សកម្មភាពចុះគាំទ្របច្ចេកទេស និងទិវាបង្ហាញអាចគណនាតម្លៃប៉ាន់ស្មានជារួមសម្រាប់ក្រុមកសិករគោលដៅទាំងមូល (ឧទាហរណ៍ ៖ កសិករគោលដៅ២០នាក់) បន្ទាប់មក យកតម្លៃប៉ាន់ស្មានសរុបនេះ*ចែកនឹង*ចំនួនសរុបនៃកសិករគោលដៅ។ ឯកសារជំនួយស្មារតីអំពីតម្រូវការអប្បបរមានៃលក្ខណៈបច្ចេកទេសគម្រោងសេវាកម្មសម្រាប់ជាមូលដ្ឋានក្នុងការគណនាតម្លៃប៉ាន់ស្មានមានក្នុងឧបសម្ព័ន្ធទី១។

**ឧទាហរណ៍ ៖** គម្រោងកសិកម្មចម្រុះមានសួនបន្លែ និងការចិញ្ចឹមត្រីសម្រាប់កសិករ២០គ្រួសារ។ សកម្មភាព និងសម្ភារៈរួមមាន៖

**១). ការបណ្តុះបណ្តាលអំពីកសិកម្មចម្រុះ (សួនបន្លែនិងការចិញ្ចឹមត្រី)**

- សម្ភារៈបណ្តុះបណ្តាល ៖ ២០នាក់ x ៤.០០០៛ = ៨០.០០០៛
- ឯកសារបណ្តុះបណ្តាល ៖ ២០នាក់ x ១២.០០០៛ = ២៤០.០០០៛
- អាហារសម្រន់ក្នុងការរៀបចំក្រុម និងបណ្តុះបណ្តាល ៖ ២០នាក់ x ១៦លើក x ៤.០០០៛ = ១.២៨០.០០០៛
- ថ្លៃសេវាបណ្តុះបណ្តាលនិងចុះគាំទ្របច្ចេកទេស ៖ ១៦លើក x ១២០.០០០៛ = ១.៩២០.០០០៛
- ការរៀបចំទិវាស្រែកសិករ ៖ ២០០.០០០៛

**២). ការធ្វើបង្ហាញអំពីសួនបន្លែ (សម្ភារៈ)**

- គ្រាប់ពូជត្រកួន ៖ ៤០កំប៉ុង x ៥.០០០៛ = ២០០.០០០៛
- គ្រាប់ពូជត្រសក់ ៖ ៤០កំប៉ុង x ៥.០០០៛ = ២០០.០០០៛
- គ្រាប់ពូជស្ពៃ ៖ ៤០កំប៉ុង x ៥.០០០៛ = ២០០.០០០៛
- គ្រាប់ពូជសណ្តែកកួរ ៖ ៤០កំប៉ុង x ៥.០០០៛ = ២០០.០០០៛
- គ្រាប់ពូជឆៃថាវ ៖ ៤០កំប៉ុង x ៥.០០០៛ = ២០០.០០០៛
- ចបកាប់ ៖ ២០ចបកាប់ x ២០.០០០៛ = ៤០០.០០០៛
- ធុងស្រោចដំណាំ (១៥លីត្រ) ៖ ២០គូ x ៣០.០០០៛ = ៦០០.០០០៛

**៣). ការធ្វើបង្ហាញអំពីការចិញ្ចឹមត្រី (សម្ភារៈ)**

- ជីកឬស្តារស្រះចិញ្ចឹមត្រី ៖ ២០ស្រះ x ១០០.០០០៛ = ២.០០០.០០០៛
- កំបោរ ៖ ២០គ្រួសារ x ១០គ.ក្រ x ១.០០០៛ = ២០០.០០០៛
- សំណាញ់ឬមុង ៖ ២០គ្រួសារ x ២០ម x ២.០០០៛ = ៨០០.០០០៛
- កូនត្រី ៖ ២០គ្រួសារ x ៥០០ក្បាល x ២០០៛ = ២.០០០.០០០៛

**៩). ការគណនាតម្លៃប្រយោលនិងប្រាក់ចំណេញ**

តម្លៃប្រយោលនិងប្រាក់ចំណេញ = តម្លៃផ្ទាល់ X ១០% (ឬ០,១០)

**តម្លៃសរុប = តម្លៃផ្ទាល់ + តម្លៃប្រយោលនិងប្រាក់ចំណេញ**

តម្លៃប្រយោល និងប្រាក់ចំណេញសម្រាប់ក្រុមហ៊ុន ឬអង្គភាពរកប្រាក់ចំណេញ។

ចំពោះអង្គភាពមិនរកប្រាក់ចំណេញ ដូចជា អង្គការមិនមែនរដ្ឋាភិបាលសមាគម និងអង្គការសហគមន៍មូលដ្ឋានពុំមានតម្លៃប្រយោល និងប្រាក់ចំណេញទេ គឺការចំណាយរដ្ឋបាល និងគ្រប់គ្រង។ ការចំណាយរដ្ឋបាល និងគ្រប់គ្រងគណនា ដូចខាងក្រោម ៖

- ចំណាយរដ្ឋបាលនិងគ្រប់គ្រង = តម្លៃផ្ទាល់ X ១០%

**តម្លៃសរុប = តម្លៃផ្ទាល់ + ការចំណាយរដ្ឋបាលនិងគ្រប់គ្រង**

**បន្ទាប់ពីគណនាតម្លៃប៉ាន់ស្មានរបស់គម្រោង ហើយ អ្នកជំនួយបច្ចេកទេសត្រូវរៀបចំបំពេញទម្រង់ទី១០ ការប៉ាន់ស្មានតម្លៃសម្រាប់គម្រោងសេវាកម្ម។**

## ទម្រង់ទី១០ ÷ ការប៉ាន់ស្មានតម្លៃសម្រាប់គម្រោងសេវាកម្ម

**ឧទាហរណ៍**

| | | | | | |
|---|---|---|---|---|---|
| **ការប៉ាន់ស្មានតម្លៃលម្អិតសម្រាប់គម្រោងសេវាកម្ម** | | | | | |
| ខេត្ត ៖ កំពង់ចាម | | ក្រុង ស្រុក ៖ ស្រីសន្ធរ | | លេខកូដក្រុង ស្រុក ៖ ០៣១៤ | |
| ឈ្មោះគម្រោង ៖ គម្រោងកសិកម្មចម្រុះស្រុកស្រីសន្ធរ | | | | | |
| ភូមិ ៖ ត្នោតលើ | | ការពិពណ៌នាលទ្ធផលគម្រោង ៖ កសិកម្មចម្រុះចំនួន២០គ្រួសារ ដែលក្នុងនោះមានសួនបន្លែនិ ងចិញ្ចឹមត្រី។ | | | |
| ឃុំសង្កាត់ ៖ ឫស្សីស្រុក | | | | | |
| **ការប៉ាន់ស្មានតម្លៃសម្រាប់មួយឯកតានៃលទ្ធផល** | | | | | |
| **ល.រ** | **ការពិពណ៌នា** | **ឯកតា** | **ចំនួន** | **តម្លៃឯកតា (៛)** | **សរុប (៛)** |
| ១ | ការបណ្តុះបណ្តាលអំពីកសិកម្មចម្រុះ(សួនបន្លែ និងការចិញ្ចឹមត្រី) | | | | |
| | សម្ភារៈបណ្តុះបណ្តាល | នាក់ | ២០ | ៤.០០០ | ៨០.០០០ |
| | ឯកសារបណ្តុះបណ្តាល | នាក់ | ២០ | ១២.០០០ | ២៤០.០០០ |
| | អាហារសម្រន់(រៀបចំក្រុម និងបណ្តុះបណ្តាល) | នាក់ថ្ងៃ | ៣២០ | ៤.០០០ | ១.២៨០.០០០ |
| | ថ្លៃសេវាបណ្តុះបណ្តាល និងចុះគាំទ្របច្ចេកទេស | លើក | ១៦ | ១២០.០០០ | ១.៩២០.០០០ |
| | ការរៀបចំទិវាស្រែកសិករ | រួម | ១ | ២០០.០០០ | ២០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| សរុបតម្លៃផ្ទាល់លទ្ធផលទី១ | | | | | ៣.៧២០.០០០ |
| តម្លៃប្រយោលនិងប្រាក់ចំណេញ | | | | ១០% | ៣៧២.០០០ |
| សរុបលទ្ធផលទី១ | | | | | **៤.០៩២.០០០** |
| ២ | ***ការធ្វើបង្ហាញអំពីសួនបន្លែ (សម្ភារៈ)*** | | | | |
| | *គ្រាប់ពូជត្រកួន* | *កំប៉ុង* | *៤០* | *៥.០០០* | *២០០.០០០* |
| | *គ្រាប់ពូជត្រសក់* | *កំប៉ុង* | *៤០* | *៥.០០០* | *២០០.០០០* |
| | *គ្រាប់ពូជស្ពៃ* | *កំប៉ុង* | *៤០* | *៥.០០០* | *២០០.០០០* |
| | *គ្រាប់ពូជសណ្តែកកួរ* | *កំប៉ុង* | *៤០* | *៥.០០០* | *២០០.០០០* |
| | *គ្រាប់ពូជឆៃថាវ* | *កំប៉ុង* | *៤០* | *៥.០០០* | *២០០.០០០* |
| | *ចបកាប់* | *ចបកាប់* | *២០* | *២០.០០០* | *៤០០.០០០* |
| | *ធុងស្រោចដំណាំ (១៥លីត្រ)* | *គូ* | *២០* | *៣០.០០០* | *៦០០.០០០* |
| សរុបតម្លៃផ្ទាល់លទ្ធផលទី២ | | | | | ២.០០០.០០០ |
| តម្លៃប្រយោលនិងប្រាក់ចំណេញ | | | | ១០% | ២០០.០០០ |
| សរុបលទ្ធផលទី២ | | | | | **២.២០០.០០០** |
| ៣ | ***ការធ្វើបង្ហាញអំពីការចិញ្ចឹមត្រី (សម្ភារៈ)*** | | | | |
| | *ជីកឬស្តារស្រះសម្រាប់ចិញ្ចឹមត្រី* | *ស្រះ* | *២០* | *១០០.០០០* | *២.០០០.០០០* |
| | *កំបោរ* | *គ.ក្រ* | *២០០* | *១.០០០* | *២០០.០០០* |
| | *សំណាញ់ឬមុង* | *ម* | *៤០០* | *២.០០០* | *៨០០.០០០* |
| | *កូនត្រី* | *ក្បាល* | *១០.០០០* | *២០០* | *២.០០០.០០០* |
| សរុបតម្លៃផ្ទាល់លទ្ធផលទី៣ | | | | | ៥.០០០.០០០ |
| តម្លៃប្រយោលនិងប្រាក់ចំណេញ | | | | ១០% | ៥០០.០០០ |
| សរុបលទ្ធផលទី៣ | | | | | **៥.៥០០.០០០** |
| ៤ | ការរៀបចំស្លាកសញ្ញាគម្រោង | | | | |
| | តម្លៃស្លាកសញ្ញាគម្រោង (១០ស្លាក) | | | | ៤០០.០០០ |
| សរុបតម្លៃផ្ទាល់លទ្ធផលទី៤ | | | | | ៤០០.០០០ |
| តម្លៃប្រយោលនិងប្រាក់ចំណេញ | | | | ១០% | ៤០.០០០ |
| សរុបលទ្ធផលទី៣ | | | | | ៤៤០.០០០ |
| **សរុបរួម** | | | | | ១២.២៣២.០០០ |

ថ្ងៃទី......... ខែ............. ឆ្នាំ..........　　　　ថ្ងៃទី......... ខែ............. ឆ្នាំ..........

**អភិបាលក្រុង ស្រុក**　　　　**អ្នកជំនួយបច្ចេកទេស**

**កំណត់សម្គាល់ ÷**

- ការគណនាតម្លៃប៉ាន់ស្មានគម្រោងមិនត្រូវរួមបញ្ចូលតម្លៃបង់ពន្ធ និងអាករទេ។ តម្លៃប៉ាន់ស្មានគម្រោងនេះត្រូវបានប្រើប្រាស់សម្រាប់ការដេញថ្លៃ។ តម្លៃបង់ពន្ធ និងអាករតាមរបបស្វ័យប្រកាស ឬរបបម៉ៅការត្រូវបានបញ្ចូលទៅក្នុងកិច្ចសន្យា នៅពេលចុះកិច្ចសន្យាអាស្រ័យទៅនឹងអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មដែលឈ្នះក្នុងការដេញថ្លៃនោះថាតើគាត់ជាប់ពន្ធតាមរបបស្វ័យប្រកាស ឬជាប់ពន្ធតាមរបបម៉ៅការ។ ចំណែកតម្លៃបង់ពន្ធក្នុងការធ្វើអាជីវកម្មផ្សេងៗទៀត(ឧទាហរណ៍ថ្លៃបង់ប័ណ្ណប៉ាតង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យា...។ល។) និងថ្លៃស្វយសារវត្ថុធាតុដើមថ្មសម្ភារៈសំណង់ គឺជាការទទួលខុសត្រូវរបស់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មផ្ទាល់។ នេះមានន័យថាអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មត្រូវគណនាតម្លៃសម្រាប់ដាក់ដេញថ្លៃ ដោយរួមបញ្ចូលទាំងតម្លៃពន្ធ និងថ្លៃស្វយសារវត្ថុធាតុដើម ថ្ម សម្ភារៈសំណង់ ដែលត្រូវបង់តាមការតម្រូវរបស់រដ្ឋ លើកលែងតែពន្ធ និងអាករតាមរបបស្វ័យប្រកាស ឬពន្ធរបបម៉ៅការ។
- ក្រុង ស្រុកនីមួយៗ ត្រូវត្រៀមបម្រុងថវិការបស់ខ្លួនចំនួន**១០%**នៃតម្លៃប៉ាន់ស្មានគម្រោងសរុប ដើម្បីគណនាតម្លៃពន្ធបញ្ចូលទៅក្នុងតម្លៃកិច្ចសន្យា បន្ទាប់ពីការដេញថ្លៃ។
- ដើម្បីធានាឱ្យការគណនាតម្លៃប៉ាន់ស្មានបានកាន់តែសុក្រឹត្យ រដ្ឋបាលខេត្តនីមួយៗ ត្រូវរៀបចំតារាងបញ្ជីតម្លៃស្តង់ដាសម្រាប់គម្រោងសេវាកម្ម។

### ៤.២.២. ការបំពេញទម្រង់លទ្ធផលនិងតម្លៃប៉ាន់ស្មានគម្រោង

ទម្រង់លទ្ធផលគម្រោង និងប៉ាន់ស្មានតម្លៃ(**ទម្រង់ទី១១**) បង្ហាញ ៖

- លទ្ធផលគម្រោងនីមួយៗព្រមទាំងទីតាំង និងទំហំរបស់វា
- តម្លៃប៉ាន់ស្មាននៃលទ្ធផលគម្រោងនីមួយៗ
- តម្លៃប៉ាន់ស្មានសរុបរបស់គម្រោង។

**ក). *ភូមិ និងឃុំ សង្កាត់***

លទ្ធផលគម្រោងមួយអាចមាននៅក្នុងមួយភូមិ ឬច្រើនជាងមួយភូមិ។

ឧទាហរណ៍ ៖ គម្រោងកសិកម្មចម្រុះ អនុវត្តនៅក្នុងភូមិចំនួន០២ ក្នុងឃុំចំនួន០២ នៃស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

លទ្ធផលគ្រោងនៅតាមភូមិ និងឃុំនីមួយៗមាន ដូចខាងក្រោម ៖

- ភូមិ "ក១" នៃឃុំ "ក" ៖ ការបណ្តុះបណ្តាលអំពីកសិកម្មចម្រុះ មានសិក្ខាកាមចំនួន ១០នាក់
- ភូមិ "ក១" នៃឃុំ "ក" ៖ ការធ្វើបង្ហាញអំពីសួនបន្លែ មានកសិករចំនួន ១០គ្រួសារ
- ភូមិ "ក១" នៃឃុំ "ក" ៖ ការធ្វើបង្ហាញអំពីចិញ្ចឹមត្រី មានកសិករចំនួន ១០គ្រួសារ
- ភូមិ "ខ១" នៃឃុំ "ខ" ៖ ការបណ្តុះបណ្តាលអំពីកសិកម្មចម្រុះ មានសិក្ខាកាមចំនួន ១០នាក់
- ភូមិ "ខ១" នៃឃុំ "ខ" ៖ ការធ្វើបង្ហាញអំពីសួនបន្លែ មានកសិករចំនួន ១០គ្រួសារ
- ភូមិ "ខ១" នៃឃុំ "ខ" ៖ ការធ្វើបង្ហាញអំពីចិញ្ចឹមត្រី មានកសិករចំនួន ១០គ្រួសារ

យើងធ្វើដូច្នេះអាច ៖

- តាមដានអំពីអ្វីដែលភូមិនីមួយៗបានទទួលផលពីគម្រោង
- ងាយស្រួលក្នុងការតាមដានទីកន្លែងនៃលទ្ធផលគម្រោង។

**ខ). លេខសម្គាល់លទ្ធផលគម្រោង និងការពិពណ៌នា**

គ្រប់ប្រភេទនៃលទ្ធផលគម្រោងទាំងអស់មានលេខកូដស្តង់ដារ ហៅថាលេខសម្គាល់លទ្ធផលគម្រោង។ លេខសម្គាល់លទ្ធផលគម្រោងទាំងនេះមាននៅក្នុងបញ្ជីលទ្ធផលគម្រោង(មានភ្ជាប់នៅខាងក្រោយ)។ ឧទាហរណ៍ លេខសម្គាល់លទ្ធផលគម្រោងបណ្តុះបណ្តាលអំពីស្រែប្រពលវប្បកម្មគឺ២០១០១០១ និងគម្រោងធ្វើបង្ហាញអំពីស្រែប្រពលវប្បកម្ម គឺ២០១០១០២ ជាដើម។

**គ). បរិមាណ (ឬចំនួន)និងឯកតា**

គ្រប់លទ្ធផលគម្រោងទាំងអស់មានរង្វាស់ឯកតាស្តង់ដារ។ យើងអាចរករង្វាស់ឯកតាស្តង់ដារនេះ នៅក្នុងបញ្ជីលទ្ធផលគម្រោងស្តង់ដារ។ ឧទាហរណ៍ ៖ ចំនួនអ្នកចូលរួមវគ្គបណ្តុះបណ្តាលត្រូវបានវាស់គិតជា "នាក់" ។

**ឃ). តម្លៃប៉ាន់ស្មានលទ្ធផលគម្រោង**

តម្លៃប៉ាន់ស្មានលទ្ធផលគម្រោងចែកចេញជាពីរ គឺតម្លៃប៉ាន់ស្មានក្នុងមួយឯកតានៃលទ្ធផលគម្រោងនីមួយៗ និងតម្លៃប៉ាន់ស្មានសរុបនៃលទ្ធផលគម្រោងនីមួយៗ។ ឧទាហរណ៍តម្លៃប៉ាន់ស្មានក្នុងមួយឯកតាសម្រាប់ការធ្វើបង្ហាញអំពីសួនបន្លែ គឺជាតម្លៃសម្រាប់ការធ្វើបង្ហាញសួនបន្លែចំនួន០១ ឬចំនួន០១គ្រួសារ។

តម្លៃប៉ាន់ស្មានក្នុងមួយឯកតា និងតម្លៃប៉ាន់ស្មានសរុបនៃលទ្ធផលនីមួយៗ ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងទម្រង់ប៉ាន់ស្មានតម្លៃលម្អិត។ ដូច្នេះយើងត្រូវស្រង់តួលេខនេះចូលក្នុងទម្រង់លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងឱ្យបានត្រឹមត្រូវ។

**ង). តម្លៃប៉ាន់ស្មានគម្រោង**

តម្លៃប៉ាន់ស្មានគម្រោង គឺជាតម្លៃប៉ាន់ស្មានសរុបលទ្ធផលគម្រោងទាំងអស់។

# ទម្រង់ទី១១ ÷ លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងសេវាកម្ម

**ឧទាហរណ៍**

| ខេត្ត ៖កំពង់ចាម | ក្រុង ស្រុក ៖ ស្រីសន្ធរ | លេខកូដក្រុង ស្រុក ៖ ០៣១៤ | ឈ្មោះគម្រោង ៖ កសិកម្មចម្រុះសួនបន្លែនិងចិញ្ចឹមត្រី |
|---|---|---|---|

| លរ | ឈ្មោះភូមិ | ឈ្មោះឃុំ សង្កាត់ | លេខលទ្ធផល | ការពិពណ៌នាអំពីលទ្ធផលគម្រោង | ថ្មីឬពង្រឹង | បរិមាណ | ឯកតា | តម្លៃឯកតា(រ) | តម្លៃសរុប(រ) |
|---|---|---|---|---|---|---|---|---|---|
| ១ | ភូមិ ក១ | ឃុំ ក | ២០១០១១១ | ការបណ្តុះបណ្តាលអំពីកសិកម្មចម្រុះ(សួនបន្លែ-ចិញ្ចឹមត្រី) | ថ្មី | ១០ | នាក់ | ២០៤.៦០០ | ២.០៤៦.០០០ |
| ២ | ភូមិ ខ១ | ឃុំ ខ | ២០១០១១១ | ការបណ្តុះបណ្តាលអំពីកសិកម្មចម្រុះ(សួនបន្លែ-ចិញ្ចឹមត្រី) | ថ្មី | ១០ | នាក់ | ២០៤.៦០០ | ២.០៤៦.០០០ |
| ៣ | ភូមិ ក១ | ឃុំ ក | ២០១០១២២ | ការធ្វើបង្ហាញអំពីសួនបន្លែ(សម្ភារ:) | ថ្មី | ១០ | គ្រួសារ | ១១០.០០០ | ១.១០០.០០០ |
| ៤ | ភូមិ ខ១ | ឃុំ ខ | ២០១០១២២ | ការធ្វើបង្ហាញអំពីសួនបន្លែ(សម្ភារ:) | ថ្មី | ១០ | គ្រួសារ | ១១០.០០០ | ១.១០០.០០០ |
| ៥ | ភូមិ ក១ | ឃុំ ក | ២០១០៤៣០ | ការធ្វើបង្ហាញអំពីការចិញ្ចឹមត្រី(សម្ភារ:) | ថ្មី | ១០ | គ្រួសារ | ២៧៥.០០០ | ២.៧៥០.០០០ |
| ៦ | ភូមិ ខ១ | ឃុំ ខ | ២០១០៤៣០ | ការធ្វើបង្ហាញអំពីការចិញ្ចឹមត្រី(សម្ភារ:) | ថ្មី | ១០ | គ្រួសារ | ២៧៥.០០០ | ២.៧៥០.០០០ |
| តម្លៃប៉ាន់ស្មានសរុបនៃគម្រោង | | | | | | | | | ១១.៧៩២.០០០ |

**កំណត់សម្គាល់** ÷ មានតែលទ្ធផលគម្រោងដែលមានថវិកាគ្រប់គ្រាន់ប៉ុណ្ណោះ ត្រូវបានកត់ត្រានៅក្នុងទម្រង់នេះ។

ថ្ងៃទី......... ខែ............. ឆ្នាំ.......... ថ្ងៃទី......... ខែ............. ឆ្នាំ..........

**អភិបាលក្រុង ស្រុក** **អ្នកជំនួយបច្ចេកទេស**

### ៤.៣. ផែនការប្រតិបត្តិ និងថែទាំ

គម្រោងនីមួយៗត្រូវមានផែនការប្រើប្រាស់និងថែទាំ។ គណៈកម្មការគ្រប់គ្រងគម្រោងត្រូវទទួលខុសត្រូវលើការរៀបចំផែនការនេះដោយប្រើប្រាស់ទម្រង់១២។ ផែនការប្រតិបត្តិ និងថែទាំត្រូវចុះហត្ថលេខាដោយមេឃុំនៃឃុំគោលដៅលទ្ធផលគម្រោង តំណាងភ្នាក់ងារទទួលខុសត្រូវក្នុងការប្រើប្រាស់ និងថែទាំ និងអ្នកជំនួយបច្ចេកទេស។

ផែនការប្រើប្រាស់ និងថែទាំត្រូវបង្ហាញអំពី ៖

**១). ការងារប្រើប្រាស់**

- តើមានការងារចាំបាច់អ្វីខ្លះក្នុងការប្រើប្រាស់?
- តើនរណាដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំការងារប្រើប្រាស់នោះ?
- តើការចំណាយទៅលើការងារប្រើប្រាស់នេះបានមកពីណា?

**២). ការងារថែទាំជាប្រចាំ**

- តើមានការងារថែទាំជាប្រចាំអ្វីខ្លះដែលចាំបាច់ត្រូវមាន?
- តើនរណាដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំការងារថែទាំជាប្រចាំនេះ?
- តើចំណាយទៅលើការងារថែទាំជាប្រចាំនេះបានមកពីណា?

**៣). ការងារថែទាំជាខួប**

- តើមានការងារថែទាំជាខួបអ្វីខ្លះដែលចាំបាច់ត្រូវមាន?
- តើនរណាដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំការងារថែទាំជាខួបនេះ?
- តើការចំណាយទៅលើការងារថែទាំជាខួបនេះបានមកពីណា?
- តើតម្លៃជាមធ្យមក្នុងមួយឆ្នាំសម្រាប់ការងារប្រើប្រាស់ និងថែទាំលទ្ធផលគម្រោងចំណាយអស់តម្លៃប៉ុន្មាន?
- តើត្រូវចំណាយប៉ុន្មានពីគម្រោងថវិកាក្រុង ស្រុកក្នុងមួយឆ្នាំ?

**កំណត់សម្គាល់ ÷** ដើម្បីធានាឱ្យមាននិរន្តរភាពនៃលទ្ធផលគម្រោង ទោះបីជាគម្រោងសេវាកម្មក្រុង ស្រុក ផ្តោតជាចម្បងលើគ្រួសារក្រីក្រ និងក្រីក្របំផុតក៏ដោយ ក៏គម្រោងប្រភេទនេះត្រូវមានការចូលរួមបដិភាគពីអ្នកទទួលផល។ ការចូលរួមបដិភាគអាចធ្វើឡើង តាមរយៈការចូលរួមជាកម្លាំងពលកម្ម សម្ភារៈ ទីកន្លែង និងពេលវេលារបស់ក្រុម ឬគ្រួសារគោលដៅនីមួយៗ។ ជាមួយគ្នានេះ អ្នកជំនួយបច្ចេកទេសត្រូវជួយគិតបំលែងអំពីការចូលរួមជាធនធាន និងសម្ភារៈទាំងនោះទៅជាចំនួនទឹកប្រាក់ ដើម្បីបង្ហាញជូនអ្នកទទួលផលអំពីទំហំនៃការចូលរួមរបស់ពួកគាត់។

### ៤.៤. ស្លាកសញ្ញាគម្រោង

ស្លាកសញ្ញាគម្រោង ត្រូវបានដាក់នៅទីតាំងគម្រោង ដើម្បីប្រាប់ប្រជាពលរដ្ឋឱ្យបានដឹងថាអ្នកណាជាម្ចាស់គម្រោង និងអ្នកណាជាអ្នកផ្តល់មូលនិធិ។ ស្លាកសញ្ញាគម្រោងត្រូវរៀបចំឡើងក្នុងរយៈពេល**១៥ថ្ងៃ** បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមអនុវត្តកិច្ចសន្យា។

គ្រប់គម្រោងក្រុង ស្រុកទាំងអស់ដែលបង្កើតបានជាលទ្ធផលស្ថិតនៅជាប់ជាប្រចាំមួយកន្លែង (ដូចជាស្រែបង្ហាញ ឬសួនកសិកម្មចម្រុះ ឬស្រះចិញ្ចឹមត្រីជាដើម) ត្រូវតែមានស្លាកសញ្ញាគម្រោង។ ចំពោះគម្រោងទាំង

ឡាយណាដែលមានត្រឹមតែសកម្មភាពថែទាំជាប្រចាំ ឬគម្រោងសេវាកម្មដែលមិនមានទីតាំងជាប់លាប់ជាប្រចាំមួយកន្លែង (ដូចជា គម្រោងបណ្តុះបណ្តាល ឬគម្រោងទស្សនកិច្ចសិក្សាជាដើម) នោះមិនចាំបាច់ត្រូវមានស្លាកសញ្ញាគម្រោងនៅតាមសកម្មភាពនីមួយៗនោះទេ ប៉ុន្តែក្រុង ស្រុកអាចរៀបចំជាផ្ទាំងបដា ដែលបង្ហាញអំពីគម្រោងនោះតាមការចាំបាច់។

ចំពោះគម្រោងក្រុង ស្រុក ស្លាកសញ្ញាគម្រោងមានមុខងារសំខាន់ណាស់ ដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុង ស្រុកអំពីអ្វីដែលរដ្ឋបាលក្រុង ស្រុកបានធ្វើ។

ព័ត៌មាននៃស្លាកសញ្ញាគម្រោងរួមមាន ៖

- ឈ្មោះក្រុង ស្រុក
- ឈ្មោះគម្រោងទំហំគម្រោង និងឆ្នាំអនុវត្តគម្រោង
- ចំនួនថវិកាពីមូលនិធិក្រុង ស្រុក
- ចំនួនថវិកាចូលរួមចំណែករបស់ប្រជាពលរដ្ឋ
- ចំនួនថវិកាពីប្រភពផ្សេងៗទៀត បើមាន
- ចំនួនថវិកាសរុប។

| | | |
|---|---|---|
| **ក្រុង ស្រុក**...................... | | |
| ....................(*ឈ្មោះគម្រោង*)......................... | | |
| **ឆ្នាំ**............. | | |
| មូលនិធិក្រុង ស្រុក | ៖ | ...................................រៀល |
| ទុនចូលរួមរបស់មូលដ្ឋាន | ៖ | ...................................រៀល |
| ថវិកាពី................. | ៖ | ...................................រៀល |
| សរុប | ៖ | ...................................រៀល |

| | | |
|---|---|---|
| **គម្រោងអន្តររដ្ឋបាលឆ្នាំ**......... | | |
| **រដ្ឋបាល**................. (*ឈ្មោះរដ្ឋបាលពាក់ព័ន្ធ*)................. | | |
| ....................(*ឈ្មោះគម្រោង*)......................... | | |
| មូលនិធិពីរដ្ឋបាល...................... | ៖ | ...................................រៀល |
| មូលនិធិពីរដ្ឋបាល...................... | ៖ | ...................................រៀល |
| មូលនិធិពីរដ្ឋបាល...................... | ៖ | ...................................រៀល |
| ទុនចូលរួមរបស់មូលដ្ឋាន | ៖ | ...................................រៀល |
| ថវិកាពី.................................... | ៖ | ...................................រៀល |
| សរុប | ៖ | ...................................រៀល |

ស្លាកសញ្ញាគម្រោងត្រូវ ៖

- ដាក់នៅកន្លែងប្រជាពលរដ្ឋអាចមើលឃើញនិងអានបាន
- មានគុណភាពល្អដែលធានាបាននូវការប្រើប្រាស់យូរអង្វែង
- ដាក់តាំងនៅទីតាំងលទ្ធផលគម្រោង។

## ឧបសម្ព័ន្ធ ១២ ÷ ផែនការប្រើប្រាស់ និងថែទាំ

| ក្រុង ស្រុក ៖ | | | ការពិពណ៌នាអំពីគម្រោង ៖ | | | | កាលបរិច្ឆេទ ៖ |
|---|---|---|---|---|---|---|---|
| អ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងលទ្ធផលគម្រោង ៖ | | | | | | | |
| **ផែនការអនុវត្ត** | | | | **តម្លៃ និងផែនការផ្តល់ហិរញ្ញវត្ថុ** | | | |
| លរ | សកម្មភាព | ប៉ុន្មានដង | អ្នកធ្វើ | តម្លៃ(គិតជារៀល) | | ប្រភពមូលនិធិ | តម្រូវការផ្សេងៗទៀត |
| | | | | ក្នុង១ដង | ក្នុង១ឆ្នាំ | | |
| **១. ការប្រើប្រាស់** | | | | | | | |
| ១ | | | | | | | |
| ២ | | | | | | | |
| | | | | | | | |
| **២. ការថែទាំជាប្រចាំ** | | | | | | | |
| ១ | | | | | | | |
| ២ | | | | | | | |
| | | | | | | | |
| **៣. ការថែទាំជាខួប** | | | | | | | |
| ១ | | | | | | | |
| ២ | | | | | | | |
| | | | | | | | |
| សរុបតម្លៃក្នុង១ឆ្នាំ | | | | | | | |

**មេឃុំ** **តំណាងភ្នាក់ងារទទួលខុសត្រូវក្នុងការប្រើប្រាស់និងថែទាំ** **អ្នកជំនួយបច្ចេកទេស**

**៤.៥. ការរៀបចំបញ្ចប់គ្រោងការគម្រោងសេវាកម្ម**

បន្ទាប់ពីបានប្រមូលព័ត៌មានសព្វគ្រប់ ហើយអ្នកជំនួយបច្ចេកទេសជួយរៀបចំគ្រោងការគម្រោង។ ចំពោះគម្រោងសេវាកម្ម គ្រោងការគម្រោងរួមមាន ការគ្រោងសកម្មភាពអនុវត្តគម្រោងនានា សេចក្តីលម្អិតបច្ចេកទេស និងគំនូសប្លង់គម្រោង(បើត្រូវការ)។

គ្រោងការគម្រោងមួយដែលល្អនឹងផ្តល់លទ្ធផលចំពោះគម្រោងមួយដែល ៖

- សម្រេចបាននូវគោលបំណង
- មិនថ្លៃពេកក្នុងការអនុវត្ត
- មិនមានការលំបាក ឬថ្លៃពេកក្នុងការប្រើប្រាស់និងថែទាំ
- មិនបណ្តាលឱ្យខូចខាតដល់បរិស្ថាន

អ្នកជំនួយបច្ចេកទេស ជាអ្នកជួយក្នុងការរៀបចំគ្រោងការគម្រោង ហើយគណៈកម្មការគ្រប់គ្រងគម្រោង ជាអ្នកទទួលខុសត្រូវក្នុងការពិនិត្យ និងអនុម័តគ្រោងការគម្រោងនេះ។

# ជំពូកទី៥

# ការបញ្ចប់គ្រោងការគម្រោង

# សេវាកម្មក្រុង ស្រុក

# ជំពូកទី៥
# ការបញ្ចប់គ្រោងការគម្រោងសេវាកម្ម

បន្ទាប់ពីបញ្ចប់ការរៀបចំគ្រោងការគម្រោងសេវាកម្មក្រុង ស្រុក គណៈកម្មការគ្រប់គ្រងគម្រោង និងអ្នកពាក់ព័ន្ធនានាត្រូវចូលរួមសម្របសម្រួល និងអនុវត្តសកម្មភាពសំខាន់ៗមួយចំនួនបន្ថែមទៀត ដើម្បីបញ្ចប់គ្រោងការគម្រោងសេវាកម្ម។ សកម្មភាពសំខាន់ៗទាំងនោះ រួមមាន ៖

- ការពិនិត្យ និងអនុម័តគ្រោងការគម្រោង
- ការពិនិត្យព័ត៌មានគម្រោងដោយទីចាត់ការផែនការ និងវិនិយោគខេត្ត
- ការពិនិត្យបញ្ជាក់បច្ចេកទេស

## ៥.១. ការពិនិត្យ និងអនុម័តគ្រោងការគម្រោង

នៅពេលទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធនានាត្រូវបានរៀបចំចប់សព្វគ្រប់ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងត្រូវរៀបចំកិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង ដើម្បីពិនិត្យ និងអនុម័តគ្រោងការគម្រោង និងដើម្បីធានាឱ្យមានការយល់ដឹងយ៉ាងពេញលេញអំពីគម្រោង និងផលប៉ះពាល់ដែលរំពឹងទុក។ ប្រសិនបើអាចធ្វើបាន ការប្រជុំនេះត្រូវបានរៀបចំឡើងជាសាធារណៈនៅទីតាំងគម្រោង។

គ្រោងការគម្រោងអាចខុសពីគំនិតដំបូងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក។ ក្នុងករណីនេះ មុននឹងគណៈកម្មការគ្រប់គ្រងគម្រោងអនុម័តគ្រោងការគម្រោង ចំណុចសំខាន់ៗមួយចំនួនខាងក្រោមនេះត្រូវបានលើកយកមកពិភាក្សា និងព្រមព្រៀង ៖

- **ការសម្រេចបាននូវគោលដៅរបស់គម្រោង** ៖ ប្រសិនបើ គ្រោងការគម្រោងបានផ្លាស់ប្តូរ តើគម្រោងនឹងនៅតែសម្រេចបាននូវទិសដៅ ដែលបានកំណត់ពីដំបូងដែរឬទេ?
- **ភាពពេញចិត្តរបស់អ្នកទទួលផល** ៖ តើអ្នកទទួលផលនឹងនៅតែពេញចិត្តចំពោះលទ្ធផលគម្រោងដែរឬទេ?
- **តម្លៃ** ៖ តើមានការព្រមព្រៀងទៅលើតម្លៃប៉ាន់ស្មានដែរឬទេ?
- **ផលប៉ះពាល់ផ្នែកបរិស្ថាន** ៖ តើនឹងមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរណាមួយដែរឬទេ?
- **ផែនការប្រើប្រាស់ និងថែទាំ** ៖ តើផែនការប្រើប្រាស់ និងថែទាំមានភាពជាក់ស្តែងដែរឬទេ?
- **ការចូលរួម** ៖ តើអ្នកប្រើប្រាស់គម្រោងនឹងសប្បាយចិត្តក្នុងការបង់ថ្លៃប្រើប្រាស់ និងថែទាំដែរឬទេ?

ក្រៅពីលក្ខណៈវិនិច្ឆ័យ ឬចំណុចពិចារណាខាងលើ គណៈកម្មការគ្រប់គ្រងគម្រោងអាចបង្កើតចំណុចពិចារណា ឬលក្ខណៈវិនិច្ឆ័យផ្សេងទៀត តាមការចាំបាច់។

## ៥.២. ការពិនិត្យព័ត៌មានគម្រោងដោយទីចាត់ការផែនការ និងវិនិយោគខេត្ត

នៅពេលទទួលទម្រង់ព័ត៌មានគម្រោងពីក្រុង ស្រុក ទីចាត់ការផែនការនិងវិនិយោគខេត្តត្រូវពិនិត្យចុះហត្ថលេខា និងបញ្ជូនទៅមន្ទីរជំនាញយ៉ាងយូររយៈពេល១០ថ្ងៃនៃថ្ងៃធ្វើការ។

ព័ត៌មានដែលទីចាត់ការផែនការ និងវិនិយោគត្រូវពិនិត្យមានដូចខាងក្រោម៖

- តើព័ត៌មានចាំបាច់នានានៃគម្រោងនេះមានគ្រប់គ្រាន់ហើយឬនៅ?
- តើគម្រោងនេះស្របទៅតាមផែនការអភិវឌ្ឍន៍ក្រុង ស្រុកដែរឬទេ?

- តើគម្រោងនេះមានលក្ខណៈសមស្របទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងការប្រើប្រាស់មូលនិធិក្រុង ស្រុក ផ្នែកអភិវឌ្ឍន៍ ឬប្រភពថវិកាផ្សេងទៀតដែលគាំទ្រគម្រោងនេះដែរឬទេ?
- តើគម្រោងនេះមានផ្ទុយទៅនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែរឬទេ?
- តើការពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថានរបស់គម្រោងត្រូវបានអនុវត្តទៅតាមនីតិវិធី ដែលមានចែងនៅក្នុងសៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុកដែរឬទេ?

ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវចុះហត្ថលេខាលើទម្រង់ព័ត៌មានគម្រោងនេះ ដើម្បីបង្ហាញថាខ្លួនបានពិនិត្យរាល់ព័ត៌មានបានចប់សព្វគ្រប់។ ការចុះហត្ថលេខានេះមិនមានន័យថាគម្រោងបានទទួលការពិនិត្យបញ្ជាក់បច្ចេកទេសនោះទេ។ មន្ទីរ អង្គភាពជំនាញដែលទទួលខុសត្រូវផ្នែកនេះត្រូវមានឱកាស ដើម្បីពិនិត្យមើលគម្រោងមុនពេលធ្វើការពិនិត្យបញ្ជាក់បច្ចេកទេសបានចប់សព្វគ្រប់។

បន្ទាប់ពីពិនិត្យរួចរាល់ហើយ ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវផ្ញើទម្រង់ព័ត៌មានគម្រោងនិងឯកសារពាក់ព័ន្ធទាំងនោះមួយច្បាប់ទៅមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។

បើត្រូវការការសិក្សាផលប៉ះពាល់បរិស្ថាន ហើយការសិក្សានេះមិនទាន់បានធ្វើនៅឡើយទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវជម្រាបដល់ក្រុង ស្រុក ឱ្យធ្វើការសិក្សាផលប៉ះពាល់បរិស្ថាននេះ។ ប្រសិនបើ ផលប៉ះពាល់ដែលកំណត់នៅក្នុងអំឡុងពេលវិភាគផលប៉ះពាល់បរិស្ថានមានផលប៉ះពាល់ធំ ឬមធ្យម រដ្ឋបាលក្រុង ស្រុកត្រូវរៀបចំផែនការគ្រប់គ្រងបរិស្ថាន។

ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវកត់ត្រាក្នុងសៀវភៅចុះលេខលិខិតចេញចូលនូវ ៖

- កាលបរិច្ឆេទដែលបានទទួលព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធពីក្រុង ស្រុក
- កាលបរិច្ឆេទដែលបានទទួលរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន
- កាលបរិច្ឆេទដែលបានទទួលការពិនិត្យបញ្ជាក់យល់ព្រមពីក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប
- កាលបរិច្ឆេទដែលបានបញ្ជូនឯកសារទាំងអស់នេះទៅមន្ទីរ អង្គភាពជំនាញ ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស
- កាលបរិច្ឆេទដែលទទួលបាននូវការពិនិត្យបញ្ជាក់បច្ចេកទេស។

## ៥.៣. ការពិនិត្យបញ្ជាក់បច្ចេកទេស

ទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវផ្ញើព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធទៅមន្ទីរ អង្គភាពជំនាញ។ មន្ទីរ អង្គភាពជំនាញនឹងធ្វើការពិនិត្យព័ត៌មានគម្រោងទាំងនោះ។

មន្ទីរ អង្គភាពជំនាញមិនមានសិទ្ធិអនុម័តទេ គឺគ្រាន់តែពិនិត្យបញ្ជាក់បច្ចេកទេសប៉ុណ្ណោះ។

មន្ទីរ អង្គភាពជំនាញនឹងបដិសេធចំពោះគម្រោង ប្រសិនបើ ៖

- មានបញ្ហាបច្ចេកទេសលើគ្រោងការគម្រោង ដែលនឹងបណ្តាលឱ្យគម្រោងទទួលបរាជ័យក្នុងការសម្រេចនូវទិសដៅគម្រោងឬ
- មានភាពត្រួតស៊ីគ្នារវាងគម្រោងសេវាកម្មរបស់រដ្ឋបាលក្រុង ស្រុក ជាមួយគម្រោងរបស់អង្គការសង្គមស៊ីវិល ឬគម្រោងរបស់មន្ទីរជំនាញ។ ឧទាហរណ៍ ៖ ស្រុកបានរៀបចំគម្រោងរៀបចំយុទ្ធនាការផ្សព្វផ្សាយការចុះឈ្មោះចូលរៀនរបស់កុមារ ជាមួយគ្នានេះ មន្ទីរអប់រំ យុវជន និងកីឡា ក៏មានផែនការរៀបចំយុទ្ធនាការផ្សព្វផ្សាយការចុះឈ្មោះចូលរៀនរបស់កុមារនៅទូទាំងខេត្តផងដែរ។

ក្នុងករណីនេះ មន្ទីរអប់រំ យុវជន និងកីឡាត្រូវពិភាក្សាជាមួយរដ្ឋបាលក្រុង ស្រុកសាមី ដើម្បីសម្រប សម្រួលការរៀបចំ និងអនុវត្តគម្រោងនេះ។

មន្ទីរ អង្គភាពជំនាញមានសិទ្ធិជំទាស់ចំពោះគម្រោងក្នុងរយៈពេល**១៥ថ្ងៃ** បន្ទាប់ពីទទួលបានទម្រង់ព័ត៌មានគម្រោងពីទីចាត់ការផែនការ និងវិនិយោគខេត្ត។ ប្រសិនបើមន្ទីរ អង្គភាពជំនាញចង់ធ្វើការជំទាស់ ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅទីចាត់ការផែនការ និងវិនិយោគខេត្ត ហើយទីចាត់ការផែនការ និងវិនិយោគខេត្តត្រូវជូនដំណឹងទៅក្រុង ស្រុក។

ប្រសិនបើ ក្នុងរយៈពេល១៥ថ្ងៃ មន្ទីរ អង្គភាពជំនាញមិនធ្វើការជំទាស់ទេ នោះមានន័យថាគម្រោងបានទទួលការពិនិត្យបញ្ជាក់បច្ចេកទេសដោយស្វ័យប្រវត្តិ។

ចំពោះគម្រោងដែលតម្រូវឱ្យមានការវិភាគផលប៉ះពាល់បរិស្ថាន គម្រោងនោះត្រូវចាត់ទុកថា មានការជំទាស់ដោយស្វ័យប្រវត្តិ រហូតទាល់តែមានការរៀបចំចប់សព្វគ្រប់ ព្រមទាំងទទួលបានការអនុម័តនូវរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន។ ការជំទាស់ដោយស្វ័យប្រវត្តិទាំងនេះនឹងត្រូវដកចេញ នៅពេលណាដែលរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានត្រូវបានអនុម័ត។

ទីចាត់ការផែនការ និងវិនិយោគខេត្ត ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅក្រុង ស្រុក(**ទម្រង់ទី១៣**) នៅពេលគម្រោងទទួលបាននូវការពិនិត្យបញ្ជាក់បច្ចេកទេស។

សេចក្ដីជូនដំណឹងអំពីការពិនិត្យបញ្ជាក់បច្ចេកទេស និងផែនទីគម្រោងត្រូវបានរក្សាទុកក្នុងសំណុំឯកសារគម្រោងនៅសាលាក្រុង ស្រុក។ ចំពោះគម្រោងអន្តររដ្ឋបាល សេចក្ដីជូនដំណឹងនេះច្បាប់ដើមរក្សាទុកនៅការិយាល័យនៃប្រធានគណៈកម្មការគ្រប់គ្រងគម្រោង ហើយច្បាប់ថតចម្លងរក្សាទុកនៅតាមរដ្ឋបាលដែលពាក់ព័ន្ធគម្រោងនោះ។

## ទម្រង់ទី១៣ ÷ សេចក្តីជូនដំណឹងស្តីពីការពិនិត្យបញ្ជាក់បច្ចេកទេស

<table>
<tr><td>ខេត្ត ៖</td><td>ក្រុង ស្រុក ៖</td><td>លេខកូដ ៖</td></tr>
<tr><td colspan="3">ឈ្មោះគម្រោង ៖</td></tr>
<tr><td colspan="2">កាលបរិច្ឆេទដាក់ជូនព័ត៌មានគម្រោងនិងឯកសារពាក់ព័ន្ធទៅទីចាត់ការផែនការនិងវិនិយោគខេត្ត</td><td></td></tr>
<tr><td colspan="2">កាលបរិច្ឆេទផ្ញើរបាយការណ៍វិភាគបរិស្ថានទៅលេខាធិការដ្ឋាន គ.ជ.អ.ប<br>ថ្ងៃទី........ខែ.............ឆ្នាំ..........<br>តើលេខាធិការដ្ឋាន គ.ជ.អ.ប បានឆ្លើយតបក្នុងអំឡុងពេល១០ថ្ងៃ?<br>☐ទេមិនបានឆ្លើយតប ☐បាទបានយល់ព្រម ☐បាទបានជំទាស់</td><td>មិនចាំបាច់ផ្ញើទៅ<br>លេខាធិការដ្ឋាន គ.ជ.អ.ប<br>☐</td></tr>
<tr><td colspan="2">កាលបរិច្ឆេទដាក់ជូនរបាយការណ៍វិភាគបរិស្ថានទៅមន្ទីរបរិស្ថាន<br>ថ្ងៃទី..........ខែ................ឆ្នាំ...............<br>តើមន្ទីរបរិស្ថានបានឆ្លើយតបក្នុងអំឡុងពេល១៥ថ្ងៃ?<br>☐ទេមិនបានឆ្លើយតប ☐បាទបានយល់ព្រម ☐បាទបានជំទាស់</td><td>មិនចាំបាច់ធ្វើការវិភាគបរិស្ថាន<br>☐</td></tr>
<tr><td colspan="2">មន្ទីរជំនាញទទួលខុសត្រូវក្នុងការពិនិត្យបញ្ជាក់បច្ចេកទេស</td><td></td></tr>
<tr><td colspan="2">កាលបរិច្ឆេទដាក់ជូនព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធទៅមន្ទីរជំនាញ<br>តើមន្ទីរ អង្គភាពជំនាញបានឆ្លើយតបក្នុងអំឡុងពេល១៥ថ្ងៃ?<br>☐ទេមិនបានឆ្លើយតប ☐បាទបានយល់ព្រម ☐បាទបានជំទាស់</td><td></td></tr>
<tr><td colspan="3">ការពិនិត្យបញ្ជាក់បច្ចេកទេសសម្រាប់គម្រោងនេះបានបញ្ចប់ គណៈកម្មការគ្រប់គ្រងគម្រោងអាចចាប់ផ្តើមដំណើរការលទ្ធកម្មបាន។</td></tr>
</table>

ថ្ងៃទី...... ខែ.......... ឆ្នាំ..........

**ទីចាត់ការផែនការ និងវិនិយោគខេត្ត**

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## ឯកសារជំនួយស្មារតីអំពីកម្រិតអប្បបរមានៃលក្ខណៈបច្ចេកទេស

## គម្រោងសេវាកម្មសម្រាប់ជាមូលដ្ឋានក្នុងការគណនាតម្លៃឯកតាស្មាន

| ល.រ | ឈ្មោះគម្រោង | កម្រិតតម្រូវការអប្បបរមាតាមលក្ខណៈបច្ចេកទេស |
|---|---|---|
| ១ | គម្រោងចិញ្ចឹមប្រចៀវ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– ស្លឹកត្នោត<br>– ដើមឫស្សីអង្កត់ផ្ចិត១០សម ប្រវែង៨ម៉ែត្រ<br>– ដើមត្នោតកម្ពស់ប្រហែល៨ម<br>– លួសចំណង<br>– បង្គោលស៊ីម៉ង់ត៍ទំហំ ២០សម x ២០សម x ៥ម៉ែត្រ<br>– ស្លាកសញ្ញាគម្រោង ៦០សម x ៨០សម |
| ២ | គម្រោងចិញ្ចឹមមាន់ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– មាន់ពូជទម្ងន់យ៉ាងតិច១.៤គីឡូក្រាម<br>– វ៉ាក់សាំងការពារជំងឺ(ញូកាសអេហ្វកូលេរ៉ានិងអាសន្នរោគបក្សី)<br>– សំណាញ់នីឡុងក្រឡា៤សម<br>– ទ្រុង<br>– ចំណី<br>– ស្លាកសញ្ញាគម្រោង |
| ៣ | គម្រោងចិញ្ចឹមជ្រូក | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– ជ្រូកពូជយ៉កសៀទម្ងន់យ៉ាងតិច១០គីឡូក្រាម<br>– វ៉ាក់សាំងការពារជំងឺបួនមុខ ដូចជា អូយេស្គី ប៉េស្តរាគ និងសាទឹកជ្រូក<br>– ទ្រុង (ឈើ និងសម្ភារៈសាងសង់ទ្រុង)<br>– ចំណី<br>– ស្លាកសញ្ញាគម្រោង |
| ៤ | គម្រោងចិញ្ចឹមកង្កែប | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– ពូជកង្កែប<br>– ស្បៃមុង/ផ្លាស់ស្ទិច<br>– ស្រះ<br>– ចំណី<br>– ស្លាកសញ្ញាគម្រោង |

| ល.រ | ឈ្មោះគម្រោង | កម្រិតតម្រូវការអប្បបរមាតាមលក្ខណៈបច្ចេកទេស |
|---|---|---|
| ៥ | គម្រោងចិញ្ចឹមត្រី | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– កូនត្រីប្រវែងជងខ្លួន៣សម ទៅ៥សម<br>– ស្រះ<br>– កំបោរ<br>– ជីអ៊ុយរ៉េ និងជីដេអាប៉េ<br>– ចំណី<br>– ស្លាកសញ្ញាគម្រោង |
| ៦ | គម្រោងដាំបន្លែលក្ខណៈគ្រួសារ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– គ្រាប់ពូជបន្លែដែលមានគុណភាពល្អ<br>– ប៉ោតស្រោចបន្លែចំណុះ១៥លីត្រ<br>– ជីកំប៉ុស្ត<br>– ថ្នាំសម្លាប់សត្វល្អិត<br>– ស្លាកសញ្ញាគម្រោង |
| ៧ | គម្រោងដាំផ្សិតលក្ខណៈគ្រួសារ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– កញ្ចប់មេផ្សិតទម្ងន់១.៥គីឡូក្រាម<br>– ស្បូវ ឬស្លឹកត្នោតប្រក់រោងបណ្តុះផ្សិត<br>– ការសាងសង់រោងបណ្តុះផ្សិត<br>– ខ្សែចំណង<br>– ស្លាកសញ្ញាគម្រោង |
| ៨ | គម្រោងសិប្បកម្ម និងការសន្សំប្រាក់ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– សម្ភារៈសម្រាប់ការធ្វើបង្ហាញ<br>– ឧបករណ៍សម្រាប់អនុវត្ត<br>– ទុនបង្វិល<br>– ស្លាកសញ្ញាគម្រោង |
| ៩ | គម្រោងកសិកម្មចម្រុះជ្រូក - មាន់ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– ជ្រូកពូជយ៉កសៀទម្ងន់យ៉ាងតិច១០គីឡូក្រាម<br>– មាន់ពូជទម្ងន់យ៉ាងតិច១.៤គីឡូក្រាម<br>– វ៉ាក់សាំងការពារជំងឺបួនមុខ ដូចជា អូយេស្គី ប៉េស្ត រាគ និងសាទឹកជ្រូក<br>– វ៉ាក់សាំងការពារជំងឺ(ញូកាសអេហ្វកូលេរ៉ា និងអាសន្នរោគបក្សី) |

| ល.រ | ឈ្មោះគម្រោង | កម្រិតតម្រូវការអប្បបរមាតាមលក្ខណៈបច្ចេកទេស |
|---|---|---|
| | | – សំណាញ់នីឡុងក្រឡា៤សម<br>– ទ្រុង<br>– ចំណី |
| ១០ | គម្រោងកសិកម្មចម្រុះ ជ្រូក - បន្លែ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– ជ្រូកពូជយ៉កសៀទម្ងន់យ៉ាងតិច១០គីឡូក្រាម<br>– វ៉ាក់សាំងការពារជំងឺបួនមុខ ដូចជា អូយេស្គី ប៉េស្ត រាគ និងសាទឹកជ្រូក<br>– គ្រាប់ពូជបន្លែដែលមានគុណភាពល្អ<br>– ប៉ោតស្រោចបន្លែចំណុះ១៥លីត្រ<br>– ជីកំប៉ុស្ត<br>– ថ្នាំសម្លាប់សត្វល្អិត<br>– ទ្រុង<br>– ចំណី |
| ១១ | គម្រោងកសិកម្មចម្រុះ ត្រី-បន្លែ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– កូនត្រីប្រវែងដងខ្លួន៣ ទៅ ៥សម<br>– ស្រះ<br>– កំបោរ<br>– ជីអ៊ុយរ៉េ និងជីដេអាប៉េ<br>– ចំណី<br>– គ្រាប់ពូជបន្លែដែលមានគុណភាពល្អ<br>– ប៉ោតស្រោចបន្លែចំណុះ១៥លីត្រ<br>– ជីកំប៉ុស្ត<br>– ថ្នាំសម្លាប់សត្វល្អិត<br>– ស្លាកសញ្ញាគម្រោង |
| ១២ | គម្រោងកសិកម្មចម្រុះ ត្រី-ស្រូវ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– កូនត្រីប្រវែងដងខ្លួន៣ ទៅ៥សម<br>– ជីអ៊ុយរ៉េ និងជីដេអាប៉េ<br>– ចំណី<br>– ពូជស្រូវគុណភាពល្អ<br>– ជីកំប៉ុស្ត<br>– ស្លាកសញ្ញាគម្រោង |

| ល.រ | ឈ្មោះគម្រោង | កម្រិតតម្រូវការអប្បបរមាតាមលក្ខណៈបច្ចេកទេស |
|---|---|---|
| ១៣ | គម្រោងកសិកម្មចម្រុះ ត្រី-ស្រូវ-បន្លែ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– កូនត្រីប្រវែងដងខ្លួន ៣ ទៅ ៥សម<br>– ជីអ៊ុយរ៉េ និងជីដេអាប៉េ<br>– ចំណី<br>– ពូជស្រូវដែលគុណភាពល្អ<br>– ពូជបន្លែដែលមានគុណភាពល្អ<br>– ជីកំប៉ុស្ត<br>– ខ្សែសិន<br>– ស្លាកសញ្ញាគម្រោង |
| ១៤ | គម្រោងកសិកម្មចម្រុះ ត្រី-ជ្រូក-បន្លែ | ក). ការបណ្តុះបណ្តាលកសិករ<br>ខ). ការធ្វើបង្ហាញ<br>– ជ្រូកពូជយ៉កសៀទម្ងន់យ៉ាងតិច១០គីឡូក្រាម<br>– វ៉ាក់សាំងការពារជំងឺបួនមុខ ដូចជា អូយេស្គី ប៉េស្ត រាគ និងសាទឹកជ្រូក<br>– ចំណីជ្រូក<br>– ទ្រុងជ្រូក<br>– គ្រាប់ពូជបន្លែដែលមានគុណភាពល្អ<br>– ប៉ោតស្រោចបន្លែចំណុះ១៥លីត្រ<br>– ជីកំប៉ុស្ត<br>– ថ្នាំសម្លាប់សត្វល្អិត<br>– កូនត្រីប្រវែងដងខ្លួន ៣ ទៅ៥សម<br>– ជីអ៊ុយរ៉េ និងជីដេអាប៉េ<br>– ចំណីត្រី<br>– ស្លាកសញ្ញាគម្រោង |
| ១៥ | គម្រោងរៀបចំសហគមន៍នេសាទ | ក). ការស្នើសុំបង្កើតសហគមន៍នេសាទ<br>– បង្កើតក្រុមស្ថាបនិក<br>– រៀបចំ និងដាក់ពាក្យស្នើសុំបង្កើត<br>– ការបណ្តុះបណ្តាលក្រុមស្ថាបនិក<br>ខ). ការវាយតម្លៃសក្តានុពលក្នុងការបង្កើត<br>– រៀបចំផែនការសិក្សា<br>– ប្រមូលឯកសារពាក់ព័ន្ធ<br>– ប្រមូលព័ត៌មានពីអ្នកពាក់ព័ន្ធ<br>– ចុះអង្កេតអំពីសក្តានុពលធនធានជលផល<br>– រៀបចំរបាយការណ៍ និងផ្សព្វផ្សាយ |

| ល.រ | ឈ្មោះគម្រោង | កម្រិតតម្រូវការអប្បបរមាតាមលក្ខណៈបច្ចេកទេស |
|---|---|---|
| | | គ). បង្កើនការយល់ដឹងអំពីសហគមន៍នេសាទ<br>– បណ្តុះបណ្តាលប្រជានេសាទអំពីក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋាន<br>ឃ). ការចុះបញ្ជីសមាជិកសហគមន៍នេសាទ<br>– ចុះបញ្ជីឈ្មោះ<br>– ដាក់បញ្ជីឈ្មោះជូនក្រុមប្រឹក្សាឃុំពិនិត្យ<br>ង). ការរៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>– រៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈ<br>– ពិនិត្យ និងកែសម្រួលសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈ<br>ច). ការកំណត់ព្រំប្រទល់សហគមន៍នេសាទ<br>– កំណត់ព្រំប្រទល់នេសាទដោយប្រើGPS<br>– ផលិតផែនទី<br>– ពិនិត្យកែសម្រួលសេចក្តីព្រាងផែនទី<br>ឆ). រៀបចំសមាជសហគមន៍នេសាទ<br>– ប្រជុំជាមួយក្រុមស្ថាបនិក និងអាជ្ញាធរមូលដ្ឋាន<br>– បណ្តុះបណ្តាលក្រុមស្ថាបនិកអំពីការរៀបចំសមាជ<br>– រៀបចំរចនាសម្ព័ន្ធ និងបោះឆ្នោតជ្រើសរើស<br>– សេចក្តីសម្រេចទទួលស្គាល់សមាសភាព<br>ជ). ការរៀបចំផែនការគ្រប់គ្រងសហគមន៍នេសាទ<br>– បណ្តុះបណ្តាលគណៈកម្មការគ្រប់គ្រង<br>– កំណត់ដែននេសាទ និងតំបន់អភិរក្ស<br>– សិក្សាអំពីតម្រូវការប្រើប្រាស់<br>– រៀបចំនិងឯកភាពលើផែនការគ្រប់គ្រង<br>– ផ្សព្វផ្សាយផែនការគ្រប់គ្រង |

**បញ្ជាក់ ÷** ជាទូទៅព័ត៌មានបច្ចេកទេសគម្រោងសេវាកម្មអាចមានលក្ខណៈខុសប្លែកៗពីគ្នា ទោះបីគម្រោងមានឈ្មោះដូចគ្នាក៏ដោយ អាស្រ័យលើមេរៀន បទពិសោធន៍របស់អ្នករៀបចំគម្រោង។ ដូច្នេះ ក្នុងការជ្រើសរើសអ្នកទទួលការអនុវត្តគម្រោង រដ្ឋបាលក្រុង ស្រុក គួរស្នើឱ្យអង្គការសង្គមស៊ីវិល វិស័យឯកជន ឬអ្នកពាក់ព័ន្ធនានារៀបចំសំណើគម្រោង ដើម្បីឱ្យក្រុង ស្រុកពិនិត្យសម្រេច ជាជាងការប្រកាសដេញថ្លៃដូចគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

# ឧបសម្ព័ន្ធទី២
## បញ្ជីលេខកូដលទ្ធផលគម្រោងស្តង់ដារសម្រាប់គម្រោងសេវាកម្ម

| លេខកូដ | ការពិពណ៌នា | ឯកតា |
|---|---|---|
| **2010000** | **កសិកម្ម** | |
| **2010100** | **កេរ្សិត្រសាស្ត្រ** | |
| 2010101 | បណ្តុះបណ្តាលអំពីស្រែប្រពលវប្បកម្ម | វគ្គ |
| 2010102 | ការបង្ហាញអំពីប្រពលវប្បកម្មដំណាំស្រូវ | បង្ហាញ |
| 2010103 | សាលារៀនស្រែកសិករអំពីប្រពលវប្បកម្មស្រូវ | សាលា |
| 2010104 | សាលារៀនស្រែកសិករអំពីការដាំស្រូវតាមគោលការណ៍ធម្មជាតិ | សាលា |
| 2010105 | ការធ្វើបង្ហាញអំពីការដាំស្រូវតាមគោលការណ៍ធម្មជាតិ | បង្ហាញ |
| 2010106 | បណ្តុះបណ្តាលអំពីការបន្សុទ្ធពូជស្រូវ | វគ្គ |
| 2010107 | សហគមន៍ធនាគារស្រូវពូជ | ក្រុម |
| 2010108 | សាលារៀនស្រែកសិករអំពីដំណាំស្រូវ | សាលា |
| 2010109 | ការបំពាក់សម្ភារៈកែច្នៃអង្ករ | កំប្លេ |
| 2010110 | សហករណ៍កែច្នៃអង្ករ | សហករណ៍ |
| 2010111 | បណ្តុះបណ្តាលអំពីប្រព័ន្ធកសិកម្មចម្រុះ | វគ្គ |
| 2010112 | ការផលិតពូជដំណាំជាលក្ខណៈគ្រួសារ | កន្លែង |
| 2010113 | សហករណ៍កែច្នៃផលិតផលដំណាំ | សហករ |
| 2010114 | បណ្តុះបណ្តាលអំពីការផលិតពូជផ្សិត | វគ្គ |
| 2010115 | បណ្តុះបណ្តាលអំពីការដាំផ្សិត | វគ្គ |
| 2010116 | ការធ្វើបង្ហាញអំពីការបណ្តុះផ្សិត | បង្ហាញ |
| 2010117 | បណ្តុះបណ្តាលអំពីការដាំដំណាំ | វគ្គ |
| 2010118 | បណ្តុះបណ្តាលអំពីការដាំដំណាំឆ្លាស់ | វគ្គ |
| 2010119 | ការធ្វើបង្ហាញអំពីការដាំដំណាំឆ្លាស់ | បង្ហាញ |
| 2010120 | ការបណ្តុះបណ្តាលអំពីការដាំបន្លែ | វគ្គ |
| 2010121 | សាលារៀនស្រែអំពីបន្លែ | សាលា |
| 2010122 | ការធ្វើបង្ហាញអំពីការដាំបន្លែ | បង្ហាញ |
| 2010123 | ការបំពាក់សម្ភារៈកែច្នៃបន្លែ | កំប្លេ |
| 2010124 | សហករណ៍កែច្នៃបន្លែ | សហករណ៍ |
| 2010125 | ការធ្វើបង្ហាញអំពីការធ្វើថ្នាំកំចាត់សត្វល្អិត | បង្ហាញ |
| 2010126 | សហករណ៍កែច្នៃឈើហូបផ្លែ | សហករណ៍ |
| 2010127 | ការបណ្តុះបណ្តាលអំពីបច្ចេកទេសដាំឈើហូបផ្លែ | វគ្គ |
| 2010128 | ថ្នាលបណ្តុះកូនឈើហូបផ្លែ | ថ្នាល |
| 2010129 | ការធ្វើបង្ហាញអំពីការកែច្នៃឈើហូបផ្លែ | បង្ហាញ |

| លេខកូដ | ការពិពណ៌នា | ឯកតា |
|---|---|---|
| 2010130 | ការធ្វើបង្ហាញអំពីការដាំដំណាំឈើហូបផ្លែ | បង្ហាញ |
| 2010131 | សាលារៀនស្រែអំពីឈើហូបផ្លែ | សាលា |
| 2010132 | ការធ្វើបង្ហាញអំពីដំណាំប្រាក់ចំណូល | បង្ហាញ |
| 2010133 | ការបណ្តុះបណ្តាលអំពីវិធានការចម្រុះថែទាំដំណាំ | វគ្គ |
| 2010134 | ការបណ្តុះបណ្តាលអំពីការគ្រប់គ្រងសំណឹកដី | វគ្គ |
| 2010135 | ការធ្វើបង្ហាញអំពីការគ្រប់គ្រងការហូរច្រោះដី | បង្ហាញ |
| 2010136 | ការបណ្តុះបណ្តាលអំពីបច្ចេកទេសកែលម្អដី | វគ្គ |
| 2010137 | ការធ្វើរោងជីកំប៉ុស្ត | កន្លែង |
| 2010138 | ការបណ្តុះបណ្តាលអំពីការប្រើប្រាស់ថ្នាំពុលឱ្យបានសមស្រប | វគ្គ |
| 2010139 | សាលារៀនស្រែកសិករអំពីកសិកម្មចម្រុះ | សាលា |
| 2010140 | ការបំពាក់ឧបករណ៍កែច្នៃម្ហូបអាហារ | កន្លែង |
| 2010141 | ការបណ្តុះបណ្តាលអំពីបច្ចេកទេសដាំកៅស៊ូ | វគ្គ |
| 2010142 | ថ្នាលបណ្តុះកូនកៅស៊ូ | ថ្នាល |
| 2010143 | ការធ្វើបង្ហាញអំពីការដាំកៅស៊ូលក្ខណៈគ្រួសារ | បង្ហាញ |
| 2010144 | សហគមន៍ធនាគារកូនកៅស៊ូ | ក្រុម |
| 2010199 | គម្រោងការងារក្សេត្រសាស្ត្រផ្សេងទៀត | |
| **2010200** | **បសុព្យាបាល** | |
| 2010201 | សហគមន៍ធនាគារជ្រូក | ក្រុម |
| 2010202 | ការបង្កើតឱសថស្ថានពេទ្យសត្វ | កន្លែង |
| 2010203 | ការភ្ញាស់កូនមាន់/ទាជាលក្ខណៈគ្រួសារ | កន្លែង |
| 2010204 | ការបណ្តុះបណ្តាលអំពីការផលិតចំណីសត្វ | វគ្គ |
| 2010205 | ការបណ្តុះបណ្តាលពេទ្យសត្វភូមិ | វគ្គ |
| 2010206 | ការបណ្តុះបណ្តាលអំពីការចញ្ចឹមមាន់/ទា | វគ្គ |
| 2010207 | ការបណ្តុះបណ្តាលអំពីការចិញ្ចឹមគោ/ក្របី | វគ្គ |
| 2010208 | ការបណ្តុះបណ្តាលអំពីការចិញ្ចឹមជ្រូក | វគ្គ |
| 2010209 | ការធ្វើបង្ហាញអំពីការចិញ្ចឹមមាន់/ទា | បង្ហាញ |
| 2010210 | ការធ្វើបង្ហាញអំពីការចិញ្ចឹមគោ/ក្របី | បង្ហាញ |
| 2010211 | ការធ្វើបង្ហាញអំពីការផលិតចំណីសត្វ | បង្ហាញ |
| 2010212 | ក្រុមកសិករចិញ្ចឹមជ្រូក | ក្រុម |
| 2010213 | ការធ្វើបង្ហាញអំពីការចិញ្ចឹមជ្រូក | បង្ហាញ |
| 2010214 | ការចែកសម្ភារៈដល់ពេទ្យសត្វភូមិ | កំប្លេ |
| 2010215 | យុទ្ធនាការចាក់វ៉ាក់សាំង | លើក |
| 2010216 | ការបង្កើតពេទ្យសត្វភូមិ | នាក់ |

| លេខកូដ | ការពិពណ៌នា | ឯកតា |
|---|---|---|
| 2010217 | គម្រោងបង្កើនការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ | |
| 2010299 | គម្រោងការងារបសុព្យាបាលផ្សេងទៀត | |
| **2010300** | **ព្រៃឈើ** | |
| 2010301 | ការបង្កើនការយល់ដឹងអំពីសារៈសំខាន់ព្រៃឈើ | វគ្គ |
| 2010302 | រចនាសម្ព័ន្ធសហគមន៍ព្រៃឈើ | គណៈកម្មការ |
| 2010303 | រចនាសម្ព័ន្ធសហគមន៍អភិរក្សសត្វព្រៃ | គណៈកម្មការ |
| 2010304 | រចនាសម្ព័ន្ធសហគមន៍ចិញ្ចឹមប្រចៀវ | គណៈកម្មការ |
| 2010305 | កិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ | កិច្ចព្រមព្រៀង |
| 2010306 | ការរៀបចំលក្ខន្តិកៈសហគមន៍ព្រៃឈើ | លក្ខន្តិកៈ |
| 2010307 | បទបញ្ជាផ្ទៃក្នុងសហគមន៍ព្រៃឈើ | លក្ខន្តិកៈ |
| 2010308 | ការធ្វើបង្ហាញអំពីការចិញ្ចឹមប្រចៀវ | បង្ហាញ |
| 2010309 | ការបណ្តុះបណ្តាលអំពីការចិញ្ចឹមឃ្មុំ | វគ្គ |
| 2010310 | ការធ្វើបង្ហាញអំពីការចិញ្ចឹមឃ្មុំ | បង្ហាញ |
| 2010311 | ការធ្វើផ្លូវភ្លើង | គីឡូម៉ែត្រ |
| 2010312 | ការគ្រប់គ្រងតំបន់ឃ្វាលសត្វ | ហិកតា |
| 2010313 | សហគមន៍កែច្នៃរំពាក់ | សហគមន៍ |
| 2010314 | ការបណ្តុះបណ្តាលអំពីការបង្កើតសហគមន៍ព្រៃឈើ | វគ្គ |
| 2010315 | ការបណ្តុះបណ្តាលអំពីកសិរុក្ខកម្ម | វគ្គ |
| 2010316 | ការបណ្តុះបណ្តាលអំពីច្បាប់ព្រៃឈើ និងអនុក្រឹត្យសហគមន៍ព្រៃឈើ | វគ្គ |
| 2010317 | ការបណ្តុះបណ្តាលអំពីការគ្រប់គ្រងរុក្ខជាតិឱសថ | វគ្គ |
| 2010318 | ការបណ្តុះបណ្តាលអំពីការដាំឈើ | វគ្គ |
| 2010319 | ផែនទីសហគមន៍ព្រៃឈើ | ផែនទី/ផ្ទាំង |
| 2010320 | ផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ | ផែនការ |
| 2010321 | ការបង្កើតឡូត៍ដាំឈើធ្វើអុស | ហិកតា |
| 2010322 | ការបោះបង្គោលព្រំព្រៃឈើ | បង្គោល |
| 2010323 | ការត្រួតពិនិត្យតំបន់សហគមន៍ព្រៃឈើ | លើក |
| 2010324 | យុទ្ធនាការទប់ស្កាត់ការកាប់ដើមត្នោត | យុទ្ធនាការ |
| 2010325 | សមាគម/បណ្តាញស្ករត្នោត | សហគមន៍ |
| 2010326 | ការល្បាតការធ្វើពាណិជ្ជកម្មសត្វព្រៃ | លើក/លើក |
| 2010327 | ថ្នាលបណ្តុះកូនឈើ | ថ្នាល |
| 2010328 | ការដាំឈើឡើងវិញ | ហ.ត |
| 2010329 | ការបណ្តុះបណ្តាលអំពីការកែច្នៃរពាក់ | វគ្គ |
| 2010330 | ការបណ្តុះបណ្តាលអំពីការប្រមូលអនុផលព្រៃឈើប្រកបដោយនិរន្តភាព | វគ្គ |

| លេខកូដ | ការពិពណ៌នា | ឯកតា |
|---|---|---|
| 2010399 | គម្រោងការងារព្រៃឈើផ្សេងទៀត | |
| **2010400** | **ជលផល** | |
| 2010401 | ការបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃធនធានជលផល | បង្ហាញ |
| 2010402 | បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | លក្ខន្តិកៈ |
| 2010403 | ការរៀបចំលក្ខន្តិកៈសហគមន៍នេសាទ | លក្ខន្តិកៈ |
| 2010404 | រចនាសម្ព័ន្ធសហគមន៍ការពារព្រៃកោងកាង | គណៈកម្មការ |
| 2010405 | រចនាសម្ព័ន្ធសហគមន៍គ្រប់គ្រងបឹង អូរ... | គណៈកម្មការ |
| 2010406 | រចនាសម្ព័ន្ធសហគមន៍នេសាទ | គណៈកម្មការ |
| 2010407 | ផែនទីដែនសហគមន៍នេសាទ | ផែនទី |
| 2010408 | កិច្ចព្រមព្រៀងសហគមន៍នេសាទ | កិច្ចព្រមព្រៀង |
| 2010409 | ផែនការគ្រប់គ្រងសហគមន៍នេសាទ | ផែនការ |
| 2010410 | សហគមន៍ធនាគារក្តាម | ក្រុម |
| 2010411 | ការបណ្តុះបណ្តាលអំពីការភ្ញាស់កូនត្រី | បង្ហាញ |
| 2010412 | ការភ្ញាស់ត្រីលក្ខណៈគ្រួសារ | កន្លែង |
| 2010413 | ការចិញ្ចឹមក្តាមតាមបែបធម្មជាតិ | សហគមន៍ |
| 2010414 | ការបណ្តុះបណ្តាលអំពីការបង្កើតសហគមន៍នេសាទ | វគ្គ |
| 2010415 | បណ្តុះបណ្តាលអំពីការចិញ្ចឹមក្តាម | វគ្គ |
| 2010416 | បណ្តុះបណ្តាលអំពីការចិញ្ចឹមត្រីក្នុងស្រែ | វគ្គ |
| 2010417 | បណ្តុះបណ្តាលអំពីការកែច្នៃត្រី | វគ្គ |
| 2010418 | បណ្តុះបណ្តាលអំពីច្បាប់ជលផល និងអនុក្រឹត្យសហគមន៍នេសាទ | វគ្គ |
| 2010419 | បណ្តុះបណ្តាលអំពីការចិញ្ចឹមកង្កែបជាលក្ខណៈគ្រួសារ | វគ្គ |
| 2010420 | បណ្តុះបណ្តាលអំពីការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ | វគ្គ |
| 2010421 | បណ្តុះបណ្តាលអំពីការដាំព្រៃលិចទឹក | វគ្គ |
| 2010422 | បណ្តុះបណ្តាលអំពីការចិញ្ចឹមក្រពើ | វគ្គ |
| 2010423 | បណ្តុះបណ្តាលអំពីការចិញ្ចឹមគ្រុំ | វគ្គ |
| 2010424 | បណ្តុះបណ្តាលអំពីការចិញ្ចឹមគ្រែង | វគ្គ |
| 2010425 | បណ្តុះបណ្តាលអំពីការចិញ្ចឹមបង្គារ | វគ្គ |
| 2010426 | ការធ្វើបង្ហាញអំពីការចិញ្ចឹមបង្គារ | បង្ហាញ |
| 2010427 | ការធ្វើបង្ហាញអំពីការចិញ្ចឹមក្តាម | បង្ហាញ |
| 2010428 | ការធ្វើបង្ហាញអំពីការចិញ្ចឹមគ្រុំ | បង្ហាញ |
| 2010429 | ការធ្វើបង្ហាញអំពីការចិញ្ចឹមគ្រែង | បង្ហាញ |
| 2010430 | ការធ្វើបង្ហាញអំពីការចិញ្ចឹមត្រី | បង្ហាញ |

| លេខកូដ | ការពិពណ៌នា | ឯកតា |
|---|---|---|
| 2010431 | ការធ្វើបង្ហាញអំពីការចិញ្ចឹមកង្កែប | បង្ហាញ |
| 2010432 | ការធ្វើបង្ហាញអំពីការចិញ្ចឹមក្រពើ | បង្ហាញ |
| 2010433 | ការកែច្នៃផលនេសាទ | គ្រួសារ |
| 2010434 | ទិវាប្រលែងកូនត្រី | កូនត្រី |
| 2010435 | ទីផ្សារត្រីសហគមន៍ | កន្លែង |
| 2010436 | ការដាំឈើព្រៃលិចទឹក | ហិកតា |
| 2010437 | សហគមន៍ដាំស្មៅសមុទ្រ | ហិកតា |
| 2010438 | ការអភិរក្សតំបន់ស្មៅសមុទ្រ | ហិកតា |
| 2010439 | ការដាំដើមកោងកាង | ហិកតា |
| 2010440 | ការដាំឬស្សីការពារច្រាំងស្ទឹង | គីឡូម៉ែត្រ |
| 2010441 | ការធ្វើរនាំងឈើទប់ច្រាំង | ម៉ែត្រការេ |
| 2010442 | ការធ្វើរនាំងបេតុងទប់ច្រាំង | ម៉ែត្រការេ |
| 2010443 | ការស្តារស្ទឹង/អូរ | ម៉ែត្រគូប |
| 2010444 | ការស្តារបឹង | ម៉ែត្រគូប |
| 2010445 | ការល្បាតក្នុងដែនសហគមន៍នេសាទ | លើក |
| 2010446 | ការចិញ្ចឹមត្រីក្នុងគង់ | ស្រះ |
| 2010447 | ការបោះបង្គោលព្រំដែនសហគមន៍នេសាទ | បង្គោល |
| 2010448 | ការបោះបង្គោលព្រំដែនការពារស្មៅសមុទ្រ | បង្គោល |
| 2010449 | អភិរក្សអន្លង់ត្រីមេពូជ | កន្លែង |
| 2010450 | ជម្រកត្រីសិប្បនិម្មិត្ត | ប្រអប់ |
| 2010451 | ការដាក់លូអភិរក្សជលវារី | កន្លែង |
| 2010452 | សហគមន៍ទេសចរណ៍តំបន់ដីសើម | គណៈកម្មការ |
| 2010453 | រចនាសម្ព័ន្ធសហគមន៍ទេសចរណ៍តំបន់ដីសើម | គណៈកម្មការ |
| 2010454 | ការបណ្តុះបណ្តាលអំពីការកែច្នៃផលិតផលត្រី | វគ្គ |
| 2010455 | ការបណ្តុះបណ្តាលអំពីការកែច្នៃកាពិ | វគ្គ |
| 2010456 | ការបង្ហាញអំពីកែច្នៃផលិតផលកាពិ | បង្ហាញ |
| 2010457 | គម្រោងរៀបចំសហគមន៍នេសាទ | សហគមន៍ |
| 2010499 | គម្រោងការងារជលផលផ្សេងទៀត | |
| **2020000** | **ដីធ្លី** | |
| 2020001 | បទបញ្ជាផ្ទៃក្នុងនៃការប្រើប្រាស់ដី | លក្ខន្តិកៈ |
| 2020002 | ការដោះស្រាយទំនាស់ដីធ្លី | ករណី |
| 2020003 | ករណីទំនាស់ដីធ្លីបានដោះស្រាយ | ករណី |
| 2020004 | ការសម្រុះសម្រួលទំនាស់ដីធ្លីអហឹង្សា | ករណី |

| លេខកូដ | ការពិពណ៌នា | ឯកតា |
|---|---|---|
| 2020005 | បង្កើតគណៈកម្មការដោះស្រាយទំនាស់ប្រពៃណី | គណៈកម្មការ |
| 2020006 | គណៈកម្មការគ្រប់គ្រងដីធ្លី | គណៈកម្មការ |
| 2020007 | ការផ្សព្វផ្សាយច្បាប់ភូមិបាល និងអនុក្រឹត្យពាក់ព័ន្ធ | វគ្គ |
| 2020008 | ធ្វើសម្បទានដីសង្គមកិច្ចដល់គ្រួសារគ្មានដី | គ្រួសារ |
| 2020009 | សម្បទានសេដ្ឋកិច្ចសហគមន៍ | ហិកតា |
| 2020010 | ការចុះបញ្ជីនីតិបុគ្គលសហគមន៍ | សហគមន៍ |
| 2020011 | ធ្វើកម្មសិទ្ធិដីធ្លីសហគមន៍ | ប័ណ្ណ |
| 2020012 | ការចុះបញ្ជីដីដាច់ដោយដុំ | ប័ណ្ណ |
| 2020013 | ការចុះបញ្ជីដីជាប្រព័ន្ធ | ប័ណ្ណ |
| 2020014 | ផែនទីសម្រាប់ផែនការប្រើប្រាស់ដីធ្លី | ផែនទី |
| 2020015 | ផែនទីសម្រាប់ផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម | ផែនទី |
| 2020016 | ផែនទីដីរដ្ឋ | ផែនទី |
| 2020099 | គម្រោងការងារដីធ្លីផ្សេងទៀត | |
| **2030000** | **ឧស្សាហកម្មរ៉ែនិងថាមពល** | |
| 2030001 | បទបញ្ជាផ្ទៃក្នុងសហគមន៍រ៉ែ | លក្ខន្តិកៈ |
| 2030002 | បង្កើតគណៈកម្មការគ្រប់គ្រងរ៉ែ | គណៈកម្មការ |
| 2030003 | បណ្តុះបណ្តាលអំពីបច្ចេកទេសដាំល្ហុងប្រេង | វគ្គ |
| 2030004 | ការធ្វើបង្ហាញអំពីការដាំល្ហុងប្រេង | បង្ហាញ |
| 2030005 | ការដាំដើមកន្ទំថេតសម្រាប់ជីវឧស្ម័ន | ហិកតា |
| 2030006 | ម៉ាស៊ីនកែច្នៃល្ហុងប្រេងសហគមន៍ | សហគមន៍ |
| 2030007 | ក្រុមកសិករផលិតស្ករត្នោត | ក្រុម |
| 2030008 | បណ្តុះបណ្តាលអំពីចង្ក្រានសន្សំសំចៃអុស | វគ្គ |
| 2030009 | បណ្តុះបណ្តាលអំពីការធ្វើចង្ក្រានសន្សំសំចៃអុស | បង្ហាញ |
| 2030010 | ការផ្គត់ផ្គង់ និងបណ្តុះបណ្តាលអំពីចង្ក្រានជីវឧស្ម័ន | បង្ហាញ |
| 2030011 | ការផ្គត់ផ្គង់ និងបណ្តុះបណ្តាលអំពីម៉ាស៊ីនភ្លើងប្រើជីវឧស្ម័ន | កន្លែង |
| 2030012 | ការផ្គត់ផ្គង់ និងបណ្តុះបណ្តាលអំពីបន្ទះថាមពលព្រះអាទិត្យ(ផ្ទាំងសូឡា) | កំប្លេ |
| 2030013 | ការរៀបចំសមាគមអាជីវករធ្វើស្រែអំបិល | សមាគម |
| 2030014 | គម្រោងសហគមន៍ផលិតទឹកបរិសុទ្ធ | សហគមន៍ |
| 2030099 | គម្រោងការងារឧស្សាហកម្មរ៉ែ និងថាមពលផ្សេងទៀត | |
| **2040000** | **បរិស្ថាន** | |
| 2040001 | ការបង្កើនការយល់ដឹងអំពីច្បាប់បរិស្ថាន | វគ្គ |
| 2040002 | បណ្តុះបណ្តាលអំពីការបំពុលបរិស្ថាន និងឥទ្ធិពលរបស់វា | វគ្គ |
| 2040003 | ប៉ាណូផ្សព្វផ្សាយបរិស្ថាន | ប៉ាណូ |

| លេខកូដ | ការពិពណ៌នា | ឯកតា |
|---|---|---|
| 2040004 | កិច្ចព្រមព្រៀងសហគមន៍តំបន់ការពារ | កិច្ចព្រមព្រៀង |
| 2040005 | រចនាសម្ព័ន្ធសហគមន៍គ្រប់គ្រងទីជម្រាល | គណៈកម្មការ |
| 2040006 | រចនាសម្ព័ន្ធសហគមន៍តំបន់ការពារ | គណៈកម្មការ |
| 2040007 | ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារ | ផែនការ |
| 2040008 | រចនាសម្ព័ន្ធសហគមន៍គ្រប់គ្រងកាកសំណល់សហគមន៍ | គណៈកម្មការ |
| 2040009 | រទេះដឹកសំរាម | រទេះ |
| 2040010 | រថយន្តដឹកសំរាម | រថយន្ត |
| 2040011 | ធុងសំរាម | ធុងសំរាម |
| 2040012 | ទិវាបរិស្ថាន | លើក |
| 2040013 | ការបង្ហាញអំពីឡដុតសំរាម | ឡ |
| 2040014 | ការបង្ហាញអំពីការគ្រប់គ្រងសារធាតុពុលគ្រោះថ្នាក់ | បង្ហាញ |
| 2040015 | ការបណ្ដុះបណ្ដាលអំពីការកែច្នៃសំរាម | វគ្គ |
| 2040016 | គម្រោងរៀបចំវេទិកាផ្សព្វផ្សាយការបំពុលបរិស្ថាន | វេទិកា |
| 2040017 | គម្រោងបង្កើតថ្នាលបណ្ដុះកូនឈើ និងដាំកូនឈើ | ថ្នាល |
| 2040018 | គម្រោងការពារព្រៃលិចទឹក | ម៉ែត្រការ៉េ |
| 2040019 | គម្រោងទប់ស្កាត់បទល្មើសនេសាទ | ករណី |
| 2040020 | គម្រោងរៀបចំសហគមន៍ព្រៃឈើ | សហគមន៍ |
| 2040021 | គម្រោងផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ | វគ្គ |
| 2040022 | គម្រោងការរៀបចំវិធានការទប់ទល់គ្រោះធម្មជាតិ | ដង |
| 2040023 | គម្រោងការឆ្លើយតបនឹងគ្រោះមហន្តរាយ និងការបន្សុំា(ទឹកជំនន់ ខ្យល់ព្យុះ រាំងស្ងួត...) | ដង |
| 2040024 | គម្រោងរៀបចំសហគមន៍ប្រើប្រាស់ទឹក | សហគមន៍ |
| 2040099 | គម្រោងការងារបរិស្ថានផ្សេងទៀត | |
| **2050000** | **ទេសចរណ៍វប្បធម៌ប្រពៃណី** | |
| 2050001 | រចនាសម្ព័ន្ធសហគមន៍ទេសចរវប្បធម៌ | គណៈកម្មការ |
| 2050002 | លក្ខន្តិកៈសហគមន៍ទេសចរណ៍ | លក្ខន្តិកៈ |
| 2050003 | រចនាសម្ព័ន្ធសហគមន៍ទេសចរធម្មជាតិ | គណៈកម្មការ |
| 2050004 | កិច្ចព្រមព្រៀងសហគមន៍ទេសចរណ៍ | កិច្ចព្រមព្រៀង |
| 2050005 | បណ្ដាញសហគមន៍វត្ថុអនុស្សាវរីយ៍ | សហគមន៍ |
| 2050006 | សហគមន៍ផលិតវត្ថុអនុស្សាវរីយ៍ | សហគមន៍ |
| 2050007 | សហគមន៍ចម្លាក់ថ្ម/ឈើ | សហគមន៍ |
| 2050008 | បណ្ដុះបណ្ដាលអំពីការបង្កើតសហគមន៍ទេសចរណ៍ | វគ្គ |
| 2050009 | បណ្ដុះបណ្ដាលអំពីសិប្បកម្មសំបកសិប្បីសត្វ | វគ្គ |

| លេខកូដ | ការពិពណ៌នា | ឯកតា |
|---|---|---|
| 2050010 | ការជ្រើសរើសមគ្គុទេសន៍ទេសចរណ៍ | ក្រុម |
| 2050011 | បណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រ | វគ្គ |
| 2050012 | បណ្តុះបណ្តាលអំពីមគ្គុទេសទេសចរណ៍ | វគ្គ |
| 2050013 | បណ្តុះបណ្តាលអំពីការផលិតវត្ថុអនុស្សាវរីយ៍ | វគ្គ |
| 2050014 | បណ្តុះបណ្តាលអំពីចម្លាក់ថ្មឬឈើ | វគ្គ |
| 2050015 | បណ្តុះបណ្តាលអំពីរបាំប្រពៃណី | វគ្គ |
| 2050016 | បណ្តុះបណ្តាលអំពីភ្លេងប្រពៃណី | វគ្គ |
| 2050017 | បណ្តុះបណ្តាលអំពីតន្ត្រីសម័យ | វគ្គ |
| 2050018 | បណ្តុះបណ្តាលអំពីសិប្បកម្មរពាក់ | វគ្គ |
| 2050019 | ការបង្កើតក្រុមតន្ត្រីបុរាណនិងសម័យ | ក្រុម |
| 2050020 | ការបង្កើតផ្ទះសំណាក់សហគមន៍ | ខ្នងផ្ទះ |
| 2050021 | ធ្វើផែនទីតំបន់សហគមន៍ទេសចរណ៍ធម្មជាតិ | ផែនទី |
| 2050022 | ផែនការគ្រប់គ្រងសហគមន៍ទេសចរណ៍ | ផែនការ |
| 2050023 | ការបង្កើតកន្លែងលក់វត្ថុអនុស្សាវរីយ៍ | កន្លែង |
| 2050024 | គម្រោងបណ្តុះបណ្តាលជំនាញចម្លាក់ និងស្មូនរូប | វគ្គ |
| 2050025 | គម្រោងពង្រឹងពង្រីកសិល្បៈ វប្បធម៌ជនជាតិដើមភាគតិច | ដង |
| 2050099 | គម្រោងការងារទេសចរណ៍វប្បធម៌ប្រពៃណីផ្សេងទៀត | |
| **2060000** | **អប់រំ** | |
| 2060001 | ថ្នាក់អក្ខរកម្មសម្រាប់មនុស្សពេញវ័យ | ថ្នាក់ |
| 2060002 | ថ្នាក់មត្តេយ្យសិក្សាសហគមន៍ | ថ្នាក់ |
| 2060003 | ការអប់រំឳពុកម្តាយនិងអ្នកថែទាំកុមារ | ភូមិ |
| 2060004 | ទារកដ្ឋាន | កន្លែង |
| 2060005 | គាំទ្រអាហារូបករណ៍ដល់កុមារ | នាក់ |
| 2060006 | យុទ្ធនាការផ្សព្វផ្សាយការងារអប់រំ | វគ្គ |
| 2060007 | វគ្គបណ្តុះបណ្តាលស្តីពីការងារអប់រំ | វគ្គ |
| 2060008 | គម្រោងផ្តល់អាហារូបករណ៍ដល់សិស្សស្រីនៅកម្រិតអនុវិទ្យាល័យ | នាក់ |
| 2060009 | គម្រោងរៀបចំ និងដំណើរការមត្តេយ្យសហគមន៍ | ថ្នាក់ |
| 2060099 | គម្រោងការងារអប់រំផ្សេងទៀត | |
| **2070000** | **សុខាភិបាល** | |
| 2070001 | យុទ្ធនាការផ្សព្វផ្សាយស្តីពីសុខភាពមាតា និងទារក | វគ្គ |
| 2070002 | ការបង្កើតផ្ទះរងចាំសម្រាប់ស្ត្រីមានផ្ទៃពោះ | កន្លែង |
| 2070003 | ពង្រឹងមធ្យោបាយបញ្ជូនស្ត្រីមានផ្ទៃពោះទៅមន្ទីរពេទ្យ | កិច្ចព្រមព្រៀង |
| 2070004 | វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពអ្នកស្ម័គ្រចិត្តសុខភាពភូមិ | វគ្គ |

| លេខកូដ | ការពិពណ៌នា | ឯកតា |
|---|---|---|
| 2070005 | វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព | វគ្គ |
| 2070006 | យុទ្ធនាការផ្សព្វផ្សាយស្តីពីសុខភាពបន្តពូជ និងការពន្យារកំណើត | វគ្គ |
| 2070007 | យុទ្ធនាការផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការឆ្លងមេរោគអេដស៍ | វគ្គ |
| 2070008 | ផ្ញើឯកសារអប់រំស្តីពីសុខភាព (សុខភាពបន្តពូជ សុខភាពមាតា និងទារក ការពន្យារកំណើត ជំងឺអេដស៍ជំងឺឆ្លង) | ឯកសារ |
| 2070009 | យុទ្ធនាការផ្តល់សេវាសុខភាព រួមទាំងសុខភាពបន្តពូជ មាតា និងទារក ពេលមានគ្រោះមហន្តរាយ | ដង |
| 2070010 | អប់រំផ្សព្វផ្សាយទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារពេលមានគ្រោះមហន្តរាយ | ដង |
| 2070011 | គម្រោងផ្សព្វផ្សាយអំពីកិច្ចការពារជំងឺផ្តាសាយបក្សី | ដង |
| 2070012 | គម្រោងបណ្តុះបណ្តាលអ្នកទ្រទ្រង់សុខភាពភូមិ | វគ្គ |
| 2070013 | គម្រោងផ្សព្វផ្សាយអំពីជំងឺកាមរោគ មេរោគអេដស៍ ជំងឺអេដស៍ និងវិធានការការពារ | ដង |
| 2070014 | គម្រោងចាក់ថ្នាំបង្ការជំងឺ៨មុខដល់កុមារ | នាក់ |
| 2070015 | គម្រោងកាត់បន្ថយអត្រាមរណៈភាពរបស់មាតា និងទារក | |
| 2070016 | គម្រោងផ្សព្វផ្សាយ លើកកម្ពស់អាហាររូបត្ថម្ភ | វគ្គ |
| 2070017 | គម្រោងផ្សព្វផ្សាយអប់រំអំពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទដល់យុវជន | វគ្គ |
| 2070018 | គម្រោងផ្តល់សេវាប្រឹក្សាយោបល់ផ្លូវចិត្ត | នាក់ |
| 2070019 | គម្រោងបញ្ជូនស្ត្រីក្នុងគ្រួសារក្រីក្រទៅទទួលសេវាពន្យារកំណើតនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក | នាក់ |
| 2070020 | គម្រោងគាំទ្រ និងឧបត្ថម្ភការប្រើប្រាស់សេវាសុខភាពសាធារណៈដល់ស្ត្រីក្រីក្រ ដូចជា មធ្យោបាយធ្វើដំណើរ និងតម្លៃសេវាមណ្ឌលសុខភាព | នាក់ |
| 2070021 | គម្រោងអប់រំផ្សព្វផ្សាយដល់យុវជនឱ្យចូលរួមសកម្មភាពធ្វើអនាម័យ និងការការពារបរិស្ថានក្នុងសហគមន៍ | វគ្គ |
| 2070022 | ការផ្សព្វផ្សាយអំពីអាហាររូបត្ថម្ភ និងសុខភាពមាតា និងទារក | វគ្គ |
| 2070023 | គម្រោងផ្តល់ជំនួយសុខាភិបាលដល់ជនរងគ្រោះដោយសារគ្រោះធម្មជាតិ | នាក់ |
| 2070099 | គម្រោងការងារសុខាភិបាលផ្សេងទៀត | |
| **2080000** | **ការងារយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម** | |
| 2080001 | គម្រោងពង្រឹងបណ្តាញស្ត្រី | ចំនួន |
| 2080002 | គម្រោងស្តារលទ្ធភាពពលកម្មជនពិការ | នាក់ |
| 2080003 | គម្រោងលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ | ករណី |
| 2080004 | គម្រោងការពារ និងទប់ស្កាត់អំពើរំលោភបំពានផ្លូវភេទ និងជួញដូរមនុស្ស | ករណី |
| 2080005 | គម្រោងលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារី | ករណី |
| 2080006 | គម្រោងពង្រឹងបណ្តាញស្ត្រីវ័យក្មេង ដើម្បីចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍នានា | ចំនួន |

| លេខកូដ | ការពិពណ៌នា | ឯកតា |
|---|---|---|
| 2080007 | គម្រោងលើកកម្ពស់យុវជនចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍នានា | ដង |
| 2080008 | គម្រោងផ្ដល់សេវាគាំពារចាស់ជរា | នាក់ |
| 2080009 | គម្រោងផ្ដល់សេវាគាំពារជនពិការ | នាក់ |
| 2080010 | គម្រោងទប់ស្កាត់ការចំណាកស្រុកដោយខុសច្បាប់ | ករណី |
| 2080011 | គម្រោងទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារដែលរងគ្រោះ ដោយសារគ្រោះធម្មជាតិ | ករណី |
| 2080012 | គម្រោងបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់ស្ត្រី | វគ្គ |
| 2080013 | គម្រោងបង្កើនប្រាក់ចំណូលរបស់ស្ត្រី | នាក់ |
| 2080014 | គម្រោងបង្កើតក្រុមជួយខ្លួនឯង | ក្រុម |
| 2080015 | គម្រោងបង្កើនប្រាក់ចំណូល តាមរយៈ ការបង្កើតមុខរបរខ្នាតតូច | គ្រួសារ |
| 2080099 | គម្រោងការងារយែនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមផ្សេងទៀត | |
| **2090000** | **រដ្ឋបាល សន្តិសុខសាធារណៈ** | |
| 2090001 | គម្រោងលើកកម្ពស់សុវត្ថិភាពចរាចរណ៍ | វគ្គ |
| 2090002 | គម្រោងគ្រប់គ្រងទិន្នន័យជនអន្តោប្រវេសន៍ | ទិន្នន័យ |
| 2090003 | គម្រោងពង្រឹងកម្មវិធីប្រជាការពារ | |
| 2090004 | គម្រោងអប់រំផ្សព្វផ្សាយអំពីគ្រឿងញៀន | វគ្គ |
| 2090005 | គម្រោងទប់ស្កាត់ និងលុបបំបាត់ក្រុមក្មេងទំនើង | ករណី |
| 2090006 | គម្រោងទប់ស្កាត់ចោរកម្ម | ករណី |
| 2090007 | គម្រោងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ | ករណី |
| 2090008 | គម្រោងទប់ស្កាត់ការរំលោភបំពានផ្លូវភេទ និងការជួញដូរមនុស្ស | ករណី |
| 2090009 | គម្រោងត្រួតពិនិត្យទំនិញហួសកាលបរិច្ឆេទប្រើប្រាស់ | ដង |
| 2090010 | គម្រោងពង្រឹងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព | ដង |
| 2090011 | គម្រោងរៀបចំសណ្ដាប់ធ្នាប់ចំណតយានយន្ត | កន្លែង |
| 2090099 | គម្រោងរដ្ឋបាល សន្តិសុខសាធារណៈផ្សេងទៀត | |